ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- បណ្ណាល័យសម្តេចម៉ែ មជ្ឈមណ្ឌលឯកសារកម្ពុជា
- ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ផាទ្រីក មូហ្វី ធ្វើទស្សនកិច្ចទៅកាន់អន្លង់វែង
- ដំណើរស្វែងរកឪពុកដែលជាជនភៀសខ្លួនជនជាតិខ្មែរ របស់ អាទីន ទេនីហ្សូអេឡា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៤៧ ខែកក្កដា ឆ្នាំ២០២០

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៤៧ ខែកក្កដា ឆ្នាំ២០២០


## មាតិកា


### សំបុត្រ

- បណ្ណាល័យសម្តេចម៉ែ ........................ ១
- ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ផាទ្រីក មូហ៊ី.. ៤

### ផ្នែកឯកសារ

- ក្រិស យ៉េន ហៅ សុឃុន មេក្រុមកុមារ ..... ៧
- ចម្លើយរបស់ គឹម លីង ហៅ លន់ ......... ១១
- ញឹក វុធ បម្រុងរត់ទៅសៀម............... ១៣
- នាង សាង ត្រូវបានចាប់ខ្លួនដោយសារ .... ១៥

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

- ដំណើរស្វែងរកឪពុកដែលជាជនភៀសខ្លួន ... ១៨
- ដំណើរជីវិតរបស់ ព្រំ ធិន នៅក្នុងសម័យ ... ២១
- បូជាភ្លើង.................................. ២៣
- ភូមិសាទុំ ................................ ២៨

### ផ្នែកច្បាប់

- សាលក្រមសំណុំរឿង០០២/០២ .......... ៣២

### ផ្នែកវេទិកាសាធារណៈ

- ភាពមន្ទិលសង្ស័យពីដំណើរជីវិតឪពុកខ្ញុំ...... ៤០

### ផ្នែកស្រាវជ្រាវរកគ្រួសារ

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មី ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

- ម៉ៃ ភី ៖ ប៉ូលីស........................... ៤៨
- គង់ មារតី ៖ ធនាគារិក.................... ៥០
- ប៊ួយ ស្រេង ៖ អ្នកបោះពុម្ព កាសែត........ ៥៣
- កៅ សំរិទ្ធ ................................ ៥៥
- បញ្ជីឈ្មោះអ្នកដែលបានស្លាប់............. ៥៩




កងកុមារលើកទំនប់នៅការដ្ឋានការងារមួយកន្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** ឆាំង យុ, លី សុខឃាង, សុខ វណ្ណៈ ហេឌី ហ្វ្រាយ, ប៊ាង ពីរីន្ត, វេនី ខកហ្កៀល, កៅ សំរិទ្ធ, វ៉ាន់ថាន់ ពៅដារ៉ា និងឡុង ដានី
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ផុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដាវី **អ្នកបកប្រែ៖** អ៊ុន សុដាវី
**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ផុនា
**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉ែង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org




# បណ្ណាល័យសម្តេចម៉ែ

## មជ្ឈមណ្ឌលឯកសារកម្ពុជា

**ឆាំង យុ**



សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ព្រះអង្គសព្វព្រះរាជហឫទ័យ ព្រះបរមរាជានុញ្ញាតឲ្យលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រាបបង្គំចូលគាល់ ដើម្បីប្រកាសថ្វាយឈ្មោះ «បណ្ណាល័យសម្តេចម៉ែ» នៅព្រះបរមរាជវាំង ក្នុងទីក្រុងភ្នំពេញ។ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ ព្រះវររាជមាតា ទ្រង់បានសព្វព្រះហឫទ័យរាជានុញ្ញាតឲ្យប្រើប្រាស់ឈ្មោះ «បណ្ណាល័យសម្តេចម៉ែ» ជាផ្លូវការ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

> **ថ្វាយព្រះកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតដល់សម្តេចម៉ែ ដែលជា សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះសកម្មភាពគាំពារការសិក្សាស្រាវជ្រាវនិងការលើកស្ទួយប្រវត្តិសាស្ត្រ វប្បធម៌ ព្រមទាំងសិល្បៈសហសម័យនៃប្រទេសកម្ពុជា**

ការសិក្សាស្រាវជ្រាវ ការអប់រំ និងវប្បធម៌ គឺមានសារសំខាន់ ចំពោះអត្តសញ្ញាណនិងការអភិវឌ្ឍរបស់ប្រទេសជាតិមួយ និងការបោះជំហានទៅមុខរបស់មនុស្សជាតិ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ពុះពារធានាថាប្រវត្តិសាស្ត្រនិងសិល្បៈរបស់ប្រទេសកម្ពុជា ទាំងបុរាណ និងសហសម័យ នឹងត្រូវបានអភិរក្ស ការពារ និងបើកទូលាយសម្រាប់សាធារណជនទូទៅ។



បណ្ណាល័យសម្តេចម៉ែ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





បណ្ណាល័យសម្តេចម៉ែ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នាពេលថ្មីៗនេះ ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ដែលជ្រេស អតីតលេខាផ្ទាល់ និងជាអ្នកនិពន្ធជីវប្រវត្តិរបស់ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បានបរិច្ចាគសមុច្ច័យផ្ទាល់ខ្លួនទាំងស្រុងរបស់លោក ដែលរួមមាន សៀវភៅនិងឯកសារផ្សេងៗ មកកាន់បណ្ណាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ដើម្បីធ្វើការទទួលស្គាល់ការចូលរួមចំណែកដ៏មានតម្លៃនេះ ព្រមទាំងជាការថ្វាយព្រះកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំពោះកិច្ចខិតខំប្រឹងប្រែងពេញមួយជីវិតរបស់ព្រះវររាជមាតា សម្តេចព្រះ នរោត្តម មុនិនាថ សីហនុ ចំពោះប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងដាក់ឈ្មោះបណ្ណាល័យរបស់ខ្លួនថា «**បណ្ណាល័យសម្តេចម៉ែ**» ដោយទទួលបានព្រះរាជានុញ្ញាតពីសម្តេចព្រះវររាជមាតា។

បន្ថែមពីលើសមុច្ច័យរបស់ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ដែលជ្រេស បណ្ណាល័យសម្តេចម៉ែ មានតម្កល់ទុកឯកសារប្រវត្តិសាស្ត្រ សៀវភៅ និងសម្ភារផ្សេងៗ ស្តីពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងនឹងបន្តពង្រីកបន្ថែមនូវចំនួនបណ្តុំឯកសាររបស់ខ្លួន។

បណ្ណាល័យនេះនឹងជាប្រភពធនធានដ៏មានសារសំខាន់មួយសម្រាប់សិស្សានុសិស្ស និងអ្នកស្រាវជ្រាវទូទៅ ដោយដើរតួនាទីជាស្ថាប័នមួយដែលបើកទូលាយសម្រាប់សាធារណជន ដើម្បីបង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រ វប្បធម៌ និងសិល្បៈសហសម័យរបស់កម្ពុជា។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានក្រាបបង្គំចូលគាល់ព្រះវររាជមាតា និងរាជវង្សានុវង្ស ដើម្បីប្រកាសថ្វាយឈ្មោះនេះជាផ្លូវការ។ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ ព្រះវររាជមាតា ទ្រង់បានសព្វព្រះហឫទ័យរាជានុញ្ញាតឲ្យប្រើប្រាស់ឈ្មោះបណ្ណាល័យនេះ។

«**បណ្ណាល័យសម្តេចម៉ែ**» នឹងដើរតួនាទីជាទីតម្កល់ទុកឯកសារបណ្ណសារ សៀវភៅ និងសម្ភារផ្សេងៗដែលមានសារៈសំខាន់ចំពោះជាតិ រហូតដល់មានវត្តមានរបស់វិទ្យាស្ថានស្លឹករឹត ដែលជាបូជនីយដ្ឋាននៃការចងចាំពិភពលោកមួយ រចនាឡើងដោយលោកស្រី ហ្សាហា ហាឌីដ ដើម្បីឧទ្ទិសជូនដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅជុំវិញពិភពលោក។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺកំពុងបន្តស្រាវជ្រាវរកមូលនិធិគាំទ្រ វិទ្យាស្ថានស្លឹករឹត និងធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីទទួលបានការគាំទ្រសម្រាប់អនាគតដៃគូវិនិយោគរបស់ខ្លួន។

នៅពេលបញ្ចប់ការសាងសង់ វិទ្យាស្ថានស្លឹករឹត បន្ថែមលើបណ្ណាសារ នឹងរួមមាន សារមន្ទីរ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវលើអំពើប្រល័យពូជសាសន៍ មជ្ឈ-មណ្ឌលអប់រំស្តីពីការសិក្សា និងបង្ការអំពើប្រល័យពូជសាសន៍ និងសាវនដ្ឋានសម្រាប់រៀបចំពិព័រណ៍ ការប្រគុំតន្ត្រី និងការធ្វើបទបង្ហាញនានា។

ការបង្កើតឲ្យមាន «**បណ្ណាល័យសម្តេចម៉ែ**» គឺជាព្រឹត្តិ-ការណ៍មួយដ៏មានសារសំខាន់ចំពោះជាតិ។ ការបង្កើតជា «**បណ្ណាល័យសម្តេចម៉ែ**» គឺមិនត្រឹមតែបង្ហាញអំពីការចាប់ផ្តើមកកើតធនធានថ្មីសម្រាប់ការអប់រំការសិក្សាស្រាវជ្រាវ និងការលើកស្ទួយសិល្បៈសហសម័យតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការទទួលស្គាល់ចំពោះការលះបង់របស់ព្រះវររាជមាតាជូនដល់ ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងការពុះពារ របស់ព្រះវររាជមាតាដ៏ខ្ពង់ខ្ពស់ ចំពោះប្រជាជនកម្ពុជា។

# ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ផាទ្រីក មូហ្វី
## ធ្វើទស្សនកិច្ចទៅកាន់អន្លង់វែង

លី សុខឃាង



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា លោក ផាទ្រីក មូហ្វី កំពុងស្តាប់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើបទបង្ហាញទាក់ទងនឹងរូបថតនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅលើខ្នងភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា ឯកឧត្តម ផាទ្រីក មូហ្វី បានធ្វើទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែងជាលើកដំបូង។ អន្លង់វែង គឺជាអតីតតំបន់សង្គ្រាមរវាងកងកម្លាំងខ្មែរក្រហម និងកងកម្លាំងរបស់រដ្ឋាភិបាលរហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៩០។ អន្លង់វែងមានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រចំនួន ១៤ ដែលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានទទួលកាតព្វកិច្ចអភិវឌ្ឍ និងអភិរក្សយ៉ាងខ្ជាប់ខ្ជួន។ ក្នុងអំឡុងពេលទស្សនកិច្ចនេះ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានជួបជាមួយបុគ្គលិក ពិនិត្យមើលការងារនិងបណ្ណសារនៅក្នុងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលមជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

បន្ទាប់មក គណៈប្រតិភូបានបន្តធ្វើដំណើរទស្សនកិច្ចទៅសារមន្ទីរអតីតផ្ទះតាម៉ុក និងអតីតផ្ទះប្រជុំរបស់តាម៉ុកនៅលើភ្នំដងរែក ដែលបច្ចុប្បន្នគឺជាបន្ទប់ប្រជុំ និងបន្ទប់រៀនរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

### ទស្សនកិច្ចទៅកាន់សារមន្ទីរអតីតផ្ទះតាម៉ុក

បន្ទាប់ពីឈានជើងចុះពីរថយន្ត ឯកឧត្តម ឯកអគ្គរដ្ឋទូត បានឃើញផ្ទាំងព័ត៌មានស្តីពីកាលប្បវត្តិប្រវត្តិសាស្ត្រនៃចលនាកម្មុយនីស្តខ្មែរក្រហម និងរថយន្តបាក់បែកទ្រុឌទ្រោមដែលធ្លាប់ជាស្ថានីយវិទ្យុផ្សាយសំឡេងចល័ត ដែលខ្មែរក្រហមបានប្រើដើម្បីផ្សព្វផ្សាយព័ត៌មានទៅកាន់មហាជន។ ស្ថិតនៅចម្ងាយតែប៉ុន្មានម៉ែត្រពីរថយន្តនេះ គឺមានទ្រុងចំនួនពីរ។ ភ្ញៀវជាតិនិងអន្តរជាតិទាំងឡាយអាចសន្និដ្ឋានថា ទ្រុងទាំងពីរនេះ គឺត្រូវបានប្រើសម្រាប់ដាក់សត្វ មានដូចជាសត្វខ្លាជាដើម។ ដើមឡើយ តាម៉ុកពិតជាបានប្រើទ្រុងនេះដើម្បីដាក់សត្វមែន ប៉ុន្តែក្រោយមក បានប្រែក្លាយទៅជាទ្រុងដាក់មនុស្សវិញ។ មេបញ្ជាការកងទ័ពដែលតាម៉ុកយល់ថាមិនស្មោះត្រង់ ត្រូវបានចាប់ដាក់ក្នុងទ្រុងនេះ និងសម្លាប់ចោល។

ឯកឧត្តម ឯកអគ្គរដ្ឋទូត បានដើរទៅកាន់ផ្ទះបន្ទាប់ដែលមានរូបបដិមាសម្រាប់បន់ស្រន់នៅចំពីមាត់ច្រកចូល និងមានផែនទីប្រទេសកម្ពុជា ប្រាសាទព្រះវិហារ និងអង្គរវត្ត ដែលគូសដោយដៃ។ នៅពីខាងមុខគំនូរទាំងអស់នេះមានពិព័រណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលរំលេចឲ្យឃើញពីដំណើរសាច់រឿង និងរូបថតនៃអតីតកម្មាភិបាលខ្មែរក្រហម។ ឯកឧត្តម ឯកអគ្គរដ្ឋទូត ក៏បានប្រាប់ឲ្យខ្ញុំបកប្រែប្រវត្តិរូប និងបទចោទប្រឆាំងនឹងអៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃកម្ពុជាប្រជាធិបតេយ្យ នៅលើទម្រពិព័រណ៍នោះ។

នៅឯជាន់ទីមួយនៃផ្ទះនេះដែរ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានចាប់អារម្មណ៍ពិព័រណ៍អចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីរយៈកាលឆ្ពោះទៅកាន់សង្គ្រាមនៅប្រទេសកម្ពុជា។ នៅក្នុងពិព័រណ៍មានរូបថតជាច្រើនដែលត្រូវបានថតតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០ មក ម្ល៉េះពិព័រណ៍រូបថតនេះស្តែងឲ្យឃើញពីសកម្មភាពសង្គមកងទ័ព និងសន្និសីទកាសែតរបស់មន្ត្រីនៃរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់។

ផ្ទះទីបីរបស់ តាម៉ុក ត្រូវបានប្រើប្រាស់ទាំងស្រុងសម្រាប់ពិព័រណ៍រូបថតប្រវត្តិសាស្ត្រ។ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានពិនិត្យមើលរូបថតដែលថតក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ដែលក្នុងនោះ លោកឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានចង្អុលប្រាប់អំពីរូបថតមួយសន្លឹក បង្ហាញជនជាតិអាមេរិកាំងមួយរូប ដែលត្រូវបានសម្លាប់នៅក្នុងអំឡុងរបបខ្មែរក្រហម។



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា លោក ផាទ្រីក មូហ្វី កំពុងអានសៀវភៅនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅក្នុងទីរួមស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា លោក ផាទ្រីក មូហ្វី និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឈរនៅពើយតាម៉ុក ស្ថិតនៅលើខ្នងភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅ ប្រទេសកម្ពុជា លោក ផាទ្រីក មូហ្វី ជួបជាមួយភ្ញៀវទេសចរដែលមកទស្សនាសារមន្ទីរអតីតផ្ទះតាម៉ុក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។ (សួត វិចិត្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅ ប្រទេសកម្ពុជា លោក ផាទ្រីក មូហ្វី ឈរថតរូបជុំគ្នានៅប្រាកភ្នំក្នុងបរិវេណការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅលើខ្នងភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិព័រណ៍រូបថតចុងក្រោយ បានបង្ហាញពីជីវិតរបស់ប្រជាជនដែលរស់នៅក្នុងតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម ក្នុងអំឡុងពេលដំណាក់កាលចុងក្រោយនៃសង្គ្រាម និងការធ្វើសមាហរណកម្មនៅក្នុងឆ្នាំ១៩៩៨។

ផ្ទះទី៤ ត្រូវបានគ្រោងប្រែក្លាយទៅជាបន្ទប់សិល្បៈសោតទស្សន៍នាពេលអនាគត ដែលភ្ញៀវជាតិ និងអន្តរជាតិ នឹងអាចទស្សនាភាពយន្តឯកសារ និងឆ្លុះបញ្ចាំងពីដំណើរទស្សនកិច្ចបែបប្រវត្តិសាស្ត្ររបស់ខ្លួន។

**អតីតផ្ទះប្រជុំរបស់តាម៉ុក**
**(បច្ចុប្បន្ន មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង)**

បន្ទាប់ពីបានចំណាយពេលជិតមួយម៉ោងនៅសារមន្ទីរ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានបន្តដំណើរឆ្ពោះទៅអតីតផ្ទះប្រជុំរបស់តាម៉ុក នៅលើភ្នំដងរែក ដែលលោក ឆាំង យុ បានជម្រាបជូន ឯកឧត្តម ឯកអគ្គរដ្ឋទូត អំពីការសាងសង់វិមានឈ្នះ ឈ្នះ នាពេលខាងមុខ នៅក្បែរមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ចំណែកឯនៅខាងក្នុងមជ្ឈមណ្ឌលសន្តិភាព ឯកឧត្តម ឯកអគ្គរដ្ឋទូត បានទស្សនាពិព័រណ៍ស្តីពីសម័យខ្មែរក្រហម និងពិធីធ្វើសមាហរណកម្មនៅក្នុងឆ្នាំ១៩៩៨។ បន្ទាប់មក ឯកឧត្តម ឯកអគ្គរដ្ឋទូតក៏បានដើរមើលប្រាក់ភ្នំដ៏ស្រស់ស្អាត និងប្រកបដោយខ្យល់អាកាសយ៉ាងត្រជាក់នារដូវវស្សានៅក្បែរមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ដំណើរទស្សនកិច្ចបានបញ្ចប់។





# ក្រិស យ៉េន ហៅ សុឃុន មេក្រុមកុមារ នៅមន្ទីរក ១៧ តំបន់១០៥

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D0២៧0២

*អ៊ុន សុជាវី*



កងយោធាខ្មែរក្រហមនៅសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នេះគឺជាចម្លើយរបស់ ក្រិស យ៉េន ហៅ សុឃុន។ សុឃុន ត្រូវបានអង្គការចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៧ រួចយកមកឃុំនៅឯភ្នំក្រោល គឺរយៈពេល១ខែបន្ទាប់ពីផែនការផ្តួលរំលំបដិវត្តន៍នៅឯមណ្ឌលគិរីរបស់គាត់បានបែកការណ៍។ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧ អង្គការបានបញ្ជូន សុឃុន មកឃុំឃាំងនៅមន្ទីរស-២១វិញ។ យោងតាមចម្លើយសារភាពឯកសារ D០២៧០២ សុឃុន បានរៀបរាប់ពីសកម្មភាព និងឈ្មោះបក្ខពួករបស់ខ្លួនយ៉ាងក្បោះក្បាយ ដោយមានឈ្មោះ ជន ឆាយ ជាអ្នកកត់ត្រាការឆ្លើយសារភាពនោះ។ ខាងក្រោមនេះគឺជាការឆ្លើយរៀបរាប់អំពីសកម្មភាពរបស់ សុឃុន មុន និងក្នុងរបបខ្មែរក្រហម៖

ខ្ញុំឈ្មោះ ក្រិស យ៉េន ហៅ សុឃុន។ នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំមានអាយុ២៥ឆ្នាំ។ ខ្ញុំគឺជាជនជាតិខ្មែរកាត់ព្នង។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ក្រង់ រី ធ្វើការនៅមន្ទីរពេទ្យក៨០។ ខ្ញុំមានស្រុកកំណើតនៅភូមិកាទី ឃុំកាទី ស្រុកអូររាំង ខេត្តមណ្ឌលគិរី។ តាំងពីតូចមក ខ្ញុំរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំ។ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាកាទីរហូតដល់ថ្នាក់ទី១០ទើបឈប់រៀន។ ក្រោយពីឈប់រៀន ខ្ញុំបានចូលធ្វើការងារនៅក្នុងក្រសួងតារ៉ូកាទី បានចំនួន៣ខែ។ ខ្ញុំទទួលបានប្រាក់ឧបត្ថម្ភក្នុងមួយខែចំនួន៨០០រៀល។ ក្រោយមក ខ្ញុំក៏ត្រឡប់មកធ្វើស្រែបានមួយរដូវវិញទើបមានរដ្ឋប្រហារកើតឡើង។ ខ្ញុំនៅបន្តធ្វើស្រែរហូតដល់ចុងឆ្នាំ១៩៧២ ទើបមានឈ្មោះ កាស៊ី ដែលជាកម្មាភិបាលខ្មែរក្រហមនៅស្រុកកែវសីម៉ា ដែលបច្ចុប្បន្នប្រធានសហករណ៍ អ ៤ ក្រោមស្រុកកោះញែក តំបន់១០៥ មកអប់រំខ្ញុំឲ្យចូលធ្វើបដិវត្តន៍។ កាស៊ី បានយកខ្ញុំមកនៅមន្ទីរសេដ្ឋកិច្ចនៅក្នុងភូមិចក់ចារក្នុងតំបន់ ១០៥ ដែលមានឈ្មោះ ខាំភួន នៅទីនោះ។ នៅដើមឆ្នាំ១៩៧៣ មន្ទីរចក់ចារបានរើមកនៅស្រុកកោះញែក ដែលបច្ចុប្បន្នហៅមន្ទីរក១៦។ ពេលនោះសភាពការណ៍នៅក្នុងមន្ទីររបស់ខ្ញុំមានសភាពច្របូកច្របល់ខ្លាំង គឺទំនាស់នឹងអង្គការដែលឲ្យរើមន្ទីរមកហើយគ្មានផ្ទះជ្រកកោន ជាពិសេស ខាំភួន ផ្ទាល់តែម្តង។ រស់នៅក្នុងកន្លែងថ្មីនេះ បានរយៈពេលប្រហែល៣ខែ ខាំភួន បានហៅបក្ខពួកខ្ញុំមកអប់រំ។ នៅពេលនោះមានអ្នកចូលរួមមានឈ្មោះ ខាំ គឺជាកូនខាំភួន ដែលនៅក្នុងមន្ទីរក១៦, កាស៊ី, ញូន គឺជាប្រធានមន្ទីរក១៦ របស់តំបន់ ១០៥, ឡាង គឺជាសមាជិកនយោបាយមន្ទីរក១៦, ប៊ុន ធឿន គឺជាមេពួកមន្ទីរក១៦, ឡាំ គឺជាសមាជិកនយោបាយមន្ទីរក១៦, ខ្វាក់ គឺជាមេពួកមន្ទីរក១៦ និងខ្ញុំ។ ចំពោះខ្លឹមសារអប់រំខាំភួនបានលើកឡើងអំពី ១) របបសង្គមចាស់ និងសង្គមបដិវត្តន៍ ។ គាត់បានលើកឡើងថា របបសង្គមបដិវត្តន៍មានការលំបាកព្រាត់ប្រាស់ឆ្ងាយពីឪពុកម្តាយ ធ្វើកាងារគ្មានប្រាក់ខែ និងបុណ្យសក្តិ។ ការងារធ្វើទាំងយប់ទាំងថ្ងៃ ហើយតឹងតែគ្រប់បែបយ៉ាង។ រីឯរបបសង្គមចាស់ ម្តាយឪពុកស្រឡាញ់កូន ថែរក្សាកូន ធ្វើការងារមានបុណ្យសក្តិមានប្រាក់ខែ។ ការរស់នៅវិញដើរហើរសេរី ស៊ីចុកតាមចិត្ត។ ២) លើកឡើងពីសភាពការណ៍ចង់កសាងរដ្ឋអំណាចនៅខេត្តមណ្ឌលគិរីឲ្យទៅជារបបសង្គមចាស់វិញ និង៣) ណែនាំឲ្យបក្ខពួកខ្ញុំចូលរួមសកម្មភាពជាមួយក្រុមគាត់ដណ្តើមរដ្ឋអំណាចពីបដិវត្តន៍មកកាន់កាប់វិញ និងកសាងរបបសង្គមចាស់ ជាពិសេស នៅមណ្ឌលគិរីនេះឲ្យបានមុនគេ។

ក្រោយមក ខាំភួន បានដាក់ភារកិច្ចឲ្យបក្ខពួកខ្ញុំធ្វើ គឺ ទី១) ប្រមូលយកគ្រាប់ អង្ករ អំបិល ខោអាវ ស្បែកជើង អគ្រឹង ចេញពីក្នុងឃ្លាំងមកទុកក្នុងព្រៃ ដើម្បីត្រៀមធ្វើសង្គ្រាមដណ្តើមរដ្ឋអំណាចពីបដិវត្តន៍។ ទី២) ធ្វើសកម្មភាពពេលយប់ដើម្បីរកកាំភ្លើង ស្រូវអង្កររបស់ប្រជាជន។ ទី៣) ស៊ើបពិនិត្យមន្ទីរផ្សេងៗរកអ្នកមានទំនាស់ បុរិបត្តិច្រើននៅក្នុងមន្ទីរ ដើម្បីអូសទាញធ្វើជាកម្លាំង។ ទី៤) ឲ្យទាក់ទងឈ្មោះ អ៊ុយ គឺជាយុទ្ធជនមន្ទីរ១៧ របស់តំបន់១០៥, ភិន គឺជាអតីតកងទ័ពវៀតណាម, ដាំ គឺជាយុវជនមន្ទីរក១៧, ស្រាំ គឺជាយុវជនមន្ទីរក១៧, ប៊ឺន គឺជាមេពួកមន្ទីរក១៧ និង ទី៥) ចុងក្រោយណែនាំឲ្យបក្ខពួកខ្ញុំលាក់ការណ៍ឲ្យជិត។

នៅក្នុងឆ្នាំ១៩៧៣ ពេលដែលខ្ញុំចូលរួមបានប្រហែល ៧ខែ ខាំ ភួន, ខាំ និង កាស៊ី បានប្រាប់ឲ្យខ្ញុំដឹង ថានេះគឺជាខ្សែរយៈខ្មែរស ដោយជនជាតិណាក៏ប្រមូលបញ្ចូលដែរ ជាពិសេស ទាហាន ប៉ូលីស និង រដ្ឋការចាស់។ ក្រោយមកឈ្មោះ ពិនិត្យ និង ឡឺយ កាន់វរសេនាតូចយោធាតំបន់១០៥ មកដឹកនាំបក្ខពួកខ្ញុំឲ្យធ្វើសកម្មភាព និងពង្រឹងពីជិហរលាក់ការណ៍។ ថ្ងៃមួយ ខាំភួនបានឲ្យខ្ញុំជូនគាត់មកស្រុកកែវសីមាជាមួយនីសាររបស់គាត់ម្នាក់ឈ្មោះ ប៊ុន មកប្រជុំជាមួយឈ្មោះ ជិនដើ ដែលជាគណៈស្រុកកែវសីមា។ នៅក្នុងឆ្នាំដដែល ពេលដែលមកធ្វើស្រែម្តងៗ បក្ខពួកខ្ញុំតែងតែពិភាក្សាគ្នាពីចលនាខ្មែរសពីការលំបាកតឹងតែង និងការសប្បាយនៅក្នុងសង្គមចាស់ជាដើម។ ក្រោយមក ខាំភួនបានចាត់តាំងឈ្មោះ ច្រឹយ អតីតយុវជននៅមន្ទីរក១៦ ឲ្យមកនៅក្នុងព្រៃ ដើម្បីចាំគ្រាប់កាំភ្លើង និងសម្ភារផ្សេងៗដែលបក្ខពួកខ្ញុំបានជញ្ជូនយកមកទុក។





នៅឆ្នាំ១៩៧៤ ខ្ញុំរួមជាមួយឈ្មោះ ញូន, ខ្វាក់, ប៊ុន ធឿន, ឡាំ, ឡាង បានអូសទាញកម្លាំងបានបន្ថែម ៦នាក់ទៀត គឺមានឈ្មោះ រ៉ុញ គឺជាមេពួកនៅមន្ទីរក១៧, ងួន គឺជាយុវជននៅមន្ទីរក១៧, នឿន គឺជាយុវជននៅមន្ទីរក១៧, ភ្លៅ គឺជាយុវជននៅមន្ទីរក១៧, តូច គឺជាយុវជននៅមន្ទីរក១៦ និង ភឹម គឺជាយុវជននៅមន្ទីរក១៦។ ចំណែកឯសកម្មភាពជញ្ជូនសម្ភារចេញនេះ គឺក្នុងមួយខែយើងជញ្ជូនចេញចំនួនមួយទៅពីរដងតាមស្ថានការណ៍ជាក់ស្តែង។ នៅក្នុងឆ្នាំដដែលនេះ ខាំភួនបានហៅខ្ញុំឲ្យជូនគាត់មកជួប ច្រឹយ នៅក្នុងព្រៃចាស់អូរយោល។ ក្នុងនោះមានឈ្មោះ ប៊ុន, ខាំ និង ញូន មកជាមួយដែរ។ ពេលជួបនោះ ខាំភួនបានណែនាំច្រឹយថា ឲ្យរៀបចំសម្ភារយកមកទុកឲ្យបានស្រួល, បើគ្មានសំបុត្រឲ្យចូលទៅយកសម្ភារទេមិនចាំបាច់ទៅយកទេ, ត្រូវខំលាក់ការណ៍ឲ្យជិត ដោយប្រុងប្រយ័ត្នខាងយោធាឃើញ ហើយបើមានសភាពការណ៍អ្វីមិនស្រួលត្រូវរត់យករួចខ្លួន កុំឲ្យមានគ្រោះថ្នាក់ហើយ ខាំភួន ក៏បានណែនាំ ច្រឹយ ពីរបៀបទាក់ទងដែរ។ បន្ទាប់ពីណែនាំចប់សព្វគ្រប់អស់ហើយ ក៏ត្រឡប់មកវិញ។ ក្រោយការណែនាំបានប្រហែលបីថ្ងៃ ខាំភួន ក៏ចុះទៅតាមមូលដ្ឋាន និងបានប្រគល់ភារកិច្ចឲ្យឈ្មោះ ញូន ដឹកនាំបក្ខពួកខ្ញុំធ្វើសកម្មភាពបន្តទៀត។ ញូន បានហៅបក្ខពួកខ្ញុំមកណែនាំថា ឲ្យបក្ខពួកខ្ញុំខិតខំបំផុសយុវជនឲ្យដើរតាម ខាំភួន និងលើកពីរបបសង្គមចាស់ជាពិសេសរឿងម៉ែឪមកនិយាយបំផុសបំផុល។

រហូតមកដល់ឆ្នាំ១៩៧៥ ក្រោយពីរំដោះហើយ ខ្ញុំមានការទាក់ទងខ្សែចាស់ដដែល។ ញូនបានចាត់តាំងឲ្យខ្ញុំ, អ៊ុយ រ៉ើយ និង ប៊ុនធឿន មកជួបទាក់ទងជាមួយឈ្មោះ ស្រែម នៅឯសហករណ៍ស្រែ ហ៊ុយ ស្រុកកោះញែកតំបន់១០៥។ បក្ខពួកខ្ញុំបានប្រាប់ទៅ ស្រែម អំពីផែនការអូសទាញកម្លាំងរបស់យើង ហើយ ស្រែម ក៏បានឯកភាពជាមួយដែរ។ ស្រែម បានរាយការណ៍អំពីស្ថានការណ៍នៅក្នុងសហករណ៍ថា នៅក្នុងសហករណ៍របស់គាត់មានទំនាស់គ្នា និងច្របូកច្របល់ណាស់។ មកដល់កន្លែងវិញ យើងបានរាយការណ៍ឲ្យគ្នីគ្នាដឹងពីព័ត៌មានទាំងអស់ដែលយើងទទួលបាន។ ថ្ងៃមួយនៅពេលយប់បន្ទាប់មកពីធ្វើការងារវិញ យើងបានពិភាក្សាគ្នាទៅលើ ១) ការស្វែងរកខ្សែបណ្តាញបន្ថែម ២) ចាត់តាំងខ្ញុំ និង អ៊ុយ ឲ្យដឹកនាំ ៣) ណែនាំទាំងអស់គ្នាឲ្យពិនិត្យមនុស្សដើម្បីអូសទាញ និង ៤) ណែនាំឲ្យមានការលាក់ការណ៍ខ្ពស់ដើម្បីពង្រឹងជិហរ ទោះបីជាអង្គការចាប់បានក៏កុំឆ្លើយ។ ក្រោយពីប្រជុំបានរយៈពេល១ខែ ខ្ញុំបានត្រឡប់មកជួប ស្រែម ម្តងទៀតដើម្បីសួរនាំរឿងទាក់ទងនឹងការអូសទាញកម្លាំង ប៉ុន្តែ ស្រែម ប្រាប់ថាការអូសទាញកម្លាំងមិនទាន់បាន ព្រោះសភាពការណ៍នៅខាងក្នុងមិនទាន់អំណោយផលទេ។ ក្រោយមកនៅក្នុងឆ្នាំ១៩៧៥នេះដដែល ស្រែម បានរាយការណ៍ឲ្យបក្ខពួកខ្ញុំដឹងថា ក្នុងសហករណ៍៦ស្រែហ៊ុយ គាត់បានចាត់តាំងកម្លាំងបាន៤នាក់បន្ថែមគឺឈ្មោះប្រោន, តាន, អាន និង អុល ដែលអ្នកទាំងអស់នោះគឺជាកងឈ្លប។ ស្រែម បានដាក់ភារកិច្ចឲ្យអ្នកទាំងអស់នេះធ្វើសកម្មភាពដោយបំផុសប្រជាជនឲ្យមានទំនាស់ជាមួយអង្គការ និងធ្វើជាអ្នកទាក់ទងផង។

នៅក្នុងឆ្នាំ១៩៧៦ ញូន បាននាំបក្ខពួកខ្ញុំមកជួបឈ្មោះ ម៉ី នៅផ្ទះរបស់គាត់ក្បែរវាលយន្តហោះមណ្ឌលគិរី។ ពេលនោះ ម៉ី បានរាយការណ៍ប្រាប់ ញូន ថា គាត់បានលាក់ ស្រូវ ក្រណាត់ ទុកដើម្បីរំដោះចូលព្រៃ និងផ្តែផ្តាំឲ្យ ញូន ប្រាប់មក ភូខាំ ផង។ ម៉ី ក៏បានប្រាប់ពីសកម្មភាពដែលគាត់បានធ្វើក្នុងចលនាប្រជាជនរហូតដល់មានសភាពការណ៍ប្រឆាំងនឹងអង្គការ និងរាយការណ៍ពីកម្លាំងអប់រំបានចំនួន១០នាក់បន្ថែមទៀត។ ពិភាក្សាគ្នាចប់ ពួកខ្ញុំក៏បានត្រឡប់មករាយការណ៍ឲ្យខាំភួន វិញ។ ពេលនោះគាត់បានសួរបក្ខពួកខ្ញុំថា ធ្វើបានឬមិនបាន យកឬមិនយកសម្ភាររបស់ ម៉ី ដែលបានលាក់ទុកនោះ។ ប៉ុន្តែបក្ខពួកខ្ញុំឲ្យ ខាំភួន ជាអ្នកសម្រេចវិញ។ ខាំភួន បានចាត់តាំងឲ្យបក្ខពួកខ្ញុំទាំង៦នាក់ យកសម្ភារដែល ម៉ី បានលាក់ទុកនោះ រួចគាត់ក៏សរសេរសំបុត្រឲ្យខ្ញុំយកមកឲ្យ ម៉ី។ លុះ ម៉ី មើលរួចហើយ បក្ខពួកខ្ញុំចូលរៀបសម្ភារដែលលាក់ទុកនោះឲ្យមើល។ សម្ភារនោះមានដូចជា កាំភ្លើង២០ដើម មានកាំភ្លើងអាកា សេកាសេកាំរ៉ាប៊ីន និងអែ១៥, គ្រាប់កាំភ្លើង៥កេះតូចៗល្មម និង

ក្រៅពីនេះមានក្រណាត់ អំបិល និងសម្ភារផ្សេងៗទៀត។ ពេលនោះបក្ខពួកខ្ញុំគ្រាន់តែរៀបចំទុកដាក់សិន ព្រោះក្នុងមួយខែបក្ខពួកខ្ញុំអាចដឹកចេញម្តង ឬ២ដង ប៉ុណ្ណោះ។ ពេលរៀបចំរួចហើយ ខ្ញុំត្រឡប់មករាយការណ៍ឲ្យ ខាំភួន វិញ។ រំលងប្រហែល៤ឬ៥ថ្ងៃក្រោយមក ម៉ី ត្រូវអង្គការចាប់ខ្លួន ហើយយោធាចូលមកយកសម្ភារនៅភ្នំក្រោលទាំងអស់។ នៅពេលដែល ខាំភួន ដឹងហើយ គាត់បានណែនាំឲ្យយើងនៅស្ងៀមសិន និងពង្រឹងជំហរលាក់ការណ៍ឲ្យបានជិត ហើយគាត់លែងឲ្យបក្ខពួកខ្ញុំចេញក្រៅហើយ។ ក្រោយមក ខាំភួនបានឲ្យ ញូន សរសេរសំបុត្រមកឲ្យ ច្រឹយ ឲ្យប្រញាប់ដឹកសម្ភារចេញពីឃ្លាំងឲ្យអស់ត្រៀមវាយពេលឆាប់ៗនេះ។ ចំណែកបក្ខពួកខ្ញុំមានគ្នីគ្នាចំនួន១៨នាក់ជាអ្នកជញ្ជូនចេញពីឃ្លាំងមកក្រៅដើម្បីឲ្យ ច្រឹយ ដឹក។ យើងណាត់ជួបគ្នាចម្ងាយពីឃ្លាំងប្រហែល៣គីឡូម៉ែត្រ។ ច្រឹយ មានដរីមួយសម្រាប់ដឹកមកព្រៃចាស់អូរយោលជាមួយមនុស្សមួយចំនួនមានយួន ខ្មែរ និងជនជាតិភាគតិច ហើយភាគច្រើនជាប៉ូលីសទាហានចាស់។ ការដឹកចេញនេះធ្វើនៅពេលយប់ជ្រៅមានសភាពស្ងាត់ គ្មានយោធាទេ។ ច្រឹយ ដឹកចេញក្នុងមួយខែប្រហែល៣ដងតាមសភាពការណ៍ជាក់ស្តែង។ សម្ភារដែលដឹកចេញនោះមាន គ្រាប់ ថ្នាំជក់ ទឹកដោះគោ ស្បែកជើងពុម្ព ខោអាវក្រមា និងអង្រឹង។ ការដឹកសម្ភារចេញនេះធ្វើរហូតដល់ខែមិថុនា ឆ្នាំ១៩៧៧។

នៅដើមឆ្នាំ១៩៧៧ ខាំ និង ញូនបានហៅបក្ខពួកខ្ញុំឲ្យមកប្រជុំនៅរោងបោកស្រូវកណ្តាលស្រែពេលយប់ម៉ោង ៩។ ខ្លឹមសារប្រជុំមានដូចជា ១) ត្រូវលាក់ការណ៍ឲ្យបានល្អពីសម្ភារដឹកចេញ និងសម្ភារនៅក្នុងឃ្លាំង ២) ការដកសម្ភារចេញគឺចង់វាយពីមណ្ឌលគិរីឆាប់ៗ ៣) កន្លែងទុកសម្ភារគឺឲ្យ ច្រឹយ បន្តរកភូមិសាស្ត្រឲ្យស្ងាត់ល្អ និង៤) ណែនាំឲ្យខំដឹកចេញ ប្រមូលកម្លាំងធ្វើសង្គ្រាមឲ្យឈ្នះ។ ថ្ងៃមួយម៉ោងប្រហែល៩យប់ កាស៊ីបានមកប្រមូលបក្ខពួកខ្ញុំពីមន្ទីរក១៦ និងមន្ទីរក១៧ ឲ្យមកចូលរួមប្រជុំនៅខាងក្រោយពេទ្យមន្ទីរក៨០ ដែលមានចម្ងាយប្រហែលកន្លះគីឡូពីមន្ទីរចម្ការបេកអូច្បារ។ ក្នុងការប្រជុំនោះមានជនជាតិវៀតណាមចំនួនប្រហែល៣០នាក់ ដែលជាកងស៊ើបការណ៍មានមេឈ្មោះ ទីដូង,ទីគង និង ថាញ់។ ខ្លឹមសារប្រជុំគឺ កាស៊ី ចង់ឲ្យបក្ខពួកខ្ញុំយល់ដឹងពីផែនការវាយនៅមណ្ឌលគិរី។ កាស៊ី បានលើកឡើងនៅក្នុងការប្រជុំនោះថា ១) ផែនការកម្ទេចមណ្ឌលគិរីដោយសហការណ៍ជាមួយវៀតណាម ហើយកម្លាំងវៀតណាមទាំង៣០នាក់នេះ គឺចូលមកពិនិត្យស្ថានការនៅមណ្ឌលគិរី ២) ឲ្យបក្ខពួកខ្ញុំត្រៀមស្បៀង គ្រាប់ អាវុធ គឺដណ្តើមមណ្ឌលគិរីឲ្យបាន មិនឲ្យបដិវត្តន៍កាន់កាប់រដ្ឋអំណាចទេ ៣) ប្រាប់កម្លាំងដែលចូលមកជួយ ២៥០០នាក់ រួមជាមួយកម្លាំងនៅកោះញែក ៤) សម្ភារគ្រាប់ដែលលាក់ត្រូវរៀបចំចែកគ្នានៅពេលវាយសម្រុក ៥) ណែនាំពីការលាក់ការណ៍ទោះវៀតណាមចូលមកក៏យើងត្រូវមានជំហរដែរ និង ៦) ចាប់ផ្តើមធ្វើសកម្មភាពពីខែកក្កដា ឆ្នាំ១៩៧៧ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧ ហើយបើមិនបានសម្រេចទេត្រូវបញ្ជូនកងទ័ពថែមទៀត។ យើងប្រជុំរហូតដល់ម៉ោង ១២ យប់ទើបបែកគ្នា។ ពេលមកដល់កន្លែងវិញ ផែនការបក្ខពួកខ្ញុំ គឺប្រមូលកម្លាំងដើម្បីត្រៀមជួយធ្វើសកម្មភាពនៅពេលកងទ័ពយួនផ្ទុះអាវុធ។ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧ ផែនការទាំងអស់ត្រូវបែកការណ៍ ហើយអង្គការបានចាប់ កាស៊ី មុនគេ និងចាប់មនុស្សជាបន្តបន្ទាប់មកទៀតនៅខាងមន្ទីរក១៦។ ខែសីហា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនខ្ញុំ មកដាក់នៅភ្នំក្រោលរហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧ ទើបអង្គការបញ្ជូនខ្ញុំមកឃុំឃាំងនៅក្នុងគុកទួលស្លែងនេះ។

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ គ្រិស យ៉េន ហៅសុឃុន ពិតប៉ុណ្ណាងណានោះទេ។





# ចម្លើយរបស់ គឹម លីង ហៅ លន់ ប្រធានរោងចក្រសុរាគារ គីឡូម៉ែត្រលេខ៦

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D0៥៥៥៦

អ៊ុន សុជាទី



រោងចក្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
(ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩)
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងខែមេសាឆ្នាំ១៩៧៦ គឹម លីង ហៅលន់ ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ នៅលីវ ត្រូវបានអង្គការឃាត់ខ្លួន ហើយចាប់បញ្ជូនមកគុកទួលស្លែង។ លន់មានកម្ពស់ ១.៧០ម៉ែត្រ មានមាឌរាងស្តើង សម្បុរសទម្រង់មុខរាងវែង និងមានដំណើរបង់បោយទន់ញាប់ៗ។ លន់ គឺជាប្រធានរោងចក្រសុរាគារគីឡូម៉ែត្រលេខ៦។ លន់ បានរៀបរាប់ពីដំណើររឿងក្បត់ដែលទាក់ទងទៅនឹង ស៊ុនួន ថា៖

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ខ្ញុំបានស្គាល់ឈ្មោះ ស៊ុនួន ដែលកាលនោះ ស៊ុនួន គឺជាប្រធានវរសេនាធំ ៧៣ ប៉ុន្តែខ្ញុំមិនបាននិយាយរកគ្នានោះទេ។ ថ្ងៃមួយក្នុងខែឧសភា វេលាម៉ោង៨យប់ ខ្ញុំបានឃើញ ស៊ុនួន ដឹកស៊ីជាមួយបក្ខពួកដែលមានឈ្មោះ ១) ប៉ុន គឺជាយោធានៅអង្គភាពវរសេនាធំ ២) ឆន ខាងនយោបាយអង្គភាពវរសេនាធំ និងឈ្មោះរឿន គឺនៅខាងភ័ស្តុភារអង្គភាពវរសេនាធំ។ នៅពេលនោះឈ្មោះ ប៉ុន បានបាញ់មិត្តម្នាក់ឈ្មោះ សិ ដែលជាយោធាអង្គភាពវរសេនាតូចស្លាប់។ ភ្លាមនោះ ស៊ុនួនបានបញ្ជាឲ្យបងប្អូនយកសាកសពមិត្ត សិ យកទៅកប់ភ្លាមមួយរំពេច។ ស៊ុនួន បាននិយាយនៅមុខមហាជនថា «យើងមិនដឹងជាធ្វើដូចម្តេចទេ ព្រោះបានជាកើតមានគ្រោះថ្នាក់ទៅហើយនោះ»។ កន្លងផុត ៤ទៅ៥ថ្ងៃ មិត្តនៅក្នុងអង្គភាពរបស់ មិត្តសិ មកសុំមតិពី ស៊ុនួន ដើម្បីចាប់យកមិត្ត ប៉ុន យកទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខ ប៉ុន្តែ ស៊ុនួន បាននិយាយដោះសារថា មិនបាច់យកមិត្ត ប៉ុន ទៅដាក់គុកទេ ចាំគាត់ជាអ្នកណែនាំមិត្ត ប៉ុន និងទុកឲ្យមិត្ត ប៉ុន បម្រើអង្គការទៅមុខបន្តទៀតចុះ។ ស៊ុនួន ថែមទាំងនិយាយទៀតថា យើងទាល់តែងាប់មួយទើបមានបទពិសោធន៍កុំឲ្យថ្ងៃក្រោយលេងកាំភ្លើងទៀត។ ចំពោះហេតុការណ៍ទាំងនេះ ខ្ញុំក្តាប់មិនបានទេ។ ខ្ញុំមិនដឹងថាអ្នកទាំងនោះមានទំនាស់គ្នាពីរឿងអ្វីទេ។ ក្រោយមករឿងនេះក៏ស្ងប់ស្ងាត់បាត់រហូតដល់សព្វថ្ងៃនេះ។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំចាប់ផ្តើមសង្ស័យពី ស៊ុនួន។ ខ្ញុំគិតថា ស៊ុនួន ប្រហែលជាបក្ខពួក

ក្បត់ដែរហើយបានជាគាំទ្រមិត្ត ប៉ុន ឲ្យជៀសផុតពីជាប់គុកបាន។

នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ស៊ីនួន ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាប្រធានឃ្លាំងអង្ករនៅគីឡូម៉ែត្រលេខ៦។

នៅខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំឃើញមិត្ត ប៉ុន ចុះឡើងទៅកន្លែងមិត្ត ស៊ីនួន ញឹកញាប់ណាស់ ប៉ុន្តែខ្ញុំមិនដឹងថាអ្នកទាំងពីរទាក់ទងគ្នាពីរឿងអ្វីនោះទេ។ ថ្ងៃមួយវេលាម៉ោង១១ថ្ងៃត្រង់ ខ្ញុំបានទៅកន្លែងមិត្ត ប៉ុន។ ខ្ញុំឃើញមិត្ត ប៉ុន យកបានស្រា ប៊ីយែរ ស្ករមួយបាវ អង្ករកន្លះបាវ។ ខ្ញុំក៏សួរគាត់ថា «តើមិត្តបានអង្ករ ស្រានេះមកពីណា?» មិត្តប៉ុនឆ្លើយតបមកវិញថា ឪពុកធំឲ្យ។ ឪពុកធំដែលមិត្ត ប៉ុន បាននិយាយនោះគឺសំដៅទៅដល់ ស៊ីនួន។ ខ្ញុំក៏សួរបន្តទៀតថា «តើមិត្តបានមកពីកន្លែងមិត្ត ស៊ីនួន គីឡូម៉ែត្រលេខ៦នោះមែនទេ? តើមិត្តស្និទ្ធគេប៉ុមួយមិត្ត ស៊ីនួន ជាអ្នកឲ្យ?» មិត្តប៉ុន ក៏ឆ្លើយតបមកវិញថា «ឪពុកធំឲ្យដោយមិនបាច់ស្នើទេ»។ បន្ទាប់មកមិត្ត ប៉ុន ក៏ប្រាស់ខ្លួនដេកទៅ។ ខ្ញុំក៏ដើរចេញមកកន្លែងរបស់ខ្ញុំវិញ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំបានទៅសួរសុខទុក្ខមិត្ត ប៉ុន។ មិត្តប៉ុន ក៏បានរំឭករឿងដែលខ្លួនបានបាញ់មិត្ត សិ។ មិត្តប៉ុន និយាយថា «ខ្លួនអញសំណាងហើយ អ្នកខ្លះគេថាយកអញទៅដាក់ឃុំឃាំង អ្នកខ្លះគេថាយកអញទៅបាញ់ចោល តើធ្វើយ៉ាងម៉េចសម្លាប់អញបាន បើឪពុកធំអញការពារជាប់រហូតមកដល់សព្វថ្ងៃនេះ»។ ខ្ញុំក៏សួរទៅមិត្ត ប៉ុន ថា «ហេតុអ្វីបានជាបាញ់មិត្ត សិ?» ។ ប៉ុន្តែមិត្ត ប៉ុន ឆ្លើយតបមកខ្ញុំវិញថា «អាឯងចង់ដឹងអី អញបាញ់ប្រាប់ថាបាញ់ រាល់កែប្រាប់ថារាលកែហើយ។ អានេះ សួរចង់ដឹងយកទៅរាយការណ៍ឲ្យអ្នកណាណឹង។ ឈប់និយាយទៅរឿងកន្លងហួសទៅហើយ»។ ខ្ញុំក៏តបថា «ខ្ញុំសួរគ្រាន់តែចង់ដឹងតែប៉ុណ្ណោះ»។ បន្ទាប់មកមិត្ត ប៉ុន ក៏ឡើងទៅហូបបាយ ហើយក៏ត្រឡប់ទៅធ្វើការវិញ។ ពេលនោះខ្ញុំបានដឹងជាក់ច្បាស់ថា ស៊ីនួន គឺជាមេក្បត់មួយដែរ។

នៅក្នុងខែកញ្ញាឆ្នាំ១៩៧៥ ស៊ីនួន ត្រូវបានអង្គការចាត់តាំងជាប្រធានរោងចក្រសុរាគារគីឡូម៉ែត្រលេខ៦។

នៅខែតុលា ឆ្នាំ១៩៧៥ ស៊ីនួន បានឲ្យស្រាទៅមិត្ត ប៉ុន ចំនួន៣០លីត្រ។

នៅខែមករាឆ្នាំ១៩៧៦ វេលាម៉ោង៧ព្រឹក មិត្ត ប៉ុន បានមកលេងផ្ទះរបស់ខ្ញុំ។ ពេលនោះយើងមានគ្នាតែពីរនាក់ ដូច្នេះមិត្ត ប៉ុន ក៏បាននិយាយមកកាន់ខ្ញុំថា «អញថ្ងៃមុនទៅលេងកន្លែង ស៊ីនួន។ ស៊ីនួន បានជប់លៀងស្ងោរមាន់ទាស៊ីផឹក»។ ខ្ញុំក៏សួរទៅមិត្ត ប៉ុន វិញថា តើជប់លៀងអ្វីខ្លះ? ក្រោយពីមិត្ត ប៉ុន បានរៀបរាប់ពីមុខម្ហូបស៊ីផឹករួចមកក៏បាននិយាយថា «ស៊ីនួន បានឲ្យអញតាមដានមើលមិត្ត ហង់ ដែលជាគណៈប្រេង។ បើមិត្ត ហង់ ឲ្យប្រេងទៅបងប្អូនណា ត្រូវរាយការណ៍ឲ្យគាត់។ គាត់នឹងរាយការណ៍ជូនអង្គការដើម្បីដកមិត្ត ហង់ចេញហើយដំឡើងអញឲ្យឡើងជំនួសងាយស្រួល ស៊ីនួន ជិះម៉ូតូបុឡានមកចាក់សាំង»។ មិត្ត ប៉ុន បានសួរមកខ្ញុំថា តើខ្ញុំដែលឃើញមិត្ត ហង់ យកប្រេងទៅឲ្យបងប្អូនគាត់ទេ? ខ្ញុំឆ្លើយតបថាមិនដែលឃើញទេ ឃើញតែមិត្ត ហង់ ធ្វើការងារជូនអង្គការ។ មិត្តប៉ុនក៏បានតបថា «ឥឡូវអញចាត់តាំងឲ្យមិត្ត លន់ ឯងជួយតាមដានមើល បើឃើញមិត្តហង់យកប្រេងទៅឲ្យបងប្អូនណាមួយត្រូវរាយការណ៍មកឲ្យអញ»។ ម៉ោងប្រហែល៧កន្លះព្រឹក មិត្ត ប៉ុន ក៏ចុះចេញទៅ ហើយខ្ញុំក៏ត្រឡប់ទៅធ្វើការវិញ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ មិត្តប៉ុន ចុះឡើងៗទៅកន្លែងស៊ីនួនញឹកញាប់ណាស់។ ទៅម្តងៗបានស្រាយកមកផឹក។

នៅក្នុងខែមេសា ឆ្នាំ១៩៧៦ អង្គការបានដកមិត្ត ប៉ុន ដោយខ្ញុំមិនដឹងថាមិត្តប៉ុនទៅណាទេ។ ក្រោយមកខ្ញុំត្រូវបានអង្គការឃាត់ខ្លួន និងបញ្ជូនមកគុកទួលស្លែង ។

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ គីម លីង ហៅលន់ ពិតប៉ុយ៉ាងណានោះទេ។





# ញឹក វុធ បម្រុងរត់ទៅសៀមដើម្បីគេចខ្លួន

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00265

ជាវ៉ារដ្ឋ មេត្តា



ប្រជាជនកំពុងរែកដីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ខ្ញុំឈ្មោះ ញឹក វុធ ភេទប្រុស អាយុ២៨ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើតនៅ ភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ញឹក យិន និងម្តាយឈ្មោះ ជូរ កែវ មានមុខរបរជាអ្នកធ្វើចម្ការ។ ខ្ញុំមានបងប្អូនប្រុសបង្កើតទាំងអស់ចំនួន៤នាក់។ នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំបានចូលរៀននៅលាសាបឋមសិក្សា បំពេញវិជ្ជានៅស្វាយពល ខេត្តព្រៃវែង។ នៅខែមិថុនា ឆ្នាំ១៩៦៨ ខ្ញុំបានរៀនដល់ថ្នាក់ទី៧ ហើយមកដល់ខែតុលា ឆ្នាំដដែល ខ្ញុំក៏បានចាកចេញពីស្រុកកំណើតមករៀនបន្តនៅភ្នំពេញ ដោយស្នាក់នៅក្នុងវត្តចក។ ខ្ញុំចូលរៀននៅសាលាវឌ្ឍនៈវិជ្ជាដោយមាននាយកសាលាឈ្មោះ អី ផ្លូនហូត។ មួយឆ្នាំក្រោយមក គឺនៅខែតុលា ឆ្នាំ១៩៦៩ ខ្ញុំបានចូលជាសមាជិកសមាគមសិស្ស-និស្សិតដែលមានប្រធានឈ្មោះ អី ផ្លូនហូត គឺជាអ្នកទទួលស្គាល់។

ពេលខ្ញុំរៀនដល់ថ្នាក់ទី៣ ខ្ញុំក៏បានប្តូរមករៀននៅសាលា ១៨ មីនា ដោយមាននាយកសាលាឈ្មោះ គីថូ វិញ។ រហូតដល់ខែសីហា ឆ្នាំ១៩៧៤ ខ្ញុំបានបញ្ចប់ការសិក្សា នៅសាលា១៨ មីនា។ ក្រោយមកខ្ញុំបានចូលរៀននៅសាលាគរុកោសល្យ ក្រុងភ្នំពេញ ដោយមាននាយកសាលាឈ្មោះ លន់ ស្រេង។ នៅពេលកំពុងសិក្សា ខ្ញុំបានចូលជាសមាគមគ្រូបង្រៀនដែលមានលោកនាយក លន់ ស្រេង គឺជាប្រធាន។

រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវអង្គការបដិវត្តន៍ជម្លៀសចេញឲ្យទៅនៅ ភូមិធាយ ឃុំវត្តអង្គ ស្រុកទូកមាស (បច្ចុប្បន្នស្ថិតស្រុកបន្ទាយមាស) ខេត្តកំពត។ ខ្ញុំទទួលតួនាទីជាសមាជិកសហករណ៍។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានចាត់តាំងខ្ញុំ និងសមាជិកសហករណ៍ផ្សេងទៀតទៅធ្វើស្រែនៅឃុំបន្ទាយមាស ជិតព្រំដែនវៀតណាមមួយរយៈទើបត្រឡប់មកភូមិវិញ។ បន្ទាប់មកអង្គការបានបែងចែកសមាជិកមួយចំនួនឲ្យទៅធ្វើស្រែនៅការដ្ឋានស្រែព្រៃ ស្ថិតនៅក្នុងឃុំវត្តអង្គ ចំណែកសមាជិកចំនួនទៀត រួមទាំងខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅធ្វើស្រែនៅជិតភូមិដែលខ្ញុំរស់នៅ។ នៅវេលាម៉ោង៧ព្រឹក ពេលទៅដល់ការដ្ឋានធ្វើការ ឈ្មោះ ខុនបានមកខ្សឹបប្រាប់ខ្ញុំ និងឈ្មោះ ស៊ីន ថាប្អូនឯងទាំងពីរនាក់ និងខ្ញុំសុទ្ធតែមានឈ្មោះត្រូវអង្គការយកទៅរៀនសូត្រហើយ ព្រោះអីកាលល្ងាចមិញមានពូម្នាក់ឈ្មោះ សែន ក៏ត្រូវអង្គការយកទៅរៀនសូត្របាត់មិនឃើញវិលត្រឡប់វិញដែរ។ ខ្ញុំមិនដឹងធ្វើយ៉ាងម៉េចក៏និយាយប្រាប់គាត់ថា បើអង្គការចង់ឲ្យខ្ញុំរៀនសូត្រស្រេចតែអង្គការទៅចុះ។ ខុន បាននិយាយបន្តថា ប្អូនឯងទាំងពីរនាក់រត់ទៅក្នុងព្រៃទៅទើបរស់ ចំណែកខ្ញុំមានកូនប្រពន្ធខ្ញុំក៏រត់ដែរ។ ខ្ញុំនិងស៊ីនបានតបទៅឈ្មោះ ខុន វិញថា ខ្ញុំមិនដឹងរត់ទៅណាទេបង ខ្ញុំសុខចិត្តធ្វើការងារក្នុងសហករណ៍ហើយ។ បងខុន នៅតែជំរុញឲ្យយើងរត់ម្តងហើយម្តងទៀត ហើយបានណាត់គ្នាថា ប្រសិនបើយើងរត់ គឺរត់ទៅជាមួយគាត់នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៧។ រំលងបានមួយថ្ងៃពេលយើងកំពុងតែរែកដី ខ្ញុំនិងឈ្មោះ ស៊ីន ក៏ជួបជាមួយឈ្មោះ ប្រេះ ម៉ាត់ ដែលកំពុងតែឃ្វាលក្របីនៅជិតការដ្ឋានខ្ញុំ។ ខ្ញុំមើលទៅទឹកមុខគាត់ដូចជាអស់សង្ឃឹមអំពីរឿងអ្វីមួយ។ ម៉ាត់ បានដើរមករកខ្ញុំ ហើយនិយាយថា យើងប្រាកដជាមិនរស់ទេ បើនៅប្រាកដជាអង្គការចាប់។ បងម៉ាត់ បាននិយាយបន្តទៀតថា បើតាមសម្តី តានី សមាជិកសហករណ៍ភូមិធាយ ចង់ឲ្យយើងរត់ទៅទិសខាងលិច ប្រហែលជាមានសង្ឃឹមរស់ច្រើន ព្រោះមានផ្លែឈើហូបតាមផ្លូវ។

លុះដល់រសៀល ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៧ ពេលម៉ាត់ មកឃ្វាក្របីនៅជិតកន្លែងរបស់ខ្ញុំ ខ្ញុំបានសួរគាត់ថា យើងលួចចេញទៅពេលណា? ម៉ាត់ ប្រាប់ថាយើងចេញទៅនៅពេលល្ងាចនេះ ដោយមានឈ្មោះ កែម ស្គាល់ផ្លូវអ្នកដឹកនាំទៅ។ នៅម៉ោងជិតប្រាំពីរយប់ ខ្ញុំបានចេញពីផ្ទះដើរតម្រង់ទៅកន្លែងណាត់ជួប ក៏ឃើញឈ្មោះ ម៉ាត់ និង កែម កំពុងអង្គុយរង់ចាំខ្ញុំ លុះបានបន្តិចក៏ឃើញឈ្មោះ ស៊ីន បានដើរមកដល់ដែរ។ កែម បានប្រាប់ថា ត្រូវលាក់ការណ៍ និងមើលសញ្ញាតាមដៃរបស់គាត់ប្រាប់ឲ្យដើរលឿនយឺត ក្រាបបុ ពួន។ និយាយហើយបង កែម ដើរទៅមុនគេ ខ្ញុំដើរនៅខាងក្រោយគេ។ យើងបានដើរឆ្លងកាត់ព្រៃ កាត់វាល ជួនកាលឆ្លងកាត់ភូមិអ្នកស្រុក ប៉ុន្តែសំណាងល្អបាន កែម ស្គាល់ផ្លូវច្បាស់។

ក្រោយពីបានធ្វើដំណើរដល់ម៉ោងប្រហែលជា ៤ទៀបភ្លឺក៏ទៅដល់ជើងភ្នំវល្លិ៍ និងបានសម្រាកនៅទីនោះ។ លុះព្រឹកឡើង យើងបានបន្តដំណើរទៅដល់ភ្នំមួយទៀត និងបានឈប់សម្រាកជុំគ្នា។ កែម និយាយថា នៅពេលដល់សៀម ខ្ញុំនឹងចិញ្ចឹមអ្នកទាំងបី ព្រោះខ្ញុំមានជនាញម៉ាស៊ីនត្រជាក់។ យើងបានបន្តដំណើរនៅវេលាម៉ោង៥កន្លះល្ងាចថ្ងៃទី២ ទៅដល់ផ្ទះអ្នកស្រុកដោយឆ្លងកាត់ផ្លូវជាតិលេខ៣។ បន្ទាប់មកទៅដេកនៅជើងភ្នំកោះចន្ទុះ។

លុះវេលាម៉ោងប្រហែលជា ៨ព្រឹក ថ្ងៃទី ៣ យើងបានធ្វើដំណើរពីកោះចន្ទុះ សំដៅទៅទិសខាងលិចបំណងទៅសៀម។ នៅពេលធ្វើដំណើរ យើងបានវាងចម្ការប្រជាជនជាច្រើនកន្លែង។ កែម បានដើរនាំមុខ ហើយក៏ជួបឆ្កែរបស់អ្នកស្រុកព្រួសនៅក្បែរផ្លូវ ដូច្នេះគាត់បានធ្វើសញ្ញាឲ្យខ្ញុំពួនសិន។ បងកែម បានដើរបន្តទៅមុខបាត់មិនឃើញត្រឡប់មកវិញ។ ឃើញដូច្នេះយើងទាំង៣នាក់ ក៏បានដើរទៅតាមរកគាត់អស់មួយសន្ទុះធំ ប៉ុន្តែរកមិនឃើញ ហើយក៏មិនដឹងជាគាត់គេចខ្លួនបុយ៉ាងណាដែរ។ ក្រោយមក យើងបានបន្តដំណើរទៅទិសខាងលិចទៀត។ យើងដើរវង្វេងផ្លូវ និងដេកក្នុងព្រៃភ្នំរហូតដល់ថ្ងៃទី ១៦ ខែសីហា ឆ្នាំ១៩៧៧ ទើបយើងមកដល់ផ្លូវជាតិលេខ ៤។ យើងបានមកជួបផ្ទះរបស់អង្គភាពកងទ័ព ហើយកងទ័ពក៏បានចាប់ខ្លួនយើងទុកនៅទីនោះមួយយប់មួយថ្ងៃ។ ថ្ងៃបន្ទាប់ខាងកងទ័ពក៏បានបញ្ជូន យើងទាំងបីនាក់មកទីកន្លែងនេះតែម្តង។

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ញឹក រុធ ពិតបុយ៉ាងណានោះទេ។





# នាង សាង ត្រូវបានចាប់ខ្លួនដោយសារអង្គការចោទថាក្បត់

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០០០៩១

ដារ៉ារដ្ឋ មេត្តា



កម្មាភិបាលខ្មែរក្រហមនៅតាមមន្ទីរ និងអង្គភាព ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) កំពុងធ្វើពលកម្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នាង សាង ហៅ ផង់ ភេទប្រុស អាយុ ៤២ ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើត នៅភូមិត្រពាំងសោម ឃុំជង្រុង ស្រុកជ្រុក ខេត្តរោងដំរី កម្ពុជាក្រោម (សព្វថ្ងៃប្រទេសវៀតណាម)។ ខ្ញុំមានឪពុកឈ្មោះ នាង (ស្លាប់) និងម្តាយឈ្មោះ ហម (ស្លាប់)។ ខ្ញុំមានបងប្អូនចំនួន ៣ នាក់ ប្រុសទាំងអស់។ គ្រួសាររបស់ខ្ញុំមានមុខរបរជាអ្នកធ្វើស្រែចម្ការ។ នៅពេលខ្ញុំធំដឹងក្តី ខ្ញុំបានដើរបោចវល្លិ៍ និងដងជ័រ សម្រាប់ចិញ្ចឹមជីវិត។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ឆា។ យើងមានកូនពីរនាក់គឺប្រុសមួយ និងស្រីមួយ។

នៅក្នុងឆ្នាំ១៩៦០ ខ្ញុំបានចូលបដិវត្តន៍ជាមួយវៀតណាម ដោយខ្ញុំនៅមន្ទីរនីរសារ និងទទួលភ្ញៀវ។ ខ្ញុំបានទទួលការអប់រំពីឈ្មោះ សឹង មានតួនាទីជាប្រធានមន្ទីរ។ គាត់បានអប់រំខ្ញុំឲ្យចេះតស៊ូ និងចេះរំដោះខ្លួនឲ្យរួចផុតពីការជិះជាន់របស់ចក្រពត្តិ។ នៅក្នុងឆ្នាំ១៩៦២ សឹង បានចាត់តាំងខ្ញុំឲ្យបង្កប់ខ្លួននៅក្នុងជួរណសិរ្សពិសេស គឺបង្កប់ខ្លួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ការបង្កប់ខ្លួនពេលនោះ សឹង បានកំណត់ថាឲ្យខ្ញុំទៅទាក់ទងជាមួយឈ្មោះ យ៉ា (គណៈមជ្ឈិមបក្សពលករ) ដែលធ្វើការនៅមន្ទីរព្រោះ យ៉ា ជាមនុស្សរបស់អង្គភាពយើង។ ទិសដៅរបស់អង្គការមិនប្រញាប់នោះទេ សំខាន់គឺយូរអង្វែងកុំឲ្យបែកការណ៍ ហើយមានការអ្វីត្រូវធ្វើការពិភាក្សាជាមួយ យ៉ា និងរួមកម្លាំងគ្នាវាយ លន់ លន់វាយចក្រពត្តិអាមេរិក ហើយត្រូវពង្រីកកម្លាំងជាបន្តបន្ទាប់។

នៅខែមីនា ឆ្នាំ១៩៧៤ បងហង់ (លេខាតំបន់ព្រះវិហារ និង ជាគណៈមជ្ឈិមបក្សពលករ) បានហៅគណៈស្រុកទាំងអស់, ក្រសួង និងមន្ទីរមួយចំនួនទៅប្រជុំនៅស្រុករវៀង។ ក្នុងនោះមានមេដឹកនាំផ្នែក១-២ និង ផ្នែក ក-១ ដែរ។ ពេលនោះ ខ្ញុំបានស្គាល់មនុស្សមួយចំនួនដូចជា៖ បងហង់, មួន (គណៈស្រុករវៀង) និង យ៉ា។ នៅពេលប្រជុំ បងហង់ គឺជាតំណាងបក្សកុម្មុយនីស្តឥណ្ឌូចិន និងគណៈបក្សមជ្ឈិមបក្សពលករកម្ពុជា។ ការប្រជុំនេះជាកិច្ចដំណើរការ អនុវត្តភារកិច្ចថ្មី គឺសម្រេចបង្រួបបង្រួម សហព័ន្ធឥណ្ឌូចិន ឲ្យបានក្នុងពេលដណ្តើមយកជ័យជម្នះពីបក្សកុម្មុយនីស្តកម្ពុជា។ បងហង់ បានបញ្ជាក់សេចក្តីរាយការណ៍ គឺសង្កត់ធ្ងន់ទៅលើបញ្ហាកម្លាំង និងសកម្មភាពថ្មីនៃដំណើរបក្សពលករកម្ពុជា។ នៅក្នុងឆ្នាំ ១៩៧៤ នេះបក្សទទួលបានជ័យជម្នះលើបក្សកុម្មុយនីស្តកម្ពុជា ជាបន្តបន្តបន្ទាប់ ប៉ុន្តែត្រូវរក្សាការសម្ងាត់មិនឲ្យបែកការណ៍នោះទេ។ នៅតំបន់ព្រះវិហារនេះភាគច្រើនជាកម្លាំងរបស់យើង ឯភាគតិចជាកម្លាំងរបស់ខ្មាំងគឺ ម៉ាន់ (លេខាតំបន់ព្រះវិហារ មុនឆ្នាំ១៩៧៥) ហេតុនេះត្រូវកម្ទេចម៉ាន់ដើម្បីយកជ័យជម្នះ។ បងហង់បានប្រគល់ផែនការនេះមកឲ្យខ្ញុំ ក្នុងការកម្ទេច ម៉ាន់ ព្រោះខ្ញុំនៅជិតម៉ាន់ស្រាប់។ ក្រោយពីប្រជុំ ខ្ញុំបានអនុវត្តផែនការដោយបាននាំកម្លាំងម្នាក់។ បងហង់ បានសរសេរសំបុត្រមួយផ្ញើមកឲ្យខ្ញុំហៅឈ្មោះ គូ មកជួបនៅស្រុកជ័យសែន។ យើងបានចាត់តាំង គូ ដោយគិតថា ងាយស្រួលបញ្ចុះ ព្រោះ គូ បានខូចសីលធម៌ជាមួយនារីម្នាក់ ដើម្បីការពារខ្លួន គូ ប្រាកដជាធ្វើ។ ម្យ៉ាងទៀត គូ គឺជាអតីតនីរសាររបស់ម៉ាន់ ពីមុន។ នៅខែតុលា ឆ្នាំ១៩៧៤ ខ្ញុំបានទៅជួបបងហង់ នៅស្រុករវៀង។ ខ្ញុំក៏បានរាយការណ៍ពីការកសាងកម្លាំងប្រាប់គាត់ ហើយគាត់បានប្រាប់ខ្ញុំថាបានឲ្យ គូ ទៅសម្លាប់ ម៉ាន់ បានសម្រេចហើយ។ ដូច្នេះតំបន់ព្រះវិហារមានតែកម្លាំងយើងប៉ុណ្ណោះ។

នៅក្នុងឆ្នាំ១៩៧៥ ក្រោយពេលរំដោះបានទូទាំងប្រទេស ក៏មានការប្រជុំមួយបានរៀបចំឡើងនៅតំបន់ព្រះវិហារ ដោយមានការចូលរួមពីគ្រប់គណៈស្រុក និងក្រសួងមន្ទីរមួយចំនួន។ អ្នកចូលរួមនោះមាន បងហង់, សេត, ម៉ាន់, យឿន (គណៈស្រុកថាឡាបរិវ៉ាត់), មួយ, សុត (លេខាតំបន់សៀមរាប), សុិត, ភាព (គណៈស្រុកត្បែង), សុិន, ថង, យ៉ាត់ (គណៈស្រុកជាំក្សាន្ត), ធឿន (គណៈស្រុកជ័ងទង់), យ៉ា (ប្រធានមន្ទីរតំបន់), ពុំ (ប្រធានចម្ការកៅស៊ូតំបន់), ហ្វា (ពាណិជ្ជកម្មតំបន់), អាន់ (វប្បធម៌តំបន់), ប៉ន (ពាណិជ្ជកម្មតំបន់), កែម, ជា, ប៊ុន, មី, ធិន, ចាន់, សុន (ប្រធានសង្គមកិច្ចតំបន់), យឿន, ពេញ និងនៅមួយចំនួនទៀត ដែលខ្ញុំមិនចាំឈ្មោះអស់។

នៅក្នុងការប្រជុំបក្សកុម្មុយនីស្តកម្ពុជាត្រូវរួបរួមជាមួយឥណ្ឌូចិន ដោយមាន បងយ៉ា គឺជាគណៈមជ្ឈិមបក្សពលករឥណ្ឌូចិន, នៅភូមិភាគឧត្តរមាន បងធុច, បងសុត នៅសៀមរាប ដែលប្រឆាំងជាមួយបក្សកុម្មុយនីស្តកម្ពុជា និងកម្លាំងខាងក្រៅមាន ឡាវ យួន និង សៀម។ បងហង់ បានលើកផែនការថ្មីមួយទៀត គឺត្រូវប្រមូលអ្នកដែលជាប់និន្នាការចាស់ទាំងអស់ ជាពិសេស គឺរដ្ឋការ ទាហាន ប៉ូលីស ដើម្បីឲ្យទៅរស់នៅក្នុងព្រៃស្អាក (ប-៣១) និងយកកម្លាំងពី ក-៥១ ទាំងអស់ និងយកកម្លាំងពីក្រសួងមួយចំនួន។ ចំណែកអ្នកដែលត្រូវទទួលខុសត្រូវលើ ៣-១ មានចំនួន៤នាក់ គឺខ្ញុំ, សេត (ប្រធាន ប-៣១), ម៉ាន់ (អនុប្រធាន ប-៣១), ភារក្ស (សមាជិក ប-៣១) ដោយធ្វើយ៉ាងណា ត្រូវលាក់ការណ៍ឲ្យជិតកុំឲ្យបង។ ថ្នាក់លើដឹង។





នៅក្នុងឆ្នាំ១៩៧៦ បងហង់ បានឲ្យខ្ញុំទទួលខុសត្រូវតំបន់សន្តិសុខ។ នៅពេលនោះសន្តិសុខតំបន់កាន់តែល្អប្រសើរ ព្រោះមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាឲ្យពួកខ្ញុំបង្កើតនូវសន្តិសុខមួយដើម្បីវាយខ្មាំង គឺយើងយកភារកិច្ចស្របច្បាប់នេះទៅអនុវត្ត ហើយឆ្លៀតអប់រំសមាជិកឲ្យចូលបក្សពលករ។ នៅពេលខ្ញុំមកធ្វើការនៅសន្តិសុខ ខ្ញុំបានអនុវត្តសកម្មភាពបំភ្លើសមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា ដោយបានកម្ទេចឈ្មោះ វង់, ម៉ៅ, សុិត, វុទ្ធី និង ម៉ែន ដែលបានធ្វើឲ្យបែកការណ៍។ ចំណែកប្រជាជនវិញខ្ញុំបានធ្វើសកម្មភាពដូចជាកម្ទេចចោលអស់ ១៥០ នាក់ គឺជាប្រជាជនដែលបានស្មោះត្រង់ជាមួយអង្គការបដិវត្តន៍។ នៅក្នុងឆ្នាំ១៩៧៦ អង្គការចាប់បានបក្ខពួករបស់ខ្ញុំមួយចំនួន ប៉ុន្តែពួកយើងមិនទាន់អស់សង្ឃឹមទេ ព្រោះនៅមានកម្លាំងឥណ្ឌូចិនជួយ ដូចជា សៀម, ឡាវ, យួន ហើយសព្វថ្ងៃនេះកម្លាំងយើងនៅទិសខាងកើត ដូចជា យួន កំពុងវាយនៅតាមព្រំដែនគោក និងទឹកជាបណ្តើរៗ។ ដូច្នេះកម្លាំងខាងក្នុងត្រូវត្រៀមលក្ខណៈ ដើម្បីរួមកម្លាំងគ្នាវាយបក្សកុម្មុយនីស្តកម្ពុជា។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ មានការប្រជុំម្តងទៀតនៅមន្ទីរទំលាប់ បងហង់ បានហៅគណៈក្រសួង មន្ទីរទាំងអស់មកប្រជុំលើកលែងតែគណៈស្រុក។ បងហង់ បានលើកឡើងពីសភាពការណ៍ទូទាំងប្រទេសកម្ពុជាសព្វថ្ងៃមានការប្រែប្រួលខ្លាំង។ ដូចជាបងៗមួយចំនួនត្រូវបក្សកុម្មុយនីស្តកម្ពុជាចាប់ខ្លួន ដូចជា យ៉ា, ស្រេង, ធុច, សុត និងបក្ខពួកនៅក្រោមៗមួយចំនួនក៏ត្រូវអង្គការចាប់ដែរ។

ដូច្នេះនៅសល់តែតំបន់ព្រះវិហារ ដែលមិនទាន់បែកការណ៍ យើងត្រូវបន្តតស៊ូប្រឆាំង និងបក្សកុម្មុយនីស្តកម្ពុជា ដើម្បីដណ្តើមយកជ័យជម្នះលើបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨។ បន្ទាប់ពីប្រជុំរួច ខ្ញុំបានធ្វើសកម្មភាពអប់រំបាន៤នាក់ រួមមាន៖ ថេក, ឆាត, កុត និង ប៉ុន។ បន្ទាប់មកបានបញ្ចូលអ្នកទាំង៤នេះទៅក្នុងបក្សពលករ។

នៅឆ្នាំ១៩៧៨នេះ ទោះបីជាអង្គការចាប់បងៗមួយចំនួន ប៉ុន្តែនៅខេត្តព្រះវិហារមិនទាន់បែកការណ៍ទេ ព្រោះយើងបានធ្វើសកម្មភាពស្របច្បាប់។ យើងត្រូវត្រៀមលក្ខណៈពិសេស ស្រូវ អង្ករ អាវុធ នៅក្នុង ប-៣១ ដែលជាកន្លែងមូលដ្ឋានអាចក្លាយជាបង្អែករបស់យើងបាន។ នៅឆ្នាំ១៩៧៨ មានការផ្ទុះអាវុធជាបណ្តើរៗនៅតាមព្រំដែន។ កម្លាំងយោធាខាងក្នុងខេត្តព្រះវិហារបានចាប់ផ្តើមរៀបចំអាវុធ និងកម្លាំង។ បន្ទាប់ពីប្រជុំរួច ខ្ញុំជឿជាក់ប្រាកដថា អាចយកឈ្នះបក្សកុម្មុយនីស្តកម្ពុជា។ ក្រោយពីប្រជុំបានមួយរយៈ អង្គការបានចាប់ បងហង់ ចំណែករូបខ្ញុំមិនទាន់ហ៊ានធ្វើសកម្មភាពទេ គឺរង់ចាំមើលសភាពការណ៍ទៅថ្ងៃមុខសិន។ ខ្ញុំបានសម្ងំលាក់ខ្លួនជាមួយបដិវត្តន៍លុះដល់រឿងនេះបែកការណ៍ ទើបអង្គការបានចាប់ខ្ញុំមកដាក់នៅមន្ទីរឃុំឃាំងតែម្តង។

កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ នាង សាង ពិតប្រាកដយ៉ាងណានោះទេ។

# ដំណើរស្វែងរកឪពុកដែលជាជនភៀសខ្លួនជនជាតិខ្មែរ របស់ អាវីន វេនីហ្សូអេឡា

អ៊ុន សុជាទី



អាវីន វេនីហ្សូអេ ឡា
(អាវីន វេនីហ្សូអេ ឡា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អាវីន វេនីហ្សូអេ ឡា មានអាយុ៣៦ឆ្នាំ សព្វថ្ងៃរស់នៅក្នុងទីក្រុងម៉ានីឡានៃប្រទេសហ្វីលីពីន។ ម្តាយរបស់ខ្ញុំឈ្មោះ អាមេនី វេនីហ្សូអេ ឡា ដែលសព្វថ្ងៃនេះមានអាយុ ៥៨ឆ្នាំ រស់នៅកោះប៊ីរី ភាគខាងជើងនៃប្រទេសហ្វីលីពីន។ ខ្ញុំកំពុងតែស្វែងរកឪពុករបស់ខ្ញុំ ឈ្មោះ ខាង ភី គឺជាអតីតជនភៀសខ្លួន ដែលជាជនជាតិខ្មែរមកពីប្រទេសកម្ពុជា។

រវាងឆ្នាំ១៩៧៥ ដល់១៩៧៩ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងវិបត្តិនយោបាយមួយយ៉ាងធ្ងន់ធ្ងរក្រោមការដឹកនាំរបស់ក្រុមកុម្មុយនីស្តមួយក្រុមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម។ របបខ្មែរក្រហម បានផ្តល់ឲ្យនូវមេរៀនជីវិតមួយដ៏សែនជូរចត់ដល់ប្រជជនខ្មែរគ្រប់រូប រួមមាន ការធ្វើទារុណកម្មទាំងផ្លូវកាយ និងផ្លូវចិត្ត ការកាប់សម្លាប់យ៉ាងសាហាវឃោរឃៅ និងការពង្រាត់បង្រាសសមាជិកក្រុមគ្រួសារបែកចេញពីគ្នា។ រហូតមកដល់ចុងឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពវៀតណាមបានវាយចូលមកប្រទេសកម្ពុជាប្រជាជនកម្ពុជា អតីតយោធា និងកម្មាភិបាលខ្មែរក្រហម បានរត់គេចខ្លួនទៅកាន់ព្រំដែនថៃ និងរស់នៅក្នុងជំរំនៅទីនោះ។ ដោយមូលហេតុនៃការមិនទុកចិត្ត និងភ័យខ្លាចក្រែងមានសង្គ្រាមកើតឡើងនៅក្នុងប្រទេសកម្ពុជាម្តងទៀត ប្រជាជនខ្មែរទាំងនោះ បានរិះរកមធ្យោបាយបន្តរត់ភៀសខ្លួនទៅរស់នៅក្នុងប្រទេសទីបីដូចជា ប្រទេសកាណាដា នូវវែស អូស្ត្រាលី បារាំង និងអាមេរិកជាដើម។ មុនពេលចាកចេញទៅរស់នៅក្នុងប្រទេសទាំងនោះ ប្រជាជនខ្មែរ តម្រូវឲ្យមករស់នៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺនជនភៀសខ្លួន ដែលស្ថិតនៅទីក្រុងម៉ូរ៉ុង ក្នុងខេត្តបាតាអាន នៃប្រទេសហ្វីលីពីនជាបណ្តោះអាសន្នសិន។ ប្រជាជនខ្មែរ បានរត់ភៀសខ្លួនទៅរស់នៅលើទឹកដីនៃប្រទេសហ្វីលីពីនចំនួនប្រមាណ១០ភាគរយបើប្រៀបធៀបទៅនឹងជនភៀសខ្លួនមកពីប្រទេសឥណ្ឌូចិនសរុបប្រមាណ៤០០.០០០នាក់។

ឪពុករបស់ខ្ញុំ គឺជាជនជាតិខ្មែរម្នាក់ក្នុងចំណោមជនជាតិខ្មែរដទៃទៀត ដែលបានរត់ភៀសខ្លួនមកកាន់ប្រទេស





ហ្វីលីពីន និងមករស់នៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺនជនភៀសខ្លួននៅទីក្រុងម៉ូរ៉ុង ក្នុងខេត្តបាតាអាននៃប្រទេសហ្វីលីពីន។ ម្តាយខ្ញុំបានប្រាប់ខ្ញុំថា នៅក្នុងអំឡុងឆ្នាំ១៩៨៥ គាត់បានជួបឪពុករបស់ខ្ញុំនៅក្នុងជំរំ។ នៅពេលរស់នៅក្នុងជំរំ ឪពុករបស់ខ្ញុំ គឺជាជំនួយការគ្រូបង្រៀនភាសាអង់គ្លេស រីឯម្តាយខ្ញុំវិញ គឺជាអ្នកធ្វើការនៅក្នុងកងទ័ពសង្គ្រោះ។ ឪពុករបស់ខ្ញុំ គឺជាជំនួយការរបស់គ្រូភាសាអង់គ្លេសម្នាក់ឈ្មោះអាមែននៀ។ គាត់ក៏បានជួយបកប្រែភាសាអង់គ្លេសដល់សិស្សដែលមិនយល់ពីអ្វីដែលគ្រូបាននិយាយ។

ក្រោយមកនៅក្នុងឆ្នាំ ១៩៨៥ ដដែល ម្តាយរបស់ខ្ញុំក៏បានចាកចេញពីខេត្ត បាតាអាន ត្រឡប់ទៅភូមិកំណើតរបស់គាត់វិញនៅក្នុងទីក្រុងតាក្លូ បានដែលពេលនោះគាត់កំពុងតែមានផ្ទៃពោះកំណើតខ្ញុំ។ គាត់បានចាកចេញពីជំរំ ដោយសាររដ្ឋាភិបាលមិនអនុញ្ញាតឲ្យជនភៀសខ្លួន និងជនជាតិហ្វីលីពីនមានទំនាក់ទំនងស្នេហាជាមួយគ្នាឡើយ។ ឪពុករបស់ខ្ញុំក៏បានដឹងអំពីរឿងនេះដែរហើយក៏បានដឹងថា ម្តាយរបស់ខ្ញុំនឹងចាកចេញទៅស្រុកកំណើតវិញ។ ម្តាយខ្ញុំក៏បានប្រាប់ខ្ញុំផងដែរថា មុនពេលដែលឪពុកខ្ញុំហៀបនឹងចាកចេញពីប្រទេសហ្វីលីពីន គាត់បានសរសេរសំបុត្រមួយប្រាប់ដល់ម្តាយរបស់ខ្ញុំថា គាត់នឹងចាកចេញពីប្រទេសហ្វីលីពីនទៅកាន់ទីក្រុងកាន់សាស នៃសហរដ្ឋអាមេរិក ឬ ប្រទេសបារាំង។ ក្រោយមកគាត់ទាំងពីរនាក់បានបែកគ្នាដោយគ្មានទំនាក់ទំនងរហូតដល់សព្វថ្ងៃនេះ។ អ្វីដែលគួរឲ្យសោកស្តាយជាទីបំផុតនោះគឺ នៅពេលដែលព្យុះបានប៉ះទង្គិចទីក្រុងតាក្លូបានដែលខ្ញុំធ្លាប់បានរស់នៅ។ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅក្នុងប្រទេសហ្វីលីពីន មានព្យុះមួយឈ្មោះ យូឡាន់ដា បានបំផ្លិចបំផ្លាញទីក្រុង តាក្លូបាន យ៉ាងធ្ងន់ធ្ងរ។ ព្យុះនោះបានកម្ទេចហេដ្ឋារចនាសម្ព័ន្ធ និងសម្លាប់មនុស្សអស់ជាច្រើននាក់។ សម្រាប់គ្រួសារខ្ញុំ យើងបានបាត់បង់សំបុត្រ និងរូបថតរបស់ឪពុកខ្ញុំ ដែលត្រូវទឹក និងព្យុះបោកបក់នាំយកទៅបាត់គ្មានសេសសល់អ្វីឡើយ។ ម្តាយរបស់ខ្ញុំបានប្រាប់ថា រូបថត និងសំបុត្រខ្លះទៀតរបស់ឪពុកខ្ញុំ ដែលបានផ្តល់ឲ្យទៅ អាមែននៀ ក៏ត្រូវបានចោរលួច



អាវីន វេនីហ្សូអេ ឡា និងម្តាយ
(អាវីន វេនីហ្សូអេ ឡា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលដែល អាមែននៀ ដាក់រូបថត និងសំបុត្រនោះនៅក្នុងកាបូបរបស់គាត់ពេលដែលគាត់ធ្វើដំណើរតាមកប៉ាល់មកកាន់ទីក្រុងតាក្លូបាន។

តាំងពីខ្ញុំកើតមក ខ្ញុំមិនដែលឃើញមុខ ឬសូម្បីតែរូបថតរបស់ឪពុកខ្ញុំឡើយ។ ម្តាយមីង និងម្តាយរបស់ខ្ញុំតែងតែនិយាយថា ឪពុករបស់ខ្ញុំមានសក់រួញ និងមានរូបរាងដូចខ្ញុំបេះបិទ។ ខ្ញុំចាប់ផ្តើមស្វែងរកឪពុករបស់ខ្ញុំនៅក្នុងកំឡុងឆ្នាំ១៩៩១ ពេលដែលខ្ញុំចាប់ផ្តើមចូលរៀននៅក្នុងសាលា។ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំតិចតួចបំផុតអំពីឪពុករបស់ខ្ញុំ ព្រោះគាត់ក៏បានចាកចេញពីខ្ញុំដែរ។ ជីដូនជីតារបស់ខ្ញុំបានប្រាប់ខ្ញុំថា ម្តាយរបស់ខ្ញុំបានចាកចេញចាប់តាំងពីខ្ញុំមានអាយុ២ខែ។ ការចាកចេញរបស់គាត់គឺដើម្បីស្វែងរកការងារធ្វើនៅខាងក្រៅផ្ទះ។ ខ្ញុំរស់នៅជាមួយជីដូនជីតាដែលមានវ័យជរា និងមិនអាចមើលថែរក្សាខ្ញុំបាន។ ក្រោយមក ខ្ញុំមិនសូវជាមានភាពស្និទ្ធស្នាលជាមួយ

និងម្តាយរបស់ខ្ញុំទេ ចាប់តាំងពីពេលដែលគាត់បានកសាងក្រុមគ្រួសារថ្មីមួយទៀត។

ការស្វែងរកដំណឹងពីឪពុកខ្ញុំពិតជាដំណើរមួយដ៏លំបាកណាស់ ដោយសារតែខ្ញុំមានព័ត៌មានស្តួចស្តើងបំផុតពីគាត់។ ខ្ញុំធ្លាប់បានស្វែងរកឪពុកខ្ញុំតាំងពីពេលនោះមក ហើយខ្ញុំក៏មានជំនឿយ៉ាងមុតមាំទៅលើការស្វែងរកនេះដែរ។ និយាយដោយស្មោះត្រង់ទៅ សម្រាប់ខ្ញុំ វាមិនជាអ្វីនោះទេប្រសិនបើខ្ញុំរកឃើញឪពុករបស់ខ្ញុំ ហើយយើងមិនបានស្និទ្ធស្នាលនឹងគ្នានោះ។ ខ្ញុំគ្រាន់តែចង់ឃើញរូបគាត់ផ្ទាល់នឹងភ្នែកទាំងគូរបស់ខ្ញុំ។ ខ្ញុំគ្រាន់តែចង់ផ្តិតទុករូបភាពរបស់គាត់នៅក្នុងចិត្តរបស់ខ្ញុំ។ ខ្ញុំចង់មានអារម្មណ៍មួយឲ្យអស់ចិត្តតែប៉ុណ្ណោះ។

ខ្ញុំសូមថ្លែងអំណរគុណដល់ព្រះជាម្ចាស់ដែលពេលនេះព្រះជាម្ចាស់បាននាំឲ្យខ្ញុំស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយខ្ញុំក្នុងការស្វែងរកដំណឹងឪពុករបស់ខ្ញុំ។ ខ្ញុំអធិដ្ឋាន ហើយសង្ឃឹមថា នៅថ្ងៃណាមួយខ្ញុំនឹងបានទទួលដំណឹងពីគាត់។ ខ្ញុំបានភ្ជាប់ជូននូវប័ណ្ណសម្គាល់ខ្លួន និង រូបថតរបស់ម្តាយខ្ញុំនិងខ្ញុំ។ សូមអរគុណ។


ម្តាយរបស់ អាវីន វេនីហ្សូអេ ឡា ឈ្មោះ អាមេនី វេនីហ្សូអេ ឡា
(អាវីន វេនីហ្សូអេ ឡា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ដំណឹងស្វែងរកឪពុក និងបង



នាងខ្ញុំឈ្មោះ **ឡាត់ កញ្ញានា** ឈ្មោះហៅក្រៅ ចក់។ ខ្ញុំមានបងប្អូន ៥នាក់ ខ្ញុំជាកូនពៅក្នុងគ្រួសារ។ ខ្ញុំកំពុងរកក្រុមគ្រួសារដែលបានបាត់ច្រើនឆ្នាំមកហើយ។ ប៉ារបស់ខ្ញុំឈ្មោះ សាមឿន ហៅ ឯម បែកគ្នានៅឆ្នាំ១៩៧៥ ។ បងស្រី វន្នី បានបែកគ្នានៅឆ្នាំ១៩៧៦។ ចំណែកបងប្រុសឈ្មោះ អាយបានបែកគ្នានៅឆ្នាំ១៩៧៩។ កាលឆ្នាំ១៩៧៩ ម៉ាក់របស់ខ្ញុំឈ្មោះ សេង លាង បងប្រុស និងខ្ញុំរស់នៅជាមួយគ្នា។ ក្រោយមកម៉ាក់ក៏បានស្លាប់នៅស៊ីសុផុន នៅក្នុងអំឡុងឆ្នាំ ១៩៧៩។ ខ្ញុំនិងបងប្រុសក៏បែកគ្នា ព្រោះបងប្រុសរបស់ខ្ញុំចង់ទៅភ្នំពេញ ដើម្បីតាមរកបងស្រី វន្នី សិន រីឯខ្ញុំក៏ទៅស្រុកថៃជួបជុំបងប្អូនជីដូនមួយរបស់ម៉ាក់។ សព្វថ្ងៃខ្ញុំរស់នៅសហរដ្ឋអាមេរិក។ រូបនេះ ថតនៅហ្វីលីពីន ក្នុងអំឡុងឆ្នាំ១៩៨០។ ខ្ញុំមានស្រុកកំណើតនៅសៃវ៉ា ខេត្តតាកែវ។ ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះខាងលើ សូមទំនាក់ទំនងមកនាងខ្ញុំតាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្អុីម៉ែល truthbunthorn.s@dccam.org និងលេខទូរសព្ទ ០១២ ៩៩៦ ៧៥០។ សូមអរគុណ!

គេហទំព័រ៖ www.dccam.org





# ដំណើរជីវិតរបស់ ព្រាំ ធិន នៅក្នុងសម័យខ្មែរក្រហម

**ហូ ថុនា**


ព្រាំ ធិន អាយុ៧៧ឆ្នាំ រស់នៅភូមិប៉ោយក្លឿង
ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។
(ហូ ថុនា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រាំ ធិន អាយុ៧៧ឆ្នាំ មានស្រុកកំណើតនៅភូមិប៉ោយក្លឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ធិន គឺជាកូនទី៧ ក្នុងចំណោមបងប្អូនប្រុសស្រី៩នាក់។ សព្វថ្ងៃ ធិន នៅសល់បងប្អូនបង្កើត៤នាក់ តែប៉ុណ្ណោះ ចំណែកបងប្អូន៥នាក់ទៀត បានស្លាប់បាត់បង់ជីវិតដោយសារអត់អាហារនៅអំឡុងសម័យខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ កាលពីក្មេង ធិន មិនបានរៀនសូត្រនោះទេ ដោយសារឪពុករបស់គាត់គិតថាគាត់ គឺជាកូនស្រីដែលគួរតែនៅមើលថែទាំប្អូនៗ និងជួយការងារឪពុកម្តាយ។ ម្យ៉ាងទៀត គ្រួសាររបស់គាត់នៅមានជីវភាពខ្វះខាតនៅឡើយ។

ព្រាំ ធិន បានរៀបរាប់ថា «កាលពីសម័យសង្គមរាស្ត្រនិយម ខ្ញុំមានវ័យជាង១០ឆ្នាំ។ កាលនោះ ឪពុកម្តាយរបស់ខ្ញុំបានទៅរកស៊ីនៅឆ្ងាយពីស្រុក ហើយគាត់បានឲ្យខ្ញុំនៅផ្ទះដើម្បីត្បាញកន្ទេល សំពត់ និងក្រមា។ ក្នុងមួយថ្ងៃខ្ញុំអាចត្បាញបានសំពត់មួយ ឬក្រមាមួយតែប៉ុណ្ណោះ។ នៅពេលដែលខ្ញុំត្បាញបានច្រើនឪពុកម្តាយខ្ញុំបានយក សំពត់ ឬក្រមា ទាំងនោះទៅដោះដូរយកស្រូវអង្ករ ឬឈើពីប្រជាជនដែលរស់នៅឃុំបន្ទាយឆ្មារ ក្នុងស្រុកថ្មពួក។ របររកស៊ីនេះឪពុកម្តាយខ្ញុំបានប្រើរទេះក្របី ដើម្បីដឹកជញ្ជូនទំនិញ និងឈើ។ ជួនកាលកន្លះខែទើបគាត់វិលត្រឡប់មកផ្ទះម្តង។ បន្ទាប់ពីគាត់ដូរបានឈើរួចមក គាត់បានយកឈើនោះទៅលក់បន្តឲ្យប្រជាជនដែលរស់នៅក្នុងភូមិផ្សេងៗ។ នៅពេលដែលគាត់លក់បានប្រាក់ខ្លះ គាត់បានយកប្រាក់នោះធ្វើជាដើមទុនសម្រាប់ទិញអំបោះឲ្យខ្ញុំត្បាញតទៅទៀត។ ខ្ញុំបានប្រកបរបរត្បាញរហូតដល់សម័យ លន់ នល់ ឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥។

នៅអំឡុងឆ្នាំ១៩៧៣ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ រាម ជឹម។ ប្តីរបស់ខ្ញុំមានស្រុកកំណើតនៅស្រុកអង្គស្នួល ខេត្តកណ្តាល។ គ្រួសារប្តីរបស់ខ្ញុំបានរត់គេចពីសង្គ្រាមដែលបង្កឡើងពីសំណាក់កងទ័ព លន់ នល់ និងកងទ័ពខ្មែរក្រហមនៅក្នុងស្រុកអង្គស្នួល កាលពីឆ្នាំ១៩៧១ ទើបខ្ញុំបានស្គាល់ប្តីរបស់ខ្ញុំ។ គាត់មានឪពុកមាដែលរស់នៅក្នុងភូមិជាមួយខ្ញុំ។ ខ្ញុំបានស្គាល់គាត់ គឺដោយសារតែគាត់តែងតែមកឡើងត្នោតនៅក្រោយផ្ទះខ្ញុំ។ ប្តីរបស់ខ្ញុំមានរបរជាអ្នកឡើងត្នោត។ យើងទាំងពីរតែងតែជួបគ្នាជាញឹកញាប់ ហើយស្នេហារវាងយើងទាំងពីរក៏កើតមានឡើង។ ប្តីរបស់ខ្ញុំបានស្នើសុំឪពុកម្តាយរបស់គាត់មកស្តីដណ្តឹងតាមប្រពៃណី។ យើងទាំងពីរ

ក៏បានរៀបការជាមួយគ្នានៅឆ្នាំ១៩៧៣។ បន្ទាប់ពីយើងទាំងពីររៀបការរួចមកប្តីរបស់ខ្ញុំក៏នៅតែបន្តរបរគាត់ ចំណែកឯខ្ញុំក៏នៅធ្វើការងារតម្បាញដដែល។ យើងទាំងពីរបានខំប្រឹងប្រែងសន្សំលុយកាក់រហូតដល់ទិញមាសបាន៥តម្លឹង។ ប៉ុន្តែមាសទាំងនេះ យើងគ្មានសំណាងបានចាយវានោះទេ ពីព្រោះខ្មែរក្រហមបានប្រមែប្រមូលដាក់ជាសម្បត្តិរួមរបស់អង្គការ នៅឆ្នាំ១៩៧៥។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងប្រទេសទាំងមូល។ ពេលនោះ យោធាខ្មែរក្រហមបានមកដល់ភូមិរបស់ខ្ញុំ ហើយបានចាប់ផ្តើមជម្លៀសប្រជាជនចេញពីភូមិឲ្យទៅរស់នៅភូមិស្រុះខាងកើត។ ខ្មែរក្រហមបានប្រកាសថា សូមបងប្អូនទាំងអស់ចាកចេញពីភូមិនេះក្នុងរយៈពេល៣ថ្ងៃតែប៉ុណ្ណោះ នឹងឲ្យវិលត្រឡប់មកភូមិវិញ។ ខ្ញុំឮដូច្នេះក៏មិនបានយកអីវ៉ាន់ទៅច្រើនទេ គឺខ្ញុំយកតែអង្ករ ស្ករ សម្លៀកបំពាក់បន្តិចបន្តួច ព្រមទាំងមាស ទៅជាមួយ។ នៅពេលដែលខ្ញុំទៅដល់ភូមិស្រុះខាងកើត ខ្មែរក្រហមចាប់ផ្តើមអនុវត្តគោលការរបស់ខ្លួន ដោយស្រាវជ្រាវអ្នកដែលជាប់និន្នាការក្នុងរបបចាស់ និងប្រមែប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជនដាក់ជាសម្បត្តិរួម។ មុននឹងប្រមែប្រមូលទ្រព្យសម្បត្តិ ខ្មែរក្រហមបានហៅប្រជាជនទាំងអស់មកប្រជុំ ហើយខ្មែរក្រហមបានលើកឡើងថា ប្រសិនបើបងប្អូនណាលាក់លៀម ឬមិនស្មោះត្រង់ជាមួយអង្គការ បើថ្ងៃក្រោយអង្គការរកឃើញអ្នកទាំងនោះនឹងត្រូវមានទោស។ ពេលខ្ញុំឮដូច្នេះ ខ្ញុំក៏បានប្រគល់មាស៥តម្លឹងដែលខ្ញុំមានជូនទៅដល់អង្គការ។ បន្ទាប់មកខ្មែរក្រហមក៏បានបែងចែកការងារឲ្យខ្ញុំធ្វើជាអ្នកកិនស្រូវ។ កាលនោះខ្ញុំកូនរបស់ខ្ញុំនៅតូច ដូច្នេះនៅពេលដែលខ្ញុំមកធ្វើការខ្ញុំបានយកក្រមាចង និងស្ពាយកូនរបស់។ ខ្ញុំធ្វើការបណ្តើរស្ពាយកូនបណ្តើរ ប្រសិនបើកូនយំខ្ញុំនឹងផ្អាកការងារមួយស្របក់ដើម្បីបំបៅកូន។ កាលនោះ ខ្មែរក្រហមមិនទាន់រឹតបន្តឹងទេ ចំណែកប្រជាជនបានទទួលរបបបាយសម្រាប់បរិភោគនៅឡើយ។ ខ្ញុំ និងប្តីរបស់ខ្ញុំបានស្នាក់នៅ និងធ្វើការនៅភូមិស្រុះខាងកើតបានរយៈពេលប្រហែលបីខែ។ ក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំ និងគ្រួសារឲ្យមករស់នៅភូមិដើងវត្ត។ ពេលនោះ ខ្មែរក្រហមបានប្រកាសសួររកប្រជាជនដែលអាចឡើងត្នោត និងយកទឹកត្នោតបាន។ ប្តីរបស់ខ្ញុំក៏បានលើកដៃ ហើយខ្មែរក្រហមក៏បានចាត់តាំងឲ្យគាត់ឡើងត្នោត។ ចំណែកខ្ញុំមានតួនាទីជាអ្នកកូរស្ករត្នោត។ កាលនោះ ក្រុមកូរស្ករត្នោតមានគ្នា ១០នាក់ និងមាន១០ខ្ទះ។ ក្នុងមួយថ្ងៃខ្ញុំកូរស្ករត្នោតបីពេល គឺនៅពេលព្រឹក ពេលថ្ងៃ និងពេលយប់។ ខ្ញុំកូរស្ករត្នោតដល់ម៉ោង៩យប់ស្ទើរតែជារៀងរាល់យប់។ មានថ្ងៃខ្លះខ្ញុំធ្វើការដល់ម៉ោង១១យប់ក៏មាន។ ក្នុងមួយថ្ងៃៗយើងកូរស្ករត្នោតបានរាប់រយគីឡូក្រាម។ ស្ករត្នោតដែលកូររួចហើយ គឺយើងបានយកទៅទុកនៅក្នុងឃ្លាំងស្ករ។ ប៉ុន្តែខ្ញុំមិនដឹងថា ស្ករត្នោតទាំងនោះត្រូវបានខ្មែរក្រហមបែងចែកទៅខាងណាខ្លះនោះទេ។

បន្ទាប់ពីរដូវកូរស្ករត្នោតកន្លងផុតទៅ ខ្មែរក្រហមបានដាក់ការងារថ្មីឲ្យខ្ញុំធ្វើ គឺការងារដាំដំឡូងមី និងដំឡូងឈ្វា។ ចំណែកឯប្តីខ្ញុំមានតួនាទីជីកប្រឡាយ លើកទំនប់នៅតាមវាលស្រែ។ កាលណោះ ខ្ញុំបានដាំដំឡូងនៅភូមិភ្នំជញ្ជាំង ភូមិត្រពាំងកក់ និងភូមិត្រពាំងវែង។ ទោះបីខ្ញុំជាអ្នកដាំដំឡូងក៏ដោយ ក៏ខ្ញុំមិនមានសិទ្ធិយកមើមដំឡូងដែលខ្លួនដាំទៅហូបបានដែរ ព្រោះមានឈ្លបភូមិនៅតាមដានមើល។ ប៉ុន្តែបើមានមើមដំឡូងខ្លះដែលបាក់ឬដកដាច់ជាកំណាត់ៗ ខ្ញុំអាចយកមើមដំឡូងនោះមកហូបបាន ប៉ុន្តែមិនអាចយកបានច្រើននោះទេ។ នៅពេលដែលខ្ញុំយកមើមដំឡូងនោះមកដល់ផ្ទះ ខ្ញុំបានយកវាមកឈូសដើម្បីចម្អិនចែកកូនៗហូប។ ខ្ញុំធ្វើការងារដាំដំឡូងរហូតដល់កងទ័ពស្ម័គ្រចិត្តវៀតណាមវាយផ្តួលរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩។ បន្ទាប់ពីខ្មែរក្រហមដួលរលំខ្ញុំ និងប្តីរបស់ខ្ញុំបាននាំកូនៗមករស់នៅភូមិប៉ោយក្លៀង និងប្រកបរបរធ្វើស្រែរហូតមកដល់សព្វថ្ងៃ។



ប្តីរបស់ ព្រាំ ធិន ឈ្មោះ រាម ជឹម។
(ហូ ផុនា /មជ្ឈមណ្ឌលឯកសារកម្ពុជា)





# បូជាភ្លើង

## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

*រេហ្ស៊ី ប្រ៊ាយ*

(តពីលេខមុន)



ពិព័រណ៍រូបថតនៅ សារមន្ទីរស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ។ ( សូវិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

### «តើអ្នកអាចអត់ឱនទោសបានដែរឬទេ?»

នេះ គឺជាសំណួរមួយដែលខ្ញុំតែងតែគិតដល់រហូតទាល់តែខ្ញុំដឹងថា ខ្ញុំមិនចាំបាច់គិតអំពីវានោះទេ។ អ្វីដែលកើតឡើងហើយមិនអាចកែប្រែបានទេ។ ពេលវេលាក៏មិនអាចវិលត្រឡប់ក្រោយបានដែរ ចំណែកឯអ្នកដែលបានស្លាប់ហើយក៏មិនអាចមានជីវិតវិញបានដែរ។ ថ្ងៃនេះគឺសម្រាប់អនាគតកាល។ អ្វីដែលយើងអាចធ្វើថ្ងៃនេះបាន គឺធ្វើកិច្ចការណាដែលមិនធ្វើឲ្យព្រឹត្តិការណ៍នេះកើតឡើងបានម្តងទៀត។

### «តើអ្នកបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញដែរឬទេ?»

ខ្ញុំត្រូវស៊ូទ្រាំជាមួយនឹងសុបិនអាក្រក់របស់ខ្ញុំអស់រយៈពេលយ៉ាងយូរអង្វែង។ នៅពេលដែលខ្ញុំរៀបការ ហើយមានកូន ខ្ញុំបានយល់សប្តិថាខ្ញុំកំពុងតែនៅស៊ីហ្គេតឯក្រុមគ្រួសាររបស់ខ្ញុំនៅទីក្រុងស្តុកខុល។ ខ្ញុំគិតថាខ្ញុំនឹងមិនហ៊ានត្រឡប់ទៅទីនោះម្តងទៀតទេ។ ប៉ុន្តែពេលវេលាបានកន្លងផុតទៅហើយនៅពេលដែលកូនៗរបស់ខ្ញុំបានធំដឹងក្តី ពួកគេចាប់ផ្តើមសួរសំណួរជាច្រើននៅពេលដែល

បានដឹងអំពីរឿងរ៉ាវដែលកើតឡើងមកលើគ្រួសាររបស់យើង។ យ៉ាងណាមិញ កូនៗរបស់ខ្ញុំមិនមានជីដូនជីតា អ៊ំ មីង ឬគ្រួសារដែលអាចចំណាយពេលវេលាជាមួយនៅពេលវិស្សមកាល ដូចជាមិត្តរួមថ្នាក់ដ៏ទៃទៀតរបស់ខ្លួននោះទេ។ ពួកគេក៏មិនមានថ្ងៃឈប់សម្រាកដែលគ្រួសារទាំងមូលបានជួបជុំគ្នាដែរ។ នៅពេលដែលកូនៗរបស់ខ្ញុំឈានចូលវ័យជំទង់ ខ្ញុំបានសម្រេចចិត្តថា យើងនឹងធ្វើដំណើរទៅស៊ុំហ្គេតម្តងទៀត។ ធ្វើបែបនេះពួកគេអាចនឹងមានអារម្មណ៍ជិតស្និទ្ធជាមួយនឹងដើមកំណើតរបស់ខ្លួន ហើយអាចយល់ដឹងទាំងអស់គ្នាអំពីស្ថានភាពរបស់យើង។

នៅពេលដែលធ្វើដំណើរ គឺពិតជាមានភាពពិបាកខ្លាំងណាស់ក្នុងការប្រាប់កូនៗរបស់ខ្ញុំអំពីសមាជិកគ្រួសារដែលយើងបានបាត់បង់។ ខ្ញុំមិនចង់ឲ្យពួកគេឃើញថាខ្ញុំពិបាកចិត្តនោះទេ។ ដូច្នេះហើយទើបខ្ញុំនិយាយហាក់បីដូចជាខ្ញុំជាអ្នកទេសចរណ៍ម្នាក់ដែលមកធ្វើដំណើរកំសាន្តនៅបរទេស។ ខ្ញុំមិនបានអនុញ្ញាតឲ្យខ្លួនឯងមានអារម្មណ៍អ្វីទាំងអស់។ ខ្ញុំមិនទាន់យល់ច្បាស់ថា ការរៀបរាប់អំពីការពិតផ្តល់ចំណេះដឹងតែផ្នែកបញ្ញា ដែលអាចជ្រាបដល់ត្រឹមតែស្មារតីរបស់មនុស្សម្នាក់ៗតែប៉ុណ្ណោះ។ សម្រាប់ការយល់ដឹងច្បាស់ដោយអារម្មណ៍រឿងរ៉ាវទាំងនោះត្រូវតែជ្រាបឲ្យដល់បេះដូងរបស់មនុស្សម្នាក់ៗ។ កូនៗរបស់ខ្ញុំបានចម្លើយសម្រាប់សំណួររបស់ខ្លួន ប៉ុន្តែខ្ញុំមិនបានដឹងអំពីអ្វីដែលពួកគេបានគិតនោះទេ។ ខ្ញុំគ្មានបទពិសោធន៍ពិតប្រាកដអំពីការទៅលេងផ្ទះកុមារភាពរបស់ខ្លួននោះទេ ហើយនោះគឺជាមូលហេតុដែលខ្ញុំបានសម្រេចចិត្តធ្វើដំណើរទៅទីនោះម្តងទៀត។ ដើម្បីធ្វើធម្មយាត្រាជាមួយប្អូនស្រីខ្ញុំ និងទៅទស្សនាកន្លែងទាំងអស់ដែលមានសារសំខាន់ចំពោះយើង ដើម្បីឲ្យអារម្មណ៍ទាំងនោះឱបក្រសោបយើង ហើយធ្វើឲ្យយើងយំចេញមកក្រៅ។ នៅរដូវក្តៅបន្ទាប់យើងក៏បានចេញដំណើរ។ ដំណើរកម្សាន្តលើកដំបូងរបស់យើង គឺទៅផ្នែកកណ្តាលនៃទីក្រុងដែលខឡានត្រូវបានជំនួសទៅដោយហាងទំនិញជាច្រើន។ នេះហាក់បីដូចជាការចូលរោងភាពយន្តដើម្បីមើលការសម្តែងដែលខ្ញុំធ្លាប់បានឃើញម្តងរួចទៅហើយ។ ទេសភាពគឺនៅដដែលប៉ុន្តែតួអង្គទាំងអស់ត្រូវបានផ្លាស់ប្តូរ។ ឆាកតន្ត្រីនៅក្នុងខឡាននៅតែមាន ប៉ុន្តែ ត្រូវបានកសាងថ្មី។ ស្លាកនៅខាងក្រៅហាងទំនិញត្រូវបានផ្លាស់ប្តូរ។ ជំនួសទៅដោយឈ្មោះរបស់ជនជាតិជ្វីហ្វ ឥឡូវនេះ គឺពោរពេញទៅដោយឈ្មោះជនជាតិរូម៉ានី។ ខ្ញុំបានដើរចូលទៅក្នុងហាងមួយដែលពីមុនធ្លាប់ជាកម្មសិទ្ធិរបស់ពូខ្ញុំ។ នៅពេលនេះវា គឺគ្រប់គ្រងដោយម្ចាស់ដែលខ្ញុំមិនស្គាល់ និងលក់ក្រណាត់ ដូចដែលខ្ញុំធ្លាប់បានជ្រើសរើសនៅក្នុងហាងរបស់ពូខ្ញុំ។ ខ្ញុំដើរជុំវិញទីក្រុង ហើយបានឃើញមីងរបស់ខ្ញុំនៅជ្រុងម្ខាងនៃផ្លូវ ប៉ុន្តែ ពេលខ្ញុំដើរទៅរកគាត់ៗ គឺជាមនុស្សផ្សេងទៅវិញទេ។

ផ្ទះចាស់របស់យើងនៅដដែល ប៉ុន្តែម្ចាស់ផ្ទះបានមើលមកយើងដោយសង្ស័យនៅពេលដែលយើងនិយាយថាធ្លាប់រស់នៅទីនេះក្នុងអំឡុងពេលកុមារភាពរបស់យើង។ ពួកគេភ័យខ្លាចថា យើងចង់យកផ្ទះវិញ ប៉ុន្តែពួកគេនៅតែអនុញ្ញាតឲ្យយើងចូលទៅក្នុង និងដើរមើលជុំវិញ។ នៅខាងក្នុងខ្ញុំមិនបានឃើញអ្វីដែលនៅចំពីមុខខ្ញុំនោះទេ។ ផ្ទុយទៅវិញខ្ញុំបានឃើញបន្ទប់គេងរបស់ឪពុកម្តាយខ្ញុំដូចដែលនៅពេលនោះ។ នៅក្នុងបន្ទប់របស់ខ្ញុំៗបានឃើញវត្ថុដែលខ្ញុំស្រឡាញ់ជាងគេ គឺព្យាណូ និងសៀវភៅ។ ខ្ញុំស្ទើរតែអាចឮសំឡេងឆ្កែរបស់យើងព្រុសនៅខាងក្រៅទីធ្លា។ លីវី និងខ្ញុំបានស្រក់ទឹកភ្នែកជាច្រើន។ យើងប្រៀបបានដូចជាកុមារដែលបានចាកចេញពីផ្ទះដោយគ្មានការអនុញ្ញាត ហើយឥឡូវនេះគឺកំពុងតែភ្លក់រសជាតិនៃផលវិបាកបន្ទាប់ពីនោះ។

ការធ្វើដំណើរនេះនាំមកនូវផលវិជ្ជមានជាច្រើន។ សុបិនអាក្រក់របស់ខ្ញុំបានកាត់បន្ថយ។ ទោះបីជាសុបិនអាក្រក់ទាំងនោះមិនបានបាត់ទៅណា ប៉ុន្តែជារឿយៗខ្ញុំឈប់ភ្ញាក់ឡើងដោយបែកញើសជោគខ្លួន និងជាមួយអារម្មណ៍ថា កូនរបស់ខ្ញុំកំពុងនៅប្រទេសស៊ុយអែតហើយខ្ញុំនៅឆ្ងាយពីពួកគេនិងមិនអាចឃើញពួកគេម្តងទៀតទេ។ នេះធ្វើឲ្យខ្ញុំយល់ថា មនុស្សគឺត្រូវតែប្រឈមមុខនឹងភាពភ័យខ្លាច។ មានតែបែបនោះទេទើបយើងអាចយកឈ្នះភាពភ័យខ្លាចរបស់ខ្លួនបាន។





## «តើអ្នកបានគិតអំពីពេលវេលានៅក្នុងជំរំជាញឹកញាប់ដែរឬទេ?»

ខ្ញុំបានបង្រៀនអំពីពេលដែលខ្ញុំនៅតាមជំរំផ្សេងៗគ្នាស្ទើរតែជារៀងរាល់ថ្ងៃ ចាប់តាំងពីអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ហើយរាល់ពេលដែលខ្ញុំនិយាយអំពីវា ខ្ញុំមានអារម្មណ៍ថាធូរចិត្ត។ ទោះបីជាពិបាកខ្លាំងប៉ុន្តែវាបាននាំទៅរកអ្វីដែលល្អនិងបានក្លាយទៅជាវិធីមួយសម្រាប់ការជាសះស្បើយអំពីការប៉ះទង្គិចផ្លូវចិត្តរបស់ខ្ញុំ។ អ្នករស់រានមានជីវិតភាគច្រើនមានការពិបាកក្នុងការនិយាយអំពីអ្វីដែលបានកើតឡើងចំពោះខ្លួន។ ដូច្នេះហើយវាបានក្លាយទៅជាសេចក្តីឈឺចាប់មួយដែលមិនអាចប្រែប្រួលបាន ពីព្រោះតែខ្ញុំធ្វើការជារៀងរាល់ថ្ងៃដោយនិយាយអំពីវា និងសរសេរសៀវភៅអំពីវាៗមិនមានតទៅទៀតទេនៅពេលដែលខ្ញុំឈប់ធ្វើការ។ សេចក្តីឈឺចាប់ទាំងនោះមិនមានវត្តមាននៅក្នុងស្មារតីរបស់ខ្ញុំទៀតនោះទេ ទោះបីជានៅតែកប់នៅក្នុងដួងចិត្តរបស់ខ្ញុំ ហើយអាចលេចចេញមកក្រៅម្តងទៀតគ្រប់ពេលណាក៏ដោយ។

ប្រសិនបើខ្ញុំកំពុងតែដើរតាមផ្លូវហើយឮសំឡេងឆ្កែព្រុសនៅពីក្រោយខ្ញុំៗនឹងមានអារម្មណ៍ថាខ្លួនឯងបានវិលត្រលប់ទៅជំរំវិញភ្លាមៗដែលមានក្រុមក្មេងស្រីដើរជាប្រាំជួរនៅតាមផ្លូវទៅធ្វើការងារ និងមានកងការពារណាហ្ស៊ីដើរពីខាងក្រោយជាមួយសត្វឆ្កែ។ ប្រសិនបើមាននរណាម្នាក់ដួលចេញពីជួរ កងការពារណាហ្ស៊ីនោះនឹងឲ្យឆ្កែហក់មកខាំអ្នកនោះ។ ខ្ញុំនៅតែអាចចងចាំអំពីអារម្មណ៍ភ័យខ្លាច និងខ្យល់បក់ត្រជាក់ដែលប៉ះសម្លៀកបំពាក់ដ៏ស្តើងរបស់ខ្ញុំ និងអារម្មណ៍ឈឺចាប់នៅលើជើងដែលបណ្តាលមកពីស្បែកជើងរបស់ខ្ញុំ។ នៅពេលខ្លះទៀតខ្ញុំស្រមៃឃើញបំពង់ផ្សែងហើយមានអារម្មណ៍ឈឺចាប់នៅពេលដែលខ្ញុំដឹងថាបំពង់ផ្សែងនៅក្នុងអូសឈ្វិចនោះគេប្រើសម្រាប់ធ្វើអ្វី។

ពេលខ្ញុំរស់នៅជាមួយប្អូនស្រី យើងកម្រនិយាយគ្នាអំពីហូឡូខស្តណាស់។ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្ញុំនឹកគិតឃើញអំពីអតីតកាល វាក៏បែបនោះសម្រាប់នាងដែរ។ យើងគ្រាន់តែមើលមុខគ្នាទៅវិញទៅមកតែប៉ុណ្ណោះដើម្បីដឹងថាយើងទាំងពីរនាក់កំពុងគិតអំពីអ្វី។

## «តើអ្នកមានអារម្មណ៍បែបណាដែរនៅពេលដែលមានវ័យចំណាស់ទៅ?»

មានយប់មួយនោះខ្ញុំភ្ញាក់ដឹងខ្លួនហើយសប្បាយចិត្តពីព្រោះជើងយន្តហោះរបស់ខ្ញុំត្រូវបានពន្យារពេល។ ខ្ញុំនៅតែមិនយល់ថាតើទាំងអស់នេះ គឺជាក្តីសុបិនឬថាតើខ្ញុំពិតជាកំពុងតែជិតចាប់ផ្តើមធ្វើដំណើរនោះទេ។ ប៉ុន្តែដោយសារតែជើងយន្តហោះហើរត្រូវបានពន្យារពេល ខ្ញុំមានអារម្មណ៍ល្អហើយខ្ញុំអាចទន្ទឹងរង់ចាំថ្ងៃនិទាឃរដូវថ្មីមួយទៀត។ តើខ្ញុំកំពុងតែយល់សុបិនឬតើនេះគឺជាការពិត?

នៅក្នុងជំរំ ខ្ញុំបានព្យាយាមស្រមៃថា សុបិនគឺជាការពិតហើយពេលថ្ងៃគឺជាក្តីសុបិនទៅវិញ។ តើឥឡូវនេះគឺដូចដែលពេលនោះដែរឬទេ? តើអ្វីទៅជាការលំបាកដែលខ្ញុំកំពុងតែជួបប្រទះសព្វថ្ងៃនេះ? ចម្លើយគឺច្បាស់ណាស់គឺវ័យចំណាស់។

តើនៅពេលមួយណាដែលមនុស្សចាប់ផ្តើមមានវ័យចំណាស់? ថ្ងៃនេះវាបានចាប់ផ្តើមហើយបន្តពីមួយថ្ងៃទៅមួយថ្ងៃទៀត។ សព្វថ្ងៃនេះយើងនិយាយអំពីនិវត្តជនវ័យក្មេងដែលកំពុងនៅមានកម្លាំង។ ប៉ុន្តែកម្លាំងនោះនឹងកាន់តែថយចុះទៅតាមពេលវេលា ហើយមនុស្សវ័យចំណាស់ដែលក្មេងជាងគេក៏ក្លាយទៅជាមនុស្សវ័យចំណាស់ដែលចាស់ជាងគេ។ នេះគឺជារឿងបុគ្គលមួយយ៉ាងពិតប្រាកដ។ អាយុជីវសាស្ត្ររបស់មនុស្សម្នាក់ៗមិនតែងតែដូចគ្នានឹងអាយុដែលមនុស្សម្នាក់គិតអំពីនោះទេ។ ខ្ញុំខ្លួនឯងក៏មិនបានគិតអំពីអាយុរបស់ខ្ញុំដែរ រហូតទាល់តែដល់ថ្ងៃខួបកំណើត ៨២ឆ្នាំរបស់ខ្លួន។ នោះហើយគឺជាពេលដែលខ្ញុំភ្ញាក់ផ្អើលថាខ្ញុំចាស់ហើយ ខ្ញុំមានអាយុ៨២ឆ្នាំហើយ។ ខ្ញុំចាប់ផ្តើមគិតលេខហើយភ្លាមៗនោះខ្ញុំបានដឹងថាខ្ញុំមានវ័យចំណាស់ចាប់តាំងពីខ្ញុំមានអាយុ២៨ឆ្នាំមកម្ល៉េះ។ វ័យចំណាស់មានគុណសម្បត្តិនិងគុណវិបត្តិរបស់វា។ រឿងដែលពិបាកបំផុត គឺការរៀនទទួលស្គាល់អំពីការបាត់បង់សមត្ថភាពបន្តិចម្តងៗរបស់មនុស្សម្នាក់ ដែលចាប់ផ្តើមពីការលំបាកក្នុងការមើលឃើញ និងការស្តាប់ហើយបន្តជាមួយកំហុសឆ្គងផ្នែករាងកាយ និងផ្លូវចិត្តផ្សេងៗទៀត។ អ្វីៗគ្រប់យ៉ាងថយចុះ ចំណែកឯចលនារបស់យើងក៏កាន់តែយឺតយ៉ាវ ហើយសកម្មភាពរបស់យើង គឺកាន់តែដុនដាប។ យើងមិន




*ពិព័រណ៍រូបថតនៅ សារមន្ទីរ ស្កុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេស ប៉ូឡូញ។ ( សូវិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា )*

គួរបន្តបើកបរទៀតនោះទេ។ មុនដំបូងខ្ញុំខឹងខ្លួនឯងដែលមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីធ្វើអ្វីមួយដូចកាលពីមុនទៀត ប៉ុន្តែបន្តិចម្តងៗខ្ញុំបានយល់ថាខ្ញុំត្រូវតែទទួលស្គាល់ការពិត ហើយរៀនបន្ថយល្បឿនរបស់ខ្លួន។ ដំបូងឡើយខ្ញុំបានព្យាយាមសងការខាតបង់របស់ខ្លួនឯងដោយធ្វើអ្វីមួយដោយយកចិត្តទុកដាក់ឲ្យបានកាន់តែច្រើនជាងមុននិងអត់ធ្មត់ថែមទៀត។ ប៉ុន្តែចុងក្រោយខ្ញុំបានត្រឹមតែសន្និដ្ឋានថាវាមិនអាចជួយអ្វីបានច្រើននោះទេ។ ការចងចាំរយៈពេលខ្លីរបស់យើងក៏បានបាត់បង់ទៅដែលធ្វើឲ្យកាន់តែមានភាពពិបាកក្នុងការចងចាំឈ្មោះរបស់មនុស្សម្នាក់ៗ នេះគឺហាក់បីដូចជាខ្ញុំបានបាត់បង់ការផ្សារភ្ជាប់ទៅនឹងខួរក្បាលរបស់ខ្លួនដែលមិនចង់ឲ្យចម្លើយដែលត្រឹមត្រូវនោះទេ ទោះបីជាខ្ញុំខំប្រឹងយ៉ាងណាក៏ដោយ។

ខ្ញុំកត់សម្គាល់ឃើញថាអ្វីៗដែលធ្លាប់តែមានសារសំខាន់បំផុតចំពោះខ្ញុំបានបាត់បង់សារសំខាន់របស់វា។ ប៉ុន្មានឆ្នាំមកនេះ ខ្ញុំមានអារម្មណ៍ថាដូចជាការឡើងភ្នំមួយដែលនៅពេលដែលយើងឡើងទៅដល់កំពូលភ្នំយើងអាចឃើញថាអ្វីៗទាំងអស់នៅខាងក្រោមកាន់តែតូចទៅៗ រហូតទាល់តែយើងមិនអាចមើលឃើញអ្វីបានទៀតនោះទេ។

ខ្ញុំឈប់ខឹងអំពីរឿងតូចតាចទៀតហើយ។ ខ្ញុំអាចអត់ទិនដល់ការនិយាយដែលឆោតល្ងង់ និងទទួលយកការចោទប្រកាន់មិនយុត្តិធម៌ដើម្បីជៀសវាងពីជម្លោះ។ ខ្ញុំខ្លួនឯងក៏មិនមានអារម្មណ៍ថា មានសារសំខាន់ទៀតនោះដែរ។ ជារៀងរាល់ព្រឹក ខ្ញុំសប្បាយរីករាយនឹងថ្ងៃថ្មី ការផ្លាស់ប្តូរនៃរដូវកាលថ្មី និងសប្បុរសធម៌ពីមនុស្សដទៃទៀត។ វាក៏កាន់តែមានសារសំខាន់ក្នុងការជួបជាមួយមនុស្សដទៃទៀតដែរ។ ខ្ញុំដែលធ្លាប់តែជាចចកឯកោម្នាក់នៅពេលនេះគឺសប្បាយរីករាយដែលមានមិត្តរាប់អានច្រើន។

នៅពេលដែលខ្ញុំបានធ្វើការស្រាវជ្រាវទៅរកការវិវត្តនៃអាយុ ខ្ញុំចាប់ផ្តើមយល់អំពីខ្លួនឯងបានច្បាស់ជាងមុន។ ជីវិតផ្លាស់ប្តូរគ្រប់ពេលវេលា ហើយយើងស្ទើរតែមិនអាចដឹងបានទេថា នៅពេលណាដែលយើងឆ្លងកាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ ទារកធំលូតលាស់ទៅជាក្មេងតូច ឯកុមារទៅជាក្មេងជំទង់។ មនុស្សស្រីឆ្លងកាត់ការអស់រដូវ ហើយសេចក្តីស្លាប់គឺជាដំណាក់កាលចុងក្រោយ។ សេចក្តីស្លាប់ គឺជាអ្វីដែលកំពុងរង់ចាំយើងទាំងអស់គ្នា ប៉ុន្តែនិយាយអំពីវាគឺជាបម្រាមហាមឃាត់មួយទៅវិញ។ រាងកាយដែលធ្លាក់ចុះទ្រុឌទ្រោមត្រៀមលក្ខណៈសម្រាប់សេចក្តីស្លាប់។ នេះហើយគឺជាអ្វីដែលអ្នកវិទ្យាសាស្ត្រកំពុងតែហៅថាជាការវិវត្តនៃអាយុ។ ការគិតអំពីសេចក្តីស្លាប់កាន់តែខិតជិតជាងមុន ហើយបានបង្ហាញឲ្យឃើញកាន់តែច្បាស់នៅក្នុងសុបិនដែលកាន់តែបង្ហាញឲ្យឃើញអំពីចលនា អំពីការធ្វើដំណើរ និងអំពីអ្វីដែលមនុស្សម្នាក់បានភ្ជាប់យកទៅជាមួយ។

សេចក្តីស្លាប់មិនអាចបន្លាចខ្ញុំបានទេ។ ខ្ញុំមានជីវិតរស់នៅយូរណាស់មកហើយ យូរជាងអ្វីដែលខ្ញុំបានស្រមៃទៅទៀត ហើយពេលខ្លះអ្វីៗទាំងអស់នឹងបានបញ្ចប់ទៅ។ អ្នកចាស់ចាកចេញពីយើងទៅហើយអ្នកថ្មីផ្សេងទៀតចូលមកដល់។ ខ្ញុំដឹងថាមិនមានការពន្យល់មួយណាដែលអាចបកស្រាយបាននោះទេថាហេតុអ្វីបានជាយើងរស់នៅលើពិភពលោកនេះ។ អ្វីដែលសំខាន់នោះគឺថាតើយើងនឹងរស់នៅជារៀងរាល់ថ្ងៃនេះដោយរបៀបណាទើបអ្នកដែលកើតមកបន្ទាប់ពីយើងអាចរស់នៅក្នុងពិភពលោកមួយដែលល្អប្រសើរជាងពិភពលោកដែលយើងកំពុងតែរស់នៅ។





## «បន្ទាប់ពីអ្វីៗដែលបានកើតឡើងមក តើអ្នកជឿទៅលើព្រះដែរឬទេ?»

តើអាចទៅរួចដែរឬទេដែលជឿទៅលើព្រះបន្ទាប់ពីអ្វីៗដែលបានកើតឡើងនៅហូឡូខសត៍? នេះគឺជាសំណួរដែលអ្នកនិពន្ធ និងអ្នកទស្សនវិទូជាច្រើនបានគិតនិងសរសេរអំពីវា។ ប្រសិនបើអ្នកសួរទៅអ្នកដែលរស់រានមានជីវិត អ្នកនឹងសង្កេតឃើញថាមនុស្សម្នាក់ៗនឹងមានប្រតិកម្មខុសៗគ្នា។ មនុស្សមួយចំនួនធំដែលមានជំនឿទៅលើព្រះយ៉ាងខ្លាំងមុនពេលសង្គ្រាមកើតឡើងបាននិយាយថា «ប្រសិនបើរឿងនេះអាចកើតឡើងបាន ខ្ញុំមិនជឿលើព្រះទៀតទេ»។ ខ្ញុំចងចាំស្ត្រីកាន់សាសនាម្នាក់នៅក្នុងទូរថភ្លើងនៅតាមផ្លូវទៅកាន់អូសឈ្វិចដែលបានសួរអ្នកជិតខាងថា តើនាងអាចសុំបរិភោគសាច់ជ្រូកបន្តិចបានទេ។ ម៉្យាងវិញទៀត មានអ្នកដែលមិនជឿថាមានព្រះជាច្រើននាក់ បានកាន់សាសនាយ៉ាងខ្ជាប់ខ្ជួន បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ។ ពួកគេបានជឿជាក់យ៉ាងខ្លាំងថាព្រះ គឺជាអ្នកដែលបានជួយពួកគេឲ្យរួចជីវិត។

ស្ត្រីកាន់សាសនាគ្រិស្តជាច្រើននាក់ដែលនៅក្នុងជំរំជាមួយខ្ញុំប្រកាន់វិន័យចាស់យ៉ាងខ្ជាប់ខ្ជួន និងមិនដែលបាត់បង់ជំនឿរបស់ខ្លួននោះទេ។ មានថ្ងៃមួយពួកគេបានត្រឡប់មកពីធ្វើការងារនៅក្នុងសំណង់បាក់បែកវិញដោយក្តីសប្បាយរីករាយ ពីព្រោះតែបានរកឃើញសៀវភៅអធិដ្ឋានមួយក្បាល។ ពួកគេបានអធិដ្ឋានជារៀងរាល់ព្រឹកនិងយប់។ ពួកគេជឿជាក់យ៉ាងពេញលេញនិងយ៉ាងមុតមាំថា «ព្រះបានជួយពួកគេឲ្យគេចពីបន្ទប់ផ្សែងពុលនិងបន្តជួយពួកគេប្រសិនបើខ្លួនធ្វើតាមបទបញ្ញត្តិរបស់ទ្រង់»។ ទោះបីជាមានការត្រួតពិនិត្យជាញឹកញាប់ក៏ដោយពួកគេនៅតែអាចថែរក្សាសៀវភៅអធិដ្ឋានរបស់ខ្លួនហើយធ្វើតាមសេចក្តីបង្គាប់របស់សាសនាទោះបីជាមានការលំបាកក៏ដោយ។ អ្នកទាំងនោះថែមទាំងអាចរៀបចំគណនាថ្ងៃលាងបាប ដែលមនុស្សម្នាក់ៗមិនត្រូវបរិភោគអាហារឬផឹកទឹកឡើយ។ ហើយក៏មិនចាំបាច់សួរដែរថាតើពួកគេនឹងបរិភោគអាហារដែរឬអត់នោះ។ ដោយគ្រពះទទេស្អាតសូម្បីតែមិនទាន់លាងមាត់របស់ខ្លួន ពួកគេចូលជួរដើម្បីដើរទៅកន្លែងធ្វើការងារ។ ដល់កន្លែងនោះ ពួកគេធ្វើការលើកបាវស៊ីម៉ងត៍ធ្ងន់ៗ ហើយសូម្បីតែទឹកមិនផឹកផង។

ជំនឿអាចមានផលប្រយោជន៍នៅក្នុងដំណើរជីវិតដោយមិនចាំបាច់គិតអំពីសាសនាមួយណារបស់មនុស្សឡើយ។ គ្រោះថ្នាក់អាចកើតមានឡើងនៅពេលដែលជំនឿត្រូវបានជឿហួសឆ្ងាយពេក ហើយមនុស្សគិតថាអ្នកដទៃទៀតត្រូវតែមានជំនឿដូចខ្លួនដែរ។ នោះហើយគឺជាពេលដែលជំនឿបានប្រែក្លាយទៅជាជ្រុលនិយម ហើយបញ្ញត្តិនៃសេចក្តីស្រឡាញ់ត្រូវបានប្រែក្លាយទៅជាបទបញ្ញត្តិនៃសេចក្តីស្អប់ខ្ពើម។ នៅក្នុងជំរំមានអ្នកដែលមិនជឿទៅលើព្រះជាច្រើននាក់បានសើចចំអកដល់អ្នកដែលជឿទៅលើព្រះ ក្នុងអំឡុងពេលដែលពួកគេទាមទារឲ្យមានការគោរពចំពោះការមិនជឿរបស់ខ្លួន។ ពួកគេមានការលំបាកក្នុងការយល់ដឹងថា ការទទួលស្គាល់ត្រូវតែស្របតាមវិធីទាំងពីរ។ ខ្ញុំមិនអាចទាមទារឲ្យមានការទទួលស្គាល់ចំពោះជំនឿរបស់ខ្ញុំទេ ប្រសិនបើខ្ញុំមិនអាចទទួលស្គាល់ជំនឿរបសអ្នកបាន។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ គ្មានអ្វីផ្លាស់ប្តូរឥរិយាបថពីមុនរបស់ខ្ញុំនោះទេ។ ខ្ញុំបានរក្សាជំនឿដូចដែលខ្ញុំធ្លាប់មាននៅមុនពេលហូឡូខសត៍។ ខ្ញុំបានធំធាត់ឡើងជាជនជាតិជ្វីហ្វហើយក៏នៅតែជាជនជាតិជ្វីហ្វដដែល។ ប៉ុន្តែខ្ញុំមិនជឿថាព្រះរបស់ខ្ញុំវិសេសវិសាលជាងគេនោះទេ។ ប្រសិនបើមានព្រះនោះគឺជាព្រះតែមួយដែលយើងទាំងអស់គ្នាជឿទៅលើ មិនថាព្រះយេហូវ៉ា ព្រះគ្រិស្ត ឬព្រះអាល់ឡាស់។ ខ្ញុំមិនជឿថាព្រះកំពុងគង់នៅលើស្ថានសួគ៌ហើយមើលថែរក្សាយើងម្នាក់ៗ និងប្រាប់យើងអំពីអ្វីៗគ្រប់យ៉ាងដែលយើងគួរតែធ្វើនោះទេ។ ព្រះគឺនៅក្នុងខ្លួនរបស់យើងគ្រប់គ្នាៗ។ គឺនៅក្នុងសីលធម៌ដែលជួយយើងឲ្យដោះស្រាយអំពីបញ្ហាជីវិតបាន។

ច្បាប់មួយបាននិយាយថា «កុំធ្វើទៅលើអ្នកដទៃនូវអំពើអ្វីដែលអ្នកមិនចង់ឲ្យគេធ្វើមកលើអ្នក» ច្បាប់នេះអាចរកឃើញនៅគ្រប់សាសនា និងគ្រប់ភាសាទាំងអស់។ ប្រសិនបើមនុស្សទាំងអស់ត្រូវបានដឹកនាំដោយច្បាប់មួយនេះ យើងនឹងរស់នៅក្នុងពិភពលោកមួយដែលកាន់តែប្រសើរឡើង។

**(តនៅលេខក្រោយ)**

# ភូមិសាទុំ

**សុខ វណ្ណះ**

ភូមិសាទុំ គឺជាភូមិមួយក្នុងចំណោមភូមិទាំង១៨ នៃឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) និងមានចម្ងាយប្រមាណជាង២០គីឡូម៉ែត្រ ប៉ែកខាងកើតផ្លូវជាតិលេខ៧។ ភូមិសាស្រ្តភូមិសាទុំ គឺស្ថិតនៅជាប់នឹងព្រំដែនរវាងខេត្តត្បូងឃ្មុំ និងខេត្តបិញភឿកនៃប្រទេសវៀតណាម។ នៅអំឡុងទសវត្សរ៍៦០ និង៧០ មានកងទ័ពយៀកកុងជាច្រើនបានចូលដល់ទីនេះក្នុងទឹកដីកម្ពុជា។ មិនខុសពីភូមិដ៏ទៃទៀតដែលស្ថិតជាប់នឹងព្រំដែនជាមួយប្រទេសវៀតណាម កងទ័ពយៀកកុងរាប់រយនាក់បានមកបោះទីតាំងក្នុងព្រៃក្នុងភូមិសាស្រ្តភូមិសាទុំ។ បន្ទាប់មកទាហានសហរដ្ឋអាមេរិក និងទាហានវៀតណាមខាងត្បូងក៏បានចូលមកដល់ភូមិសាទុំ។ ហេតុការណ៍ប្រយុទ្ធគ្នារវាងទាហានអាមេរិកដែលសហការជាមួយទាហានវៀតណាមខាងត្បូងប្រឆាំងទល់នឹងកងទ័ពយៀកកុង បានកើតមានឡើងជាបន្តបន្ទាប់។ នៅពេលនោះ មានការទម្លាក់គ្រាប់បែកជាច្រើនសន្ធឹកសន្ធាប់មកលើភូមិសាទុំ ដែលបណ្តាលឲ្យកងទ័ពយៀកកុង និងប្រជាជនមួយចំនួនបានស្លាប់ និងរបួស។ មានឧទ្ធម្ភាគចក្ររបស់ទាហានអាមេរិកមួយគ្រឿងបានធ្លាក់នៅក្នុងភូមិសាស្រ្តភូមិសាទុំ។

កុប ឌី អាយុ៦៩ឆ្នាំ មានប្រពន្ធឈ្មោះ ឆេន មានកូន៦នាក់ ប្រុស៣ ស្រី៣ ប្រកបមុខរបរធ្វើស្រែចម្ការនៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានរៀបរាប់ថា កាលពីកុមារខ្ញុំរស់នៅជាមួយឪពុកម្តាយ និងជួយធ្វើស្រែចម្ការគាត់។ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្រួសាររបស់ខ្ញុំមានជីវភាពខ្វះខាត។ សម័យនោះភូមិសាទុំមានប្រជាជនប្រមាណ ៣០ទៅ ៤០គ្រួសារ និងមានមនុស្សប្រមាណជាជាង១០០នាក់តែប៉ុណ្ណោះ។ ភូមិសាទុំ ជាតំបន់



កុប ឌី សំឡឹងមើលរូបឧទ្ធម្ភាគចក្រក្នុងអំឡុងពេលផ្តល់បទសម្ភាសន៍ដល់ ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាប់នឹងព្រំដែនជាមួយប្រទេសវៀតណាមដែលមានព្រៃឈើដុះច្រើន ហើយមិនងាយមាននរណាចូលទៅដល់ទេ។ ប្រជាជនទាំងនោះភាគច្រើនមានជីវភាពក្រីក្រ និងមានផ្ទះឈើតូចៗដែលដំបូលនិងជញ្ជាំងបាំងស្លឹកខាន់ម៉ា ចំណែកផ្ទះក្បឿងមានតែមួយខ្នងប៉ុណ្ណោះ។ ប៉ុន្តែបច្ចុប្បន្ន ប្រជាជននៅក្នុងភូមិសាទុំភាគច្រើនមានផ្ទះធំៗ ហើយតំបន់ព្រៃកាលពីសម័យមុនត្រូវបានប្រែក្លាយទៅជាដីចម្ការកៅស៊ូ និងចម្ការដំឡូង។

នៅដើមទសវត្សរ៍៦០ សង្រ្គាមបានកើតឡើងនៅក្នុងប្រទេសវៀតណាម ប៉ុន្តែបានធ្វើឲ្យភូមិខ្មែរមួយចំនួននៅជាប់នឹងព្រំដែនជាមួយប្រទេសវៀតណាមបានរងគ្រោះដោយសារសង្រ្គាមនេះ។ ឌី បានរៀបរាប់បន្តថា ខ្ញុំបានរស់នៅទីនេះតាំងពីតូច និងបានឃើញហេតុការណ៍ជាច្រើនកើតមានឡើងនៅក្នុងភូមិ។ ខ្ញុំបានឃើញកងទ័ពយៀកកុងជាច្រើនរយនាក់មកលាក់ខ្លួននៅក្នុងព្រៃក្នុងទឹកដីខ្មែរ







កុប ឌី រស់នៅឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាពិសេសនៅក្នុងភូមិសាទុំ។ ពេលនោះប្រជាជនភាគច្រើននាំគ្នាទៅទិញអង្ករ និងថ្នាំពេទ្យពីផ្សារក្នុងស្រុកមេមត់មកលក់ឲ្យកងទ័ពយៀកកុង។ ឌីបានស្គាល់ឈ្មោះកងទ័ពយៀកកុងមួយចំនួនដូចជា បាធីក, ទីឡាយ, សៅភុក និង តឹងបាយ៉ ជាដើម។ កងទ័ពយៀកកុងទាំងនោះ ស្លៀកពាក់ខោអាវពណ៌បៃតង។ ទោះបីប្រជាជនរស់នៅភូមិសាទុំលក់អង្ករឲ្យយៀកកុងចំណេញបានប្រាក់ច្រើនយ៉ាងណាក៏ដោយ ក៏រៀងរាល់ថ្ងៃប្រជាជនបារម្ភយន្តហោះមកទម្លាក់គ្រាប់បែក ដែលបណ្តាលឲ្យអ្នកខ្លះស្លាប់ និងរងរបួស ចំណែកព្រៃឈើត្រូវបានឆាបឆេះ។ នៅឆ្នាំ១៩៦៤ មានឧទ្ធម្ភាគចក្ររបស់ទាហានអាមេរិកមួយគ្រឿងបានចុះនៅក្នុងភូមិសាទុំ ចំពីមុខផ្ទះឪដុក។ ចំណែកកងទ័ពយៀកកុងតស៊ូរស់នៅក្នុងព្រៃ និងមិនមានទីតាំងច្បាស់លាស់ទេ ព្រោះខ្លាចយន្តហោះយកការណ៍របស់ទាហានអាមេរិកដឹង បន្ទាប់មកទម្លាក់គ្រាប់បែក។

នៅឆ្នាំ១៩៦៧ ប្រជាជននៅភូមិសាទុំទ្រាំនឹងការទម្លាក់គ្រាប់បែកលែងបានក៏បាននាំគ្នាចាកចេញពីភូមិ។ គ្រួសារខ្ញុំបានភៀសខ្លួនទៅនៅភូមិក្រវៀន ក្នុងឃុំដាំក្រវៀន។ ក្រោយមកក៏មានយន្តហោះទម្លាក់គ្រាប់បែកទៅដល់ភូមិដែលខ្ញុំរស់នៅពេលក្រោយនេះទៀត។ កាលនោះឪពុកម្តាយរបស់ខ្ញុំបានលួនចូលពួនក្នុងលេណដ្ឋានមុន គឺនៅសល់តែខ្ញុំបានចូលលេណដ្ឋានបានដាច់ពាក់កណ្តាលខ្លួន ដូច្នេះខ្ញុំបានឃើញយន្តហោះដោយផ្ទាល់។ ឧទ្ធម្ភាគចក្រកាលនោះមានពីរប្រភេទ ទី១) ឧទ្ធម្ភាគចក្រមានកង់នៅខាងក្រោម និង ទី២) គឺឧទ្ធម្ភាគ-ចក្រដែលមានជើងទម្រពីរនៅខាងក្រោម ដែលអ្នកភូមិរស់នៅទីនេះហៅឈ្មោះថា អាវេវៗ។ យន្តហោះនេះសំកាំងបាញ់ពីលើ បណ្តាលឲ្យប្រជាជនស្លាប់ និងរបួសជាច្រើន។ មានកងទ័ពយៀកកុងម្នាក់ បានរត់ចូលពួនក្នុងលេណដ្ឋានជាមួយប្រជាជនខ្មែរ ខណៈនោះ ទាហានអាមេរិកបានមកដល់ និងបានហៅកងទ័ពយៀកកុងឲ្យចេញមកវិញ ប៉ុន្តែ កងទ័ពយៀកកុងនោះមិនព្រមចេញឡើយ។ ដូច្នេះ ទាហានអាមេរិកបានបោះគ្រាប់បែកចូលក្នុងលេណដ្ឋានបណ្តាលឲ្យស្លាប់ទាំងកងទ័ពយៀកកុង និងប្រជាជនខ្មែរ។ បន្ទាប់មកយន្តហោះ បានមកទម្លាក់គ្រាប់បែកបេ ៥២ កាន់តែច្រើន ធ្វើឲ្យប្រជាជននៅភូមិសាទុំ និងភូមិក្រវៀនបានភៀសខ្លួនទៅរស់នៅកន្លែងផ្សេងៗ។

នៅឆ្នាំ១៩៧០ ខ្ញុំនិងក្រុមគ្រួសារ បានរត់ភៀសខ្លួនទៅរស់នៅភូមិស្អាត ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ។ នៅក្នុងឆ្នាំ១៩៧១ សង្រ្គាមបានកើតឡើងកាន់តែខ្លាំងរវាងទាហាន លន់ នល់ និងកម្លាំងបដិវត្តន៍ខ្មែរក្រហម។ ពេលនោះមានយន្តហោះជាច្រើនគ្រឿងបានមកទម្លាក់គ្រាប់នៅស្រុកស្នួល និងនៅតាមព្រៃ ហើយពេលខ្លះគ្រាប់ទាំងនេះបានធ្លាក់ចំផ្ទះប្រជាជន។ កាលនោះផ្ទះរបស់ខ្ញុំត្រូវបានឆេះអស់ដោយសារយន្តហោះមកទម្លាក់គ្រាប់។ នៅក្នុងឆ្នាំ១៩៧១ ដដែល ខ្ញុំវិលត្រឡប់មករស់នៅភូមិកំណើតនៅភូមិក្តួល ឃុំទន្លូងវិញ ព្រោះខ្ញុំគិតថានៅក្នុងប្រទេសកម្ពុជាទីណាក៏មានសង្រ្គាមដែរ។

នៅឆ្នាំ១៩៧៤ ខ្ញុំ និងក្រុមគ្រួសារបានត្រឡប់មករស់នៅភូមិសាទុំវិញ។ មានថ្ងៃមួយខ្ញុំបានដើរចូលព្រៃខាងក្រោយដែលមានចម្ងាយជាង ៣០០ម៉ែត្រ ពីផ្ទះក៏បានប្រទះឃើញបំណែកឧទ្ធម្ភាគចក្រ ដែលបានធ្លាក់នៅក្រោយផ្ទះរបស់ខ្ញុំ នៅក្នុងទឹកដីរបស់ខ្មែរដែលមានចម្ងាយប្រហែល៣០០ម៉ែត្រពីព្រំដែនវៀតណាម។ ឧទ្ធម្ភាគចក្រនោះមិននៅរូបរាងទាំងមូលទេ ព្រោះមានមនុស្សមកអារយកបំណែកសំខាន់ៗយកទៅអស់ហើយ។ ខ្ញុំបានរើសយកអាលុយមីញ៉ូមខ្លះយកមកទុកនៅក្នុងផ្ទះ។ ខ្ញុំមិនបានឃើញឧទ្ធម្ភាគចក្រនោះធ្លាក់ដោយផ្ទាល់ភ្នែកទេ ពីព្រោះខ្ញុំ និងប្រជាជនបានភៀសខ្លួនទៅនៅភូមិផ្សេងៗ

អស់។ បើតាមខ្ញុំសន្និដ្ឋាន ខ្ទមម្កាគចក្រនេះប្រហែលជាធ្លាក់នៅចុងទសវត្សរ៍៦០ ឬដើមទសវត្សរ៍៧០។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងកាន់អំណាច និងបានបង្ខំឲ្យប្រជាជនរស់នៅជាសហករណ៍ និងមិនមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនឡើយ។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យបង្រៀនអក្សរដល់កុមារតូចៗ។ នៅឆ្នាំ១៩៧៦ អង្គការបានដកខ្ញុំឲ្យទៅភ្ជួរស្រែមួយរយៈ បន្ទាប់មកចាត់តាំងខ្ញុំឲ្យធ្វើជាកងឈ្លបឃុំ ដែលកាលនោះគណៈឃុំជាំក្រវៀនឈ្មោះ តាចឺរ៉ុង, តានួន និង តាឆាយ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ កម្មាភិបាលមកពីមជ្ឈិមបានមកចាប់តាចឺរ៉ុង, តានួន និង តាឆាយ រួមទាំងកម្មាភិបាលខ្មែរក្រហមមួយចំនួនទៀតនៅភូមិភាគបូព៌ា។ មិនយូរប៉ុន្មានខាងមជ្ឈិមបានប្រើ សុង គឺជាយោធាតំបន់២១ ដែលជាអ្នករស់នៅក្នុងស្រុកភូមិជាមួយខ្ញុំឲ្យមកហៅខ្ញុំទៅ ប៉ុន្តែខ្ញុំបានប្រកែក។ ទោះបីយ៉ាងណា សុង នៅតែនាំខ្ញុំទៅខានតែបាន ព្រោះជាបញ្ជារបស់អង្គការ។ ខ្ញុំបានដើរទៅជាមួយ សុង រហូតដល់ល្ងាចយើងបានធ្វើផ្លែមួយក្បាលហូប។ ពេលនោះខ្ញុំមានជំងឺធ្លាក់ឈាមតាមរន្ធគូទ ដូច្នេះ សុង ក៏អនុញ្ញាតឲ្យខ្ញុំត្រឡប់មកភូមិវិញ ហើយចាប់តាំងពេលនោះមកខ្ញុំក៏ឈប់ធ្វើឈ្លបដោយបន្ទំខ្លួនជាមួយប្រជាជនមករស់នៅតាមសហករណ៍វិញ។

នៅឆ្នាំ១៩៧៨ ស្ថានភាពនៅព្រំដែនជាប់ប្រទេសវៀតណាមកាន់តែច្របូលច្របល់ ហើយសង្គ្រាមរវាងខ្មែរក្រហម និងវៀតណាមផ្ទុះឡើងកាន់តែខ្លាំងឡើង។ អង្គការបានជម្លៀសប្រជាជននៅភូមិសាទុំទាំងអស់ឲ្យទៅរស់នៅភូមិស្រែនាម ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ។ ពេលនោះខ្ញុំមិនបានទៅរស់នៅតាមការចាត់តាំងរបស់អង្គការទេ គឺខ្ញុំបានសម្រេចចិត្តរត់ចូលព្រៃលាក់ខ្លួនរយៈពេល១៨យប់១៨ថ្ងៃ។ ខ្ញុំបានជួបកងទ័ពវៀតណាម ហើយកងទ័ពវៀតណាម បានចាប់ខ្ញុំឃុំខ្លួន។ នៅព្រឹកបន្ទាប់អ្នកបកប្រែភាសាខ្មែរ បានមកដល់ប្រាប់ឲ្យខ្ញុំរៀបចំអីវ៉ាន់ចេញទៅប្រទេសវៀតណាម ព្រោះកងទ័ពវៀតណាមគិតថា ខ្ញុំជាយោធាខ្មែរក្រហម។ ខ្ញុំបានប្រាប់អ្នកបកប្រែភាសាថា ខ្ញុំមិនមែនជាយោធាខ្មែរក្រហមទេ ហើយកងទ័ពវៀតណាមក៏ជឿខ្ញុំ។

នៅឆ្នាំ១៩៧៩ ខ្ញុំត្រឡប់មកស្រុកខ្មែរវិញ និងបានចូលធ្វើកងទ័ពក្នុងអង្គភាពរបស់សម្តេច ហ៊ុន សែន។ នៅឆ្នាំ១៩៧៩ ខ្ញុំនៅប្រចាំការនៅម្តុំភ្នំប្រុសភ្នំស្រី ហើយពេលនោះ យោធាខ្មែរក្រហមបានឡើងមកវាយឆ្មក់ជាញឹកញាប់។ ពេលនោះជំងឺចាស់របស់ខ្ញុំបានរើឡើងវិញ ខ្ញុំក៏មកសម្រាក់នៅមន្ទីរពេទ្យកំពង់ចាម។ នៅពេលជាសះស្បើយពីជំងឺវិញ ខ្ញុំក៏បានត្រឡប់ទៅអង្គភាពវិញ ប៉ុន្តែអង្គភាពរបស់ខ្ញុំបានផ្លាស់ចេញទៅហើយ។ ដោយខ្ញុំដើររកអង្គភាពមិនឃើញ ខ្ញុំក៏បានត្រឡប់មករស់នៅស្រុកកំណើតប្រកបមុខរបរធ្វើស្រែចម្ការ។ ពេលនោះនៅភូមិរបស់ខ្ញុំមិនសូវមានប្រជាជនរស់នៅទេ ពីព្រោះប្រជាជនត្រូវបានខ្មែរក្រហមសម្លាប់ស្ទើរអស់ទៅហើយ។ ខ្ញុំបានដើររកប្រពន្ធនៅភូមិជេង និងបានរៀបការនៅឆ្នាំ១៩៨១។



កុប ឌី ចង្អុលបង្ហាញទីតាំងធ្លាក់ខ្ទមម្កាគចក្រក្នុងអំឡុងពេលផ្តល់បទសម្ភាសន៍ដល់ ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងទិសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!























# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ារដ្ឋ មេត្តា

(តពីលេខមុន)



រូបថតជនរងគ្រោះ និងខ្នោះ នៅអតីតមន្ទីរសន្តិសុខស-២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**១៦៥.** ចំពោះការជំទាស់ដែលនៅសេសសល់ អង្គជំនុំជម្រះយល់ឃើញថា ការជំទាស់ឃើញថា ការជំទាស់ទាំងអស់នោះ គឺជាការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ក្នុងការវិនិច្ឆ័យទៅលើអង្គហេតុមួយចំនួន។ ហេតុដូច្នេះ អញ្ញត្រកម្មទាំងនោះគួរត្រូវបានដាក់តាមពេលវេលាកំណត់ ផ្អែកលើវិធាន ៨៩ នៃវិធានផ្ទៃក្នុង។ សំណើរទាំងនោះត្រូវបានលើកឡើងក្រោយពេលវេលាកំណត់នេះ ដូច្នេះសំណើរទាំងនេះត្រូវបដិសេធចោលដោយសារតែមានភាពយឺតយ៉ាវ។

**២.៥.៦.៣.៣** ការចោទប្រកាន់ស្តីពីការនិរទេសជនជាតិវៀតណាម

**១៦៦.** ពីដំបូងឡើយ អង្គជំនុំជម្រះកត់សម្គាល់ថា កម្រិតនៃការរៀបរាប់លម្អិត ត្រូវមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងនៅក្នុងដីកាដំណោះស្រាយចំពោះការបង្ហាញអង្គហេតុដែលត្រូវបានស៊ើបសួរ ឬវិនិច្ឆ័យមានកម្រិតខុសគ្នា។ ត្រង់ចំណុចនេះអង្គបុរេជំនុំជម្រះបានសម្រេចថា «នៅពេលមានតែសេចក្តីសង្ខេបនៃអង្គហេតុនិងប្រភេទនៃបទល្មើស ត្រូវបានកំណត់នៅដំណាក់កាលនៃដីកាលសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ការពិពណ៌នាអំពីអង្គហេតុសត្យានុម័ត និងការកំណត់លក្ខណៈគតិយុត្តិរបស់វា ត្រូវបានកំណត់លក្ខខណ្ឌនៅក្នុងដីកាដំណោះស្រាយ» ។

**១៦៧.** ដើម្បីយល់អំពីវិសាលភាពនៃអង្គហេតុជាក់លាក់ ដែលសហព្រះរាជអាជ្ញាបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះត្រូវពិចារណាទៅលើអង្គហេតុដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយផ្អែកលើឯកសារគាំទ្រទាំងអស់ដែលបានយោងនៅក្នុងជើងទំព័រ ឬនៅក្នុងឧបសម្ព័ន្ធ។ អង្គជំនុំជម្រះកត់សម្គាល់ថា «ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីកថាខណ្ឌ ១ ដល់ ១០៥ រួមមានភស្តុតាងជាសម្រង់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកា សន្និដ្ឋាននេះ» និង «ឧបសម្ព័ន្ធ គ ដែលជាឧបសម្ព័ន្ធនៃឯកសារដទៃទៀត ដែលសហព្រះរាជអាជ្ញា មានមូលហេតុក្នុងការជឿជាក់ថា គាំទ្រទៅដល់ការចោទប្រកាន់ដែលបានធ្វើឡើងនៅក្នុងសារណា នេះ»។

**១៦៨.** យោងតាមកថាខណ្ឌ ១២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ «ប.ក.ក.បានអនុវត្តការរើសអើងមានលក្ខណៈជាប្រព័ន្ធប្រឆាំងនឹងក្រុមដែលជាគោលដៅនានារួមទាំង៖ [...]ជនជាតិវៀត ណាមនិង «វិសាលភាពនៃការរើសអើងដែលមានលក្ខណៈជាប្រព័ន្ធ» ត្រូវបានបង្ហាញតាមរយៈ «អំពើឧក្រិដ្ឋកម្មទាំងអស់នេះ» ដូចជា «បក្សកុម្មុយនីស្តកម្ពុជាបានបន្តធ្វើនយោបាយ រើសអើងប្រឆាំង និងសម្លាប់ជនជាតិវៀតណាម»។ ក្នុងចំណោមឯកសារដែលសហព្រះរាជអាជ្ញាសំអាងទៅលើ ទាំងនៅក្នុងជើងទំព័រនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬនៅក្នុងឧបសម្ព័ន្ធ បានផ្តល់នូវភស្តុតាងដែលបានគាំទ្រដល់អង្គហេតុដែលត្រូវបានចោទប្រកាន់ និងស្ថិតក្រោមកិច្ចស៊ើបសួរនោះ មានការយោងទៅឯកសារចំនួនពីរជាច្រើន។ ឯកសារទីមួយគឺ សៀវភៅដែលបានបោះពុម្ពដោយនាយកដ្ឋានសារព័ត៌មាន និងព័ត៌មានរបស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើង «សៀវភៅខ្មៅ» ហេតុការណ៍ និងភស្តុតាងនានានៃអំពើឈ្លានពាន និងវាតទីទឹកដីរបស់វៀតណាមប្រឆាំងកម្ពុជា («សៀវភៅខ្មៅ»)។ ឯកសារទីពីរគឺ សៀវភៅដែលនិពន្ធឡើងដោយ Ben KIERNAN ដែលមានចំណងជើងថា «របប ប៉ុល ពត ៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍»។ ឯកសារទាំងពីរមិនគ្រាន់តែត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានវិភាគផងដែរនៅក្នុងលិខិតក្រមឯកសារ D3/TV ហើយត្រូវបានបង្ហាញថាមានការចោទប្រកាន់ដែល «ជួយដល់ការបង្ហាញថា មានការចោទប្រកាន់ដែលជួយដល់ការបង្ហាញភស្តុតាង» នៃចេតនារើសអើងប្រឆាំងជនជាតិវៀតណាមដែលត្រូវទទួលរងការផ្លាស់ទីដោយបង្ខំ។ ជាងនេះទៀត មានការយោងយ៉ាងច្បាស់ទៅគោលនយោបាយ «បណ្តេញ» ជនជាតិវៀតណាមដែលរស់នៅលើទឹកដីកម្ពុជា។ ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានបញ្ជាក់យ៉ាងច្បាស់ថា ការចោទប្រកាន់ផ្អែកអង្គហេតុផ្តល់ជាការជូនដំណឹងគ្រប់គ្រាន់ទៅជនជាប់ចោទថា សហចៅក្រមស៊ើបអង្កេតនឹងធ្វើការស៊ើបសួរទៅលើអង្គហេតុដែលបានប្រព្រឹត្តឡើង ដើម្បីជំរុញគោលនយោបាយរបស់ ប.ក.ក. ក្នុងការរើសអើងប្រឆាំងនឹងជនជាតិវៀតណាម រួមទាំងជម្រះច្រានចោលអំណះអំណាងរបស់មេធាវីការពារក្តី ខៀវ សំផន ដែលថាអង្គហេតុនៃការនិរទេសមិនស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការ។

**២.៥.៦.៣.៤.** ការចោទប្រកាន់ស្តីពីការនិរទេសនៅសហករណ៍ត្រាំកក់

**១៦៩.** មេធាវីការពារក្តី ខៀវ សំផនបានលើកឡើងផងដែរថា អង្គជំនុំជម្រះបានបំបែកការចោទប្រកាន់ស្តីពីការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅសហករណ៍ត្រាំកក់ ចេញពីសំណុំរឿង០០២/០២។

ជាការគាំទ្រ មេធាវីការពារក្តី ខៀវ សំផន បានដកស្រង់នូវប្រយោគក្នុងរង្វង់ក្រចកជាភាសាបារាំង នៃឧបសម្ព័ន្ធរបស់ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿង ០០២ ដែលបញ្ជាក់ថា ការនិរទេសត្រូវបានចោទប្រកាន់ ដោយកម្រិតត្រឹមតែខេត្តព្រៃវែង និងស្វាយរៀង (ដោយលុបចោលការយោងទៅសហករណ៍ត្រាំងកក់)។ អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារជាភាសាអង់គ្លេស និងភាសាខ្មែរនៃឧបសម្ព័ន្ធបញ្ជាក់ថាការចោទប្រកាន់ស្តីពីការរិរទេសនៅសហករណ៍ត្រាំងកក់ ត្រូវបានបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០។ ចំណុចនេះបានបង្ហាញយ៉ាងច្បាស់ថា ឯកសារបកប្រែជាភាសាបារាំង នៅត្រង់ចំណុចនេះមានកំហុស។ លើសពីនេះទៀតឧបសម្ព័ន្ធទាំងបីភាសារួមទាំង ការយោងទៅលើកថាខណ្ឌ ១៣៩៧ នៃដីកាដំណោះស្រាយ ដែលបានបញ្ចូលការចោទប្រកាន់ស្តីពីការនិរទេសនៅសហករណ៍ត្រាំងកក់។ ដោយបានកត់សម្គាល់ថាមេធាវីការពារក្តី ខៀវ សំផន អាចលើកឡើងពីសភាពមិនស៊ីចង្វាក់គ្នានេះ នៅពេលណាមួយ ចាប់តាំងពីពេលដែលអង្គជំនុំជម្រះបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី នៅខែមេសា ឆ្នាំ២០១៤ មកនោះ អង្គជំនុំជម្រះមិនជឿថា ភាពអយុត្តិធម៌មិនត្រូវបានកើតឡើងដោយសារតែកំហុសក្នុងឧបសម្ព័ន្ធជាភាសាបារាំងនេះនោះទេ។

**២.៥.៦.៤.** ការជូនដំណឹងអំពីការចោទប្រកាន់ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

**១៧០.** យោងតាមដីកាដំណោះស្រាយ ប.ក.ក. បានបង្កើតនិងអនុវត្តគោលនយោបាយអប់រំ «សមាសភាពមិនល្អ» និងសម្លាប់ «ខ្មាំង» ទាំងនៅខាងក្នុង និងខាងក្រៅជួរបក្ស។ ជាមួយគ្នានេះផងដែរ ដីកាដំណោះស្រាយក៏បានបង្ហាញថា ប.ក.ក. បានកំណត់ក្រុមមួយចំនួនថាជា «ខ្មាំង» ដែលត្រូវបានធ្វើទុក្ខបុកម្នេញដោយមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬដោយការសន្មត់របស់ក្រុមនោះ ឬដោយមូលហេតុនៃការប្រឆាំងទៅនឹងនយោបាយរបស់ ប.ក.ក.។ ទាក់ទិនចំណុចនេះ ដីកាដំណោះស្រាយលើកយកក្រុមចំនួនបីធ្វើជាឧទាហរណ៍ ដោយមិនរួមបញ្ចូលក្រុមទាំងអស់ (ដោយប្រើពាក្យ«ដូចជា»)៖ (១) អតីតអ្នករដ្ឋការស៊ីវិល និងទាហាននៃរបបសាធារណរដ្ឋខ្មែរ (២)«ប្រជាជនថ្មី» ឬ «ប្រជាជន១៧ មេសា» និង (៣) បញ្ញវន្ត និស្សិត និង



អដ្ឋិធាតុជនរងគ្រោះនៅអតីតមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានថែរក្សា និងគោរពបូជា បន្ទាប់ពីរបបខ្មែរក្រោមដួលរលំ នៅខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





អ្នកការទូតដែលរស់នៅបរទេសត្រូវបានអំពាវនាវឲ្យត្រឡប់ចូលប្រទេសកម្ពុជាវិញ។ ដូចជាលើកឡើងក្នុងដីកាដំណោះស្រាយ មិនមែនមានតែក្រុមចំនួនបីនេះទេដែលត្រូវបានកំណត់ថាជាខ្មាំងនោះឡើយ ហើយសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងបញ្ហានេះត្រូវបានបដិសេធចោល។ ក្នុងករណីចាំបាច់ អង្គជំនុំជម្រះនឹងដោះស្រាយលើការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន អំពីក្រុមខ្មាំងជាក់លាក់ ដែលដីកាដំណោះស្រាយបានកំណត់នៅតាមឧក្រិដ្ឋកម្មនីមួយៗនៅក្នុងផ្នែកសំអាងច្បាប់ដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មទាំងនោះ។

**១៧១.** មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា រាល់បទចោទពាក់ព័ន្ធនឹងការប្រព្រឹត្តប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងគោលនយោបាយកំណត់ក្រុមនេះថា ជាគោលដៅមិនមានភាពច្បាស់លាស់នោះទេ ហើយការកំណត់បទចោទបែបនេះធ្វើឲ្យមានការរំលោភបំពានដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជូនដំណឹងភ្លាមអំពីបទចោទប្រឆាំងនឹងខ្លួន។ មេធាវីការពារក្តី នួន ជា កត់សម្គាល់ថា ក្រុមគោលដៅជាជនជាតិវៀតណាម ជនជាតិចាម និងពុទ្ធសាសនិកត្រូវបានពិភាក្សាដាច់ដោយឡែកពីគ្នានៅក្នុងផ្នែក VIII-ឃ («សំអាងហេតុពាក់ព័ន្ធនឹងបទឧក្រិដ្ឋនានា» ក្រោមទម្រង់នៃ«ការប្រព្រឹត្តទៅលើក្រុមជាក់លាក់») ប៉ុន្តែអតីតទាហាននិងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមិនត្រូវបានលើកយកមកពិភាក្សាដោយឡែកនៅក្នុងផ្នែកជាក់លាក់នៅក្នុងដីកាដំណោះស្រាយទាំងនោះទេ។ មេធាវីការពារក្តី នួន ជា បន្ថែមទៀតថាផ្នែក VI-ក នៃដីកាដំណោះស្រាយ («សំអាងហេតុពាក់ព័ន្ធនឹងការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួមគ្នា») មិនរួមបញ្ចូលការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅលើក្រុមគោលដៅជាអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានចោទប្រកាន់ទៅទីតាំងឧក្រិដ្ឋកម្មចំនួន ៤កន្លែងគឺ (សហករណ៍ត្រាំងកក់ ការដ្ឋានការងារទំនប់ ១មករា មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់) ប៉ុន្តែមេធាវីការពារក្តី នួន ជា បានអះអាងថា វាមានភាពច្បាស់លាស់ថាតើផ្នែកនៃអង្គហេតុជាក់លាក់ណាខ្លះដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបជាក់លាក់ណាខ្លះ ដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ តើគោលនយោបាយណាខ្លះត្រូវបានចោទប្រកាន់ឬថាតើបទចោទអ្វីខ្លះត្រូវបានកំណត់សម្រាប់អង្គហេតុនេះ។ ភាគីផ្សេងទៀតមិនបានធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហានេះទេ។

**១៧២.** អង្គជំនុំជម្រះរម្លឹកថា វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងចែងថា ក្នុងចំណោមសិទ្ធិផ្សេងៗទៀត ជនជាប់ចោទមានសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួន។ អង្គជំនុំជម្រះឃើញថា ការចោទប្រកាន់ត្រូវបានកំណត់ដោយផ្អែកលើទាំងអង្គហេតុជាមូលដ្ឋាននិងការកំណត់ដោយច្បាប់។

**១៧៣.** ដីកាដំណោះស្រាយនឹងត្រូវបានយកមកពិនិត្យជារួម នៅពេលកំណត់បទចោទប្រកាន់ និងអង្គហេតុគាំទ្រជាមូលដ្ឋាន។ ចំណុចថា តើបទចោទប្រកាន់នានាពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការស៊ីវិល និងទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវធ្វើឡើងដោយរបៀបណា ដើម្បីឲ្យមានភាពជាក់លាក់គ្រប់គ្រាន់ និងដើម្បីជៀសវាងការប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ក្នុងការការពារក្តីយ៉ាងមានប្រសិទ្ធភាពគឺតម្រូវផ្អែកមួយផ្នែក ទៅលើបញ្ហាថាតើអង្គហេតុដែលត្រូវបានចោទប្រកាន់ទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងសំណុំរឿង ០០២/០២ ដូចជា សហករណ៍ត្រាំងកក់ ការរដ្ឋានការងារទំនប់ ១ មករា មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ត្រង់ផ្នែកពាក់ព័ន្ធនៅក្នុងសាលក្រម អង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនានា ដែលត្រូវយកមកចោទប្រកាន់ពាក់ព័ន្ធនឹងទីតាំងនេះមានភាពជាក់លាក់គ្រប់គ្រាន់។

**១៧៤.** ស្រដៀងគ្នានេះ ដីកាដំណោះស្រាយក៏បានលើកឡើងយ៉ាងច្បាស់លាស់ គោលនយោបាយប្រឆាំងនឹងអតីតអ្នករដ្ឋការស៊ីវិល និងទាហាននៃរបបសាធារណរដ្ឋខ្មែរពិតជាមានអត្ថិភាពនៅតាមទីតាំងឧក្រិដ្ឋកម្មនេះ។ ផ្អែកលើមូលដ្ឋាននេះ ដីការដំណោះស្រាយបានចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ដីការដំណោះស្រាយបានលើកឡើងថា គោលនយោបាយនេះមានអត្ថិភាពនៅមុនឆ្នាំ ១៩៧៥ ហើយបានបន្តយ៉ាង

ហោចណាស់រហូតដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៩ ហើយមានការចាប់ខ្លួន ឬយកទៅសម្លាប់សមាជិកក្រុមនេះ ដើម្បីទប់ស្កាត់ពួកគេមិនឲ្យរៀបចំ «ការវិលត្រឡប់មកប្រឆាំងនឹងបដិវត្តន៍វិញ»។ គោលនយោបាយនេះ គឺជាផ្នែកមួយនៃគោលបំណងរួម។ ដីកាដំណោះស្រាយលើកឡើងយ៉ាងច្បាស់ទៀតថា ក្រុមនេះត្រូវបានកំណត់គោលដៅ «នៅទូទាំងប្រទេសកម្ពុជា» រួមទាំងនៅតាមទីតាំងឧក្រិដ្ឋកម្មចំនួន ៤កន្លែង នៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ផងដែរ។

**១៧៥.** ដូចដែលមេធាវីការពារក្តី នួន ជា បានសន្និដ្ឋាន «ការទទួលខុសត្រូវក្រោមទម្រង់នៃការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម» នៅក្នុងដីកាដំណោះស្រាយ មិនបានបញ្ចូលការធ្វើទុក្ខបុកម្នេញនៅលើអតីតអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរនោះឡើយ។ ទោះបីយ៉ាងណាអង្គជំនុំជម្រះកត់សម្គាល់ថា ដីកាដំណោះស្រាយបានចែងយ៉ាងច្បាស់ថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ តាមរយៈការប្រព្រឹត្តចំពោះអតីតទាហាន និងអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរត្រូវបានចោទប្រកាន់នៅក្នុងទីតាំងឧក្រិដ្ឋកម្មចំនួន ៤កន្លែងដែលបានរៀបរាប់ខាងលើ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ខ្លួនបានទទួលយកការចោទប្រកាន់ទាំងនេះបានត្រឹមត្រូវហើយ ភាគីនានាក៏បានទទួលនូវការជូនដំណឹងអំពីបទចោទប្រកាន់ទាំងនេះរួចមកហើយដែរ។

**១៧៦.** ផ្អែកលើសំអាងហេតុទាំងនេះ អង្គជំនុំជម្រះច្រានចោលសេចក្តីសន្និដ្ឋានរបស់មេធាវី ការពារក្តី នួន ជា ដែលជាការចោទប្រកាន់នានា ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមិនមានភាពជាក់លាក់។

**២.៥.៦.៥.** ការជូនដំណឹងអំពីការចោទប្រកាន់ពាក់ព័ន្ធនឹងគោលនយោបាយទូទាំងប្រទេសចំពោះការប្រព្រឹត្តទៅលើពុទ្ធសាសនិក

**១៧៧.** មេធាវីការពារក្តី នួន ជា បានលើកឡើងថាបទចោទពាក់ព័ន្ធនឹងការកំណត់គោលដៅទៅលើពុទ្ធសាសនិក គឺកំណត់ត្រឹមសហករណ៍ត្រាំកក់ ដូច្នេះហើយការផ្តន្ទាទោសណាមួយទៅលើបទចោទទាំងអស់នេះ ត្រូវតែផ្អែកទៅលើភ័ស្តុតាងពីទីតាំងឧក្រិដ្ឋកម្មនេះ។ ទោះបីជាអង្គជំនុំជម្រះទទួលយកភ័ស្តុតាងនៃការប្រព្រឹត្តចំពោះពុទ្ធសាសនិក ដែលស្ថិតនៅក្រៅសហករណ៍ត្រាំកក់ ដោយសារតែការជាប់ពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់ពីគោលនយោបាយទូទាំងប្រទេសក្តី តែមេធាវីការពារក្តី នួន ជា បានលើកឡើងថាភ័ស្តុតាងនេះមិនអាចត្រូវបានប្រើប្រាស់សម្រាប់គាំទ្រដល់ការផ្តន្ទាទោសឡើយ ព្រោះ នួន ជា មិនបានទទួលដំណឹងការដាក់បញ្ចូលទីតាំងដល់ការផ្តន្ទាទោសឡើយ ព្រោះ នួន ជា មិនបានទទួលការជូនដំណឹងអំពីទីតាំងការដាក់បញ្ចូលទីតាំងភូមិសាស្ត្រដទៃទៀតនៅក្នុងដីកាដំណោះស្រាយទេ។

**១៧៨.** អង្គជំនុំជម្រះរម្លឹកថា នៅពេលបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានស្រេចថា «ការបញ្ចូលការចោទប្រកាន់ទូទៅដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិក និងសហករណ៍ត្រាំកក់ជាឧទាហរណ៍មួយនៃទីតាំងឧក្រិដ្ឋកម្មដែលឆ្លុះបញ្ចាំងសមស្របនូវទំហំ និងចរិតលក្ខណៈនៃអំពើនានាដែលត្រូវបានចោទប្រកាន់ ដើម្បីធានាឲ្យមានសវនាការមួយប្រកបដោយប្រសិទ្ធភាពចំពោះប្រធានបទនេះ»។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនពង្រីកការប្រព្រឹត្តចំពោះពុទ្ធសាសនិក នៅក្នុងវិសាលភាពទូទាំងប្រទេសនោះទេ។ ស្របជាមួយនឹងសេចក្តីសម្រេចនេះ និងដោយមានការជូនដំណឹងអំពីបទចោទទៅកាន់ភាគីនានានោះ អង្គជំនុំជម្រះអាចមិនធ្វើការផ្តន្ទាទោសជនជាប់ចោទពីការប្រព្រឹត្តចំពោះពុទ្ធសាសនិកដែលអាចកើតឡើងនៅក្រៅស្រុកត្រាំកក់ឡើយ។

**២.៥.៦.៦.** ការដកចេញពីវិសាលភាពនៃការជំនុំជម្រះចំពោះបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ ប៉ុន្តែមិនមានភ័ស្តុតាងគ្រប់គ្រាន់គាំទ្រដល់ការបញ្ជូនរឿងទៅជំនុំជម្រះ

**១៧៩.** មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា ដើម្បីជៀសវាងការដកហូតសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានឧបាស្រ័យប្រកបដោយប្រសិទ្ធភាព ចំពោះកំហុសផ្នែកនីតិវិធីទាំងអស់ដែលប៉ះពាល់ដល់ដីកាដំណោះស្រាយ អង្គជំនុំជ្រះសាលាដំបូងគួរពិចារណាទៅលើអំណះអំណាងរបស់មេធាវីការពារក្តី អំពីការដែលសហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអង្គហេតុដែលអាចគាំទ្រដល់បទចោទផ្សេងៗនៅក្នុងកម្រិតមួយដែលចាំបាច់សម្រាប់ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ហើយត្រូវមោឃភាពផ្នែកខ្លះនៃដីកាដំណោះស្រាយទាក់ទងនឹងបទចោទដែលត្រូវបានបង្ហាញដោយមិនគ្រប់គ្រាន់ ដើម្បីអាចបញ្ជូនសំណុំរឿងទៅជំនុំជម្រះបាន។

**១៨០.** អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនមិនច្បាស់លាស់ទេថា តើមេធាវីការពារក្តីយោងទៅបទចោទដែលមានកង្វល់ចន្លោះណាមួយឲ្យប្រាកដ ហើយថាតើអង្គជំនុំជម្រះបានទទួលបណ្តឹងតវ៉ាពាក់ព័ន្ធនឹងវិការៈដែលរងការចោទប្រកាន់នេះដែរឬទេ។ ដោយសារតែមិនមានការបញ្ជាក់ភ័ស្តុតាងបន្ថែមទៀត ដូច្នេះការតវ៉ាទាំងអស់នេះត្រូវបដិសេធចោល។

**២.៥.៦.៧.** អង្គហេតុដែលត្រូវបានចោទប្រកាន់ដែលនៅក្រៅវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ

**២.៥.៦.៧.១.** ខ្មែរក្រហម

**១៨១.** មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា បានលើឡើងថា អង្គជំនុំជម្រះមិនដែលបានទទួលអង្គហេតុទាក់ទងនឹងការប្រព្រឹត្តចំពោះក្រុមជនជាតិភាគតិចខ្មែរក្រោមទេ ដោយសារតែបទចោទនេះមិនមែនជាផ្នែកមួយនៃដីកាដំណោះស្រាយឡើយ ដោយមានការកត់សម្គាល់ជាក់លាក់ក្នុងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបនិងអង្គជុំនុំជម្រះ អំពីវិសាលភាពនៃកិច្ចស៊ើបសួរសំណុំរឿង០០២។ មេធាវីការពារក្តី នួន ជា ក៏បានលើកឡើងផងដែរថាការប្រព្រឹត្តទៅលើខ្មែរកម្ពុជាក្រោមមិនអាចចាត់ទុកថាជាផ្នែកមួយនៃការចោទប្រកាន់ទាក់ទងទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាមឡើយ ព្រោះខ្មែរក្រោមមិនមែនជាវៀតណាមតាមសញ្ជាតិ ជាតិពន្ធុ ឬក្រុមពូជសាសន៍នោះទេ។

**១៨២.** ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីបទប្រល័យពូជសាសន៍លើ «បុគ្គលដែលជាសមាជិកនៃក្រុមជនជាតិវៀតណាម (ក្រុមជាតិពន្ធុ និងក្រុមជនជាតិជាក់លាក់ដែលត្រូវបានចាត់ទុក ដូចជា ក្រុមពូជសាសន៍ដោយបក្សកុម្មុយនីស្តកម្ពុជា)» នៅទូទាំង



បរិវេណអតីតមន្ទីរសន្តិសុខក្រាំងតាចាន់ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រទេសកម្ពុជា។ ដីកាដំណោះស្រាយ ក៏បានចោទប្រកាន់ជនជាប់ចោទពីការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និង ការធ្វើទុក្ខបុកម្នេញទៅលើជនជាតិវៀតណាម នៅតាមទីតាំងមួយចំនួននៅទូទាំងប្រទេសកម្ពុជា។ ទោះបីជាភ័ស្តុតាងទាក់ទងនឹងខ្មែរក្រោមត្រូវបានពិភាក្សាជាច្រើនលើកនៅក្នុងដីកាដំណោះស្រាយ ជាពិសេសទាក់ទងនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាមក្តី ប៉ុន្តែខ្មែរកម្ពុជាក្រោមមិនជាមូលដ្ឋានឯករាជ្យមួយសម្រាប់បទចោទនានា នៅក្នុងសំអាងច្បាប់នៃដីកាដំណោះស្រាយឡើយ។

**១៨៣.** ជាលទ្ធផល ជាការឆ្លើយតបចំពោះសំណើរសុំឲ្យធ្វើការសម្រេចថា តើភ័ស្តុតាងនៃការប្រព្រឹត្តទៅលើខ្មែរកម្ពុជាក្រោម ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ដែរឬទេនោះ អង្គជំនុំជម្រះបានសម្រេចថា៖

១). សំណុំរឿង ០០២/០២ មិនបញ្ចូលការចោទប្រកាន់ទាក់ទងនឹងការកំណត់គោលដៅទៅលើខ្មែរ

ក្រោមថាជាក្រុមជាក់លាក់មួយនោះទេ ពោលគឺ ការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញ ដែលជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម។ គ្មានភាគីណាមួយបានស្នើសុំឲ្យកំណត់សាជាថ្មីទៅលើការចោទប្រកាន់ចំពោះអង្គហេតុណាមួយ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដើម្បីបញ្ចូលបទចោទនៃការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោមថា ជាក្រុមមួយដោយឡែកពីគេនោះឡើយ។

២). អង្គជំនុំជម្រះ នឹងធ្វើការពិចារណាទៅលើភស្តុតាងករណីនីមួយៗ ដោយផ្អែកតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.។ ជាគោលការណ៍ ក្នុងករណីភស្តុតាងដែលបានស្នើឡើង ឬដែលបានពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះ ជាប់ពាក់ព័ន្ធតែទៅនឹងការកំណត់គោលដៅទៅលើខ្មែរក្រោម ហើយដែលពាក់ព័ន្ធតែជាមួយនឹងការបង្កើតធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍លើខ្មែរក្រោមទេនោះ អង្គជំនុំជម្រះយល់ថា បញ្ហានេះមិនពាក់ព័ន្ធ ហើយនឹងមិនអនុញ្ញាតឲ្យធ្វើការដេញដោលឡើយ។

៣). ទោះជាយ៉ាងនេះក្តី ភស្តុតាងដែលទាក់ទងនឹងខ្មែរក្រោមអាចជាប់ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀតនៅក្នុងសំណុំរឿង០០២/០២ ដូចជា បរិបទប្រវត្តិសាស្ត្រ និងគោលនយោបាយ ឬបទល្មើសដទៃទៀតដែលត្រូវបានចោទប្រកាន់ និងជនរងគ្រោះមួយចំនួនគឺជាខ្មែរក្រោម។ ក្នុងករណីនេះ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យធ្វើការដេញដោលបាន ក៏ប៉ុន្តែអង្គជំនុំជម្រះស្នើឲ្យភាគីផ្តោតជាចម្បងទៅលើការដេញដោលភស្តុតាង ដែលជាប់ពាក់ព័ន្ធខ្លាំងបំផុតទៅលើការចោទប្រកាន់ចំពោះអង្គហេតុនានានៅក្នុងសំណុំរឿង០០២/០២។ អង្គជំនុំជម្រះនឹងមិនបដិសេធនូវសក្តីកម្មករបស់សាក្សីឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មថា បុគ្គលម្នាក់ជាខ្មែរក្រោមទេ ពីព្រោះសក្ខីកម្មនេះទាក់ទងនឹងបញ្ហាដទៃទៀតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ ប៉ុន្តែ ចំណុចនេះពុំគួរជាចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់នៃការតាំងសំណួររបស់មេធាវីការពារក្តីឡើយ ព្រោះថាការកំណត់គោលដៅទៅលើខ្មែរក្រោម មិនត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងក្តីនេះទេ។

**១៨៤.** ស្របជាមួយនឹងសេចក្តីសម្រេចនេះ ក្រោយមកអង្គជំនុំជម្រះបានសម្រេចថា « ទោះបីជាភស្តុតាងទាក់ទិននឹងខ្មែរក្រោមមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿងនេះយ៉ាងណាក៏ ដោយតែបញ្ហាជាក់លាក់ទៅនឹងការចោទប្រកាន់នៃការធ្វើទុក្ខបុកម្នេញលើក្រុមគោលដៅជាក់លាក់នោះ វាស្ថិតក្រៅវិសាលភាពនៃសំណុំរឿង០០២/០២» ហើយថា «ភស្តុតាងពីខ្មែរក្រោមអាចពាក់ព័ន្ធជាមួយបញ្ហាផ្សេង ក្រៅពីការធ្វើទុក្ខបុកម្នេញទៅលើខ្មែរក្រោមជាក្រុមជាក់លាក់មួយ ដូច្នេះហើយភស្តុតាងបែបនេះអាចទទួលបាន»។ អង្គជំនុំជម្រះទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទាក់ទងនឹងការប្រព្រឹត្តទៅលើខ្មែរក្រោម ដោយសារតែកំណត់ហេតុទាំងនោះមានភាពពាក់ព័ន្ធជាមួយនឹងបរិបទនយោបាយនឹងប្រវត្តិសាស្ត្រ ឬ «ឧក្រិដ្ឋកម្មដ៏ទៃទៀតដែលត្រូវបានចោទប្រកាន់»។ អង្គជំនុំជម្រះក៏បានស្តាប់សក្ខីកម្មទាក់ទងនឹងការប្រព្រឹត្តទៅលើខ្មែរក្រោមផងដែរ។

**១៨៥.** អង្គជំនុំជម្រះកត់សម្គាល់ថា ទឡ្ហីករណ៍ទាំងអស់បានលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន ត្រូវបានដោះស្រាយនៅក្នុងសេចក្តីសម្រេចផ្សេងៗកន្លងមករបស់អង្គជំនុំជម្រះហើយក៏បានបញ្ជាក់សាជាថ្មីនៅក្នុងសេចក្តីសម្រេចនេះដែរ។ ដីកាដំណោះស្រាយមិនបានកំណត់ថាខ្មែរក្រោមគឺជាក្រុមមួយនៃជនជាតិវៀតណាមនោះឡើយ ដូច្នេះហើយ មេធាវីការពារក្តីមិនត្រូវបានជូនដំណឹងឲ្យបានគ្រប់គ្រាន់ថា ការចោទប្រកាន់នានាពាក់ព័ន្ធនឹងខ្មែរក្រោមមួយដែលអាចជាផ្នែកមួយនៃបទចោទប្រកាន់នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ថា អង្គជំនុំជម្រះមិនទទួលបានការកំណត់គោលដៅលើខ្មែរក្រោមថា ជាក្រុមជាក់លាក់ ឬជាក្រុមមួយរបស់ជនជាតិវៀតណាមឲ្យបានត្រឹមត្រូវនៅឡើយទេ។

**២.៥.៦.៧.២.** ការរំលោភផ្លូវភេទនៅក្រៅពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ





**១៨៦.** មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះមិនដែលបានទទួលការចោទប្រកាន់អំពីការរំលោភផ្លូវភេទក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ ដូច្នេះអង្គជំនុំជម្រះមិនអាចពិចារណាលើភស្តុតាងនៃការរំលោភផ្លូវភេទថា មានការពាក់ព័ន្ធនឹងបទចោទណាមួយនៅក្នុងដីកាដំណោះស្រាយឡើយ។ មេធាវីការពារក្តីបានលើកបញ្ហាពិសេសនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ដែលក្នុងសេចក្តីសម្រេចនោះអង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះពិចារណាលើភស្តុតាងនៃការរំលោភផ្លូវភេទ ប្រសិនបើភស្តុតាងនោះមិនត្រូវបានលើកមកពិចារណាសម្រាប់ឧក្រិដ្ឋកម្មជាក់លាក់នោះ។ មេធាវីការពារក្តីបានលើកឡើងថា ការចាត់ទុកអំពើរំលោភផ្លូវភេទបទល្មើសឡើងវិញចំពោះអង្គហេតុដែលអង្គជំនុំជម្រះមិនបានទទួល។

**១៨៧.** អង្គជំនុំជម្រះបានសម្រេចស្របគ្នាថា ការរំលោភផ្លូវភេទក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានចោទប្រកាន់ឡើយនៅក្នុងសំណុំរឿង ០០២/០២។ នៅពេលចាប់ផ្តើមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានស្រេចថា៖

ពុំមានមូលដ្ឋានច្បាប់ សម្រាប់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំបន្ថែមនៅក្នុងដីកាដំណោះស្រាយនូវការចោទប្រកាន់ចំពោះការរំលោភសេពសន្ថវៈ (ក្រៅក្របខណ្ឌនៃការរៀបអាពាហ៍-ពិពាហរណ៍ដោយបង្ខំ) ដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខនានាឡើយ (ឯកសារ E991 កថាខណ្ឌ៣២-៤១-៤៣-៤៥)។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ការរំលោភសេពសន្ថវៈ ពុំកើតមានឡើងនៅមន្ទីរសន្តិសុខទេ ហើយបទល្មើសទាំងនេះមិនអាចយកធ្វើជាមូលដ្ឋាន ដើម្បីចោទប្រកាន់ចំពោះជនជាប់ចោទបានដែរ ដោយហេតុថា ពុំមានភស្តុតាងគាំទ្រដែលថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យប្រើប្រាស់គោលនយោបាយនៃការរំលោភសន្ថវៈនៅក្នុងមន្ទីរសន្តិសុខឡើយ (ឯកសារ D427 កថាខណ្ឌ១៤២៦-១៤២៩)។ ទោះបីជា អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាដំណោះស្រាយ បានកំណត់ក្នុងដីកាដំណោះស្រាយក៏ដោយ ក៏ប៉ុន្តែអង្គជំនុំជម្រះមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ ផ្អែកតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចបញ្ចូលអង្គហេតុ ឬបទចោទថ្មីទៅក្នុងដីកាដំណោះស្រាយដែលអង្គហេតុ ឬ បទចោទនោះត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតនោះ។

**១៨៨.** អង្គជំនុំជម្រះបានកត់សម្គាល់ថា «ហេតុការណ៍នៃការរំលោភផ្លូវភេទ អាចជាការពាក់ព័ន្ធក្នុងចំណោមការពាក់ព័ន្ធផ្សេងទៀតទៅនឹងលក្ខខណ្ឌនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់» ដោយមិនគិតដល់អង្គហេតុដែលថា ដីកាដំណោះស្រាយមិនបានចោទប្រកាន់ថា ជនជាប់ចោទមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរំលោភផ្លូវភេទនៅក្រាំងតាចាន់ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវណាមួយនោះទេ។ នាពេលថ្មីៗនេះ អង្គជំនុំជម្រះបានច្រានចោលសំណើសុំកំណត់ប្រភេទបទចោទឡើងវិញ ចំពោះការរំលោភផ្លូវភេទថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការរំលោភផ្លូវភេទ អំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ឬការធ្វើទារុណកម្ម។ អង្គជំនុំជម្រះយល់ស្របជាមួយមេធាវីការពារក្តី ខៀវ សំផន ថាការពិចារណាទៅលើភស្តុតាងនៃការររំលោភផ្លូវភេទ ដើម្បីគាំទ្រដល់បទចោទដ៏ទៃទៀតនៅក្នុងដីកាដំណោះស្រាយ គឺជាការកំណត់ប្រភេទបទល្មើសឡើងវិញ ចំពោះអង្គហេតុដែលអង្គជំនុំជម្រះបានសម្រេចថា មិនអាចធ្វើទៅបានក្នុងកាលៈទេសៈទាំងអស់នេះនោះ។ ហេតុដូច្នេះ ភស្តុតាងនៃការរំលោភផ្លូវភេទនៅក្នុងមន្ទីរសន្តិសុខនានា (ស្ថិតក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហណ៍ដោយបង្ខំ) នឹងមិនត្រូវបានពិចារណាជាការគាំទ្រដល់ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌណាមួយនៅក្នុងសំណុំរឿងនេះឡើយ។ ទោះជាយ៉ាងនេះក្តី អង្គហេតុនេះ អាចជួយឲ្យយល់អំពីបរិបទទូទៅនៃស្ថានភាពរស់នៅក្នុងមន្ទីរសន្តិសុខ ហើយនឹងការវាយតម្លៃទៅលើភាពអាចជឿជាក់បាននៃអ្នកផ្តល់ចម្លើយដែលចោទប្រកាន់ចារីពីបទល្មើសទាំងនេះ ឬចារីត្រូវបានចោទប្រកាន់។

**(តនៅលេខក្រោយ)**

# ភាពមន្ទិលសង្ស័យពីដំណើរជីវិតឪពុកខ្ញុំត្រូវបានបញ្ជាក់ច្បាស់

## បន្ទាប់ពី ៤៣ ឆ្នាំដែលគាត់បាត់ខ្លួន

*អ៊ុន សុជាទី*




*ស្រ៊ុន សេងហ៊ត (ស្រ៊ុន សុទិដ្ឋ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិត បានចាប់ផ្ដើមស្វែងរកសាច់ញាតិដែលបានបែកគ្នា និងបាត់ដំណឹង។ គ្រួសារខ្លះបានជួបជុំគ្នាវិញ គ្រួសារខ្លះទៀតបានស្លាប់បាត់បង់សមាជិកគ្រួសារ និងបាត់ដំណឹងមិនដឹងថានៅរស់ ឬក៏ស្លាប់រហូតមកដល់សព្វថ្ងៃ។ ឪពុករបស់ ស្រ៊ុន សុទិដ្ឋ ឈ្មោះ ស្រ៊ុន សេងហ៊ត ត្រូវបានខ្មែរក្រហមចាប់ខ្លួន តាំងពីឆ្នាំ១៩៧៧ នៅក្នុងខេត្តបាត់ដំបង។ ចាប់តាំងពីពេលនោះមក សុទិដ្ឋ





មិនដែលបានទទួលដំណឹងពីឪពុករបស់គាត់ឡើយ។ កន្លងផុតអស់រយៈពេល៤៣ឆ្នាំ ទើប សុទិដ្ឋ បានទទួលដំណឹងថា ឪពុករបស់ខ្លួនត្រូវបានបញ្ជូនមកឃុំឃាំង និងសម្លាប់នៅក្នុងគុកទួលស្លែង។ សព្វថ្ងៃ ស្រ៊ុន សុទិដ្ឋ ភេទប្រុស អាយុ ៥០ឆ្នាំ រស់នៅក្នុងខេត្តបាត់ដំបង មានមុខរបរជាគ្រូបង្រៀនភាសាអង់គ្លេស នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាបាត់ដំបង។ សុទិដ្ឋ បានរៀបរាប់ថា៖

ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនចំនួន៥នាក់ គឺមានស្រីម្នាក់ និងប្រុស៤ នាក់។ ខ្ញុំរៀបការ និងមានកូនចំនួន៤នាក់។ ខ្ញុំមានស្រុកកំណើតនៅខេត្តបាត់ដំបង។ សព្វថ្ងៃនេះ ម្ដាយរបស់ខ្ញុំមានអាយុ៧០ឆ្នាំហើយ។ បងប្អូនខ្ញុំចំនួន៤នាក់ រួមទាំងខ្ញុំ បានឆ្លងកាត់របបខ្មែរក្រហមជាមួយគ្នា។ ចាប់តាំងពីបាត់ឪពុកមក ក្រុមគ្រួសារខ្ញុំមិនដែលបានស៊ើបសួរដំណឹងរបស់គាត់ទេ ព្រោះយើងមិនដែលសង្ឃឹមថា គាត់នៅរស់រានមានជីវិតឡើយ។ ប៉ុន្តែទោះបីយ៉ាងណា យើងនៅតែចង់ដឹងពីទីកន្លែងដែលគាត់ស្លាប់ ហើយនៅពេលដែលមានបុណ្យទានបងប្អូន និងសាច់ញាតិរបស់ខ្ញុំតែងតែធ្វើបុណ្យឧទ្ទិសកុសលជូនគាត់។

### ការចងចាំរបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហម

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុប្រហែលជា៥ឆ្នាំ ប៉ុន្តែខ្ញុំអាចនៅចាំរឿងរ៉ាវដែលបានកើតឡើងចំពោះក្រុមគ្រួសារ និងសាច់ញាតិរបស់ខ្ញុំបានខ្លះៗ។ នៅពេលនោះ ប្អូនៗរបស់ខ្ញុំចំនួន៣នាក់នៅតូចៗនៅឡើយ។ នៅអំឡុងឆ្នាំ ១៩៧៥ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំចេញពីផ្ទះ ឲ្យទៅរស់នៅក្នុងសហករណ៍មួយនៅក្បែរភ្នំសំពៅ ក្នុងខេត្តបាត់ដំបង។ ទៅដល់ទីនោះ ខ្មែរក្រហមបានបំបែកក្រុមគ្រួសាររបស់ខ្ញុំឲ្យរស់នៅដាច់ដោយឡែកពីគ្នា។ ខ្មែរក្រហមបានហៅឪពុករបស់ខ្ញុំទៅរៀនសូត្រ ហើយក្រោយមកក៏ចាត់តាំងគាត់ឲ្យទៅធ្វើមេកងចល័តនៅសហករណ៍ផ្សេង។ ចំណែកខ្ញុំ ត្រូវបានចាត់តាំងឲ្យទៅរស់នៅក្នុងកងកុមារ ដែលក្នុងក្រុមកុមារខ្ញុំតូចជាងគេបង្អស់។ រីឯម្ដាយរបស់ខ្ញុំរស់នៅជាមួយប្អូនៗរបស់ខ្ញុំចំនួន៣នាក់ទៀត។ ពេលរស់នៅក្នុងកងកុមារ ខ្ញុំនឹករឭកម្ដាយ និងសាច់ញាតិរបស់ខ្ញុំយ៉ាងខ្លាំង។ ខ្ញុំតែងតែលួចរត់ចេញពីកងកុមារទៅជួបម្ដាយជាញឹកញាប់។ មានថ្ងៃមួយ មេកងកុមារបានដឹង និងទៅប្រាប់ម្ដាយរបស់ខ្ញុំថា ប្រសិនបើខ្ញុំនៅតែលួចរត់មកផ្ទះទៀត នោះនឹងចាប់ខ្ញុំយកទៅសម្លាប់ចោលហើយ។ ម្ដាយខ្ញុំភិតភ័យយ៉ាងខ្លាំង។ គាត់បានប្រាប់ខ្ញុំឲ្យត្រឡប់ទៅនៅកងកុមារវិញ ថែមទាំងកុំឲ្យលួចរត់មកផ្ទះទៀត។ ខ្ញុំមិនចង់រស់នៅក្នុងកងកុមារទៀតទេ ដូច្នេះ ខ្ញុំតែងតែលួចរត់ចេញពីកងកុមារនៅពេលយប់ ដោយគ្មានគោលដៅច្បាស់លាស់។ ខ្ញុំដេកនៅលើរោងណាដែលគ្មានមនុស្សរស់នៅ។ ប៉ុន្តែ ខ្ញុំមិនហ៊ានទៅជួបម្ដាយ និងសាច់ញាតិរបស់ខ្ញុំទៀតទេព្រោះខ្លាចគាត់ស្ដីបន្ទោស។ លុះព្រឹកឡើងខ្ញុំទៅរកអាហារហូប និងត្រឡប់មកកងកុមារវិញ។ ក្រោយមកម្ដាយរបស់ខ្ញុំបានដឹងរឿងនេះ គាត់បានស្នើសុំមេកងឲ្យខ្ញុំមករស់នៅជាមួយគាត់វិញ។ ខ្ញុំត្រូវបានចាត់តាំងឲ្យឃ្វាលគោ។ ខ្ញុំតែងតែទៅដឹកគោពីកងភ្ជួរ បន្ទាប់ពីភ្ជួររួចយកទៅឲ្យស៊ីស្មៅ ផឹកទឹក និងលាងជម្រះវា។ ខ្ញុំបានដឹកគោទាំងនោះមកឲ្យកងវិញនៅពេលដែលកងភ្ជួររាស់ត្រូវការគោ។ ខ្ញុំធ្វើការងារនេះជារៀងរាល់ថ្ងៃ។

ចាប់តាំងពីឪពុករបស់ខ្ញុំចេញទៅ ខ្ញុំមិនដែលឃើញគាត់ត្រឡប់មកផ្ទះវិញទេ។ រហូតដល់ឆ្នាំ១៩៧៧ ស្រាប់តែឪពុករបស់ខ្ញុំបានត្រឡប់មកផ្ទះរស់នៅជួបជុំគ្រួសារវិញ។ ខ្ញុំសប្បាយរីករាយខ្លាំងណាស់ ព្រោះបានជួបឪពុកវិញ។ ប៉ុន្តែ ខ្ញុំមិនដែលសួរគាត់ថា តើមូលហេតុអ្វីបានជាគាត់ត្រឡប់មកវិញទេ។ ម្ដាយរបស់ខ្ញុំក៏មិនដែលបាននិយាយរឿងអ្វីពីឪពុកខ្ញុំដែរនៅពេលនោះ។ រៀងរាល់ថ្ងៃឪពុករបស់ខ្ញុំត្រូវចេញទៅធ្វើការងារដូចប្រជាជនដទៃទៀតនៅក្នុងសហករណ៍ដែរ។

នៅវេលាម៉ោងប្រហែល ៨ យប់ថ្ងៃមួយ នៅពេលដែលឪពុកខ្ញុំត្រឡប់មកពីភ្ជួរស្រែវិញ គាត់ក៏បានចេញទៅដងទឹកអណ្ដូងក្បែរផ្ទះដោយស្លៀកតែកន្សែងមួយប៉ុណ្ណោះ។ ពេលនោះ ខ្មែរក្រហមមួយក្រុមបានមកដល់ផ្ទះខ្ញុំ ហើយហៅឪពុករបស់ខ្ញុំដោយប្រាប់ថា ឲ្យគាត់ទៅជួយលើកអីវ៉ាន់នៅក្នុងឃ្លាំង រួចហើយក៏នាំគាត់ចេញទៅ។ នៅយប់នោះខ្ញុំដេកលក់យ៉ាងស្កប់ស្កល់ ព្រោះខ្ញុំអស់កម្លាំងបន្ទាប់មកពីឃ្វាលគោវិញ។ ខ្ញុំមិនបានឃើញខ្មែរក្រហមនាំឪពុករបស់ខ្ញុំចេញទៅទេ ប៉ុន្តែខ្ញុំបានឮម្ដាយរបស់ខ្ញុំនិយាយរឿងរ៉ាវទាំងអស់នេះប្រាប់យាយ



ស្តូបរំឭកពីចាចងចាំនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ (ស៊្រុន សុទិដ្ឋ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

និងតារបស់ខ្ញុំនៅពេលព្រឹកឡើង។ យាយនិងតារបស់ខ្ញុំបានទៅសួរនាំមេឃុំឈ្មោះ តាវ៉ាក់ នៅឯភ្នំសំពៅ ដែលធ្លាប់ស្គាល់គ្នានៅក្នុងភូមិ ប៉ុន្តែ តាវ៉ាក់ ឆ្លើយថាមិនបានដឹងរឿងនេះទេ។ ចាប់តាំងពីពេលនោះមក ឪពុករបស់ខ្ញុំទៅបាត់រហូត។ នោះគឺជាការចាកចេញលើកទីពីរ ហើយក៏ជាលើកចុងក្រោយរបស់គាត់ដែលចាកចេញពីយើងដែរ។ ប៉ុន្តែយើងនៅតែទន្ទឹងរង់ចាំផ្លូវគាត់ជានិច្ច។ ខ្ញុំតែងតែនឹកគិតថា តើឪពុករបស់ខ្ញុំបានហូបអាហារពេលល្ងាចហើយ ឬនៅមុនពេលដែលខ្មែរក្រហមមកចាប់គាត់ចេញទៅ ព្រោះពេលនោះគាត់ទើបតែមកពីភ្ជួរស្រែវិញ។ បើតាមការរៀបរាប់របស់ម្តាយខ្ញុំ គឺមានមនុស្សចំនួន២នាក់ផ្សេងទៀត ដែលខ្មែរក្រហមហៅចេញទៅជាមួយឪពុកខ្ញុំ។ ទីមួយ គឺឪពុករបស់ខ្ញុំ ហើយពីរនាក់ទៀតគឺឪពុកមារបស់ម្តាយខ្ញុំ។ ខ្ញុំចាំបានថា នៅពេលដែលខ្មែរក្រហមមកយកឪពុករបស់ខ្ញុំចេញទៅ គឺជាពេលដែលយោធា និងកម្មាភិបាលខ្មែរក្រហមភូមិភាគនិរតីបានចូលមកនៅក្នុងតំបន់ដែលខ្ញុំរស់នៅ ហើយក៏ជាពេលម្តាយរបស់ខ្ញុំកំពុងតែមានផ្ទៃពោះ។ មុនពេលឪពុករបស់ខ្ញុំត្រូវចាប់ខ្លួន ឪពុករបស់ខ្ញុំបានកាប់ឈើដុតធ្វើជាធ្យូង ទុកឲ្យម្តាយខ្ញុំដុតអាំងភ្លើងពេលសម្រាលកូន។ បន្ទាប់ពីបាត់ឪពុករបស់ខ្ញុំ ម្តាយខ្ញុំរស់នៅតស៊ូ និងមើលថែរក្សាកូនតូចៗតែម្នាក់ឯង។ ម្តាយខ្ញុំមិនធ្លាប់បានសម្រាកពីការងារទេ ទោះបីជាគាត់កំពុងតែពពោះ និងសម្រាលកូនរួចភ្លាមៗក៏ដោយ។ ខ្ញុំតែងតែឃើញគាត់ទៅដកសំណាបស្ទូងស្រូវ និងធ្វើការងារផ្សេងៗទៀត។ នៅពេលគាត់ត្រឡប់មកវិញនៅពេលល្ងាច គាត់តែងតែលួចចាប់ក្តាម និងខ្យងនៅក្នុងស្រែយកមកផ្ទះ។

នៅពេលបាត់ខ្លួនឪពុកមិនបានប៉ុន្មានថ្ងៃផង មានអ្នកភូមិខ្លះបានមកប្រាប់ម្តាយរបស់ខ្ញុំថា ឲ្យក្រុមគ្រួសាររបស់ខ្ញុំប្រុងប្រយ័ត្នខ្លួន ព្រោះខ្មែរក្រហមចង់មកចាប់ទាំងក្រុមគ្រួសាររបស់ខ្ញុំយកទៅទៀត។ ពេលនោះយើងរស់នៅក្នុងភាពភ័យខ្លាច និងលំបាកវេទនាយ៉ាងខ្លាំង។ ក្រុមគ្រួសាររបស់ខ្ញុំបានសង្ស័យថា ឪពុករបស់ខ្ញុំប្រហែលត្រូវបានខ្មែរក្រហមសម្លាប់នៅក្នុងល្អាងភ្នំសំពៅ ព្រោះល្អាងនេះ គឺជាទីកន្លែងដែលខ្មែរក្រហមយកមនុស្សទៅសម្លាប់។

## ការស្វែងរកឪពុក

ទោះបីជាក្រុមគ្រួសារ ខ្ញុំបានសន្មតថា ឪពុករបស់ខ្ញុំស្លាប់នៅល្អាងភ្នំសំពៅក៏ដោយ ប៉ុន្តែខ្ញុំនៅតែ ចង់ស្វែងរកដំណឹងរបស់គាត់ឲ្យច្បាស់លាស់។ នៅពេលដែលខ្ញុំអានព័ត៌មាន ហើយប្រទះឃើញរូបថតជនរងគ្រោះនៃរបបខ្មែរក្រហម ខ្ញុំតែងតែបើកមើលរូបថតនោះម្តងមួយៗសន្ធឹក ក្រែងលោប្រទះឃើញរូបថតឪពុករបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដែលបានប្រទះឃើញរូបថតរបស់គាត់ឡើយ។ ខ្ញុំក៏មិនបានដើរស្វែងរកគាត់ដែរ ព្រោះខ្ញុំមិនដឹងថាត្រូវស្វែងរកតាមរបៀបណាទៀត។

ថ្ងៃមួយខ្ញុំបានធ្វើដំណើរមកទីក្រុងភ្នំពេញជាមួយមិត្តភក្តិរបស់ខ្ញុំ។ យើងបានមកទស្សនាសារមន្ទីរទួលស្លែង។ នេះគឺជាដំណើរទស្សនកិច្ចលើកដំបូងរបស់ខ្ញុំមកកាន់សារមន្ទីរទួលស្លែង។ ខ្ញុំបានដើរមើលពីមួយអគារទៅមួយអគារដោយបានប្រទះឃើញរូបថត និងខ្នោះប្រវ៉ាក់សម្រាប់ធ្វើទារុណកម្មជនរងគ្រោះ។ ខ្ញុំរំជួលចិត្តណាស់នៅពេលដែលខ្ញុំបានឃើញរូបភាពសាហាវយ៉ាងយង់ឃ្នងទាំងនោះ។ ខ្ញុំនិងមិត្តភក្តិ បានដើរដល់ស្តូបរំឭកវិញ្ញាណក្ខន្ធមួយ ហើយមិត្តភក្តិរបស់ខ្ញុំបានចង្អុលប្រាប់ខ្ញុំថា ឈ្មោះនៅលើថ្មម៉ាបនៅស្តូបនោះ គឺជាឈ្មោះរបស់អ្នកដែលបានជាប់នៅក្នុងគុកទួលស្លែងនេះ។ ខ្ញុំបានដើរទៅពិនិត្យមើលឈ្មោះទាំងអស់នោះម្តងមួយៗ ហើយ







ក្រុមគ្រួសារ និងបងប្អូនរបស់ ស៊្រុន សុទិដ្ឋ បានធ្វើបុណ្យឧទ្ទិសកុសលដល់ឪពុក ស៊្រុន សេងហ៊ត នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងនៅសារមន្ទីរវាលពិឃាដបឹងជើងឯក។ (ស៊្រុន សុទិដ្ឋ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រំពេចនោះខ្ញុំក៏ប្រទះឃើញមានឈ្មោះពីរ ដែលឆ្លាក់នៅលើផ្ទាំងថ្មម៉ាបនោះ ដូចទៅនឹងឈ្មោះឪពុកខ្ញុំ។ ពេលនោះ ខ្ញុំមានអារម្មណ៍វិលវល់ និងតក់ស្លុតយ៉ាងខ្លាំង ហើយទឹកភ្នែកក៏ស្រក់ចុះមកភ្លាមៗ ព្រោះខ្ញុំគិតក្នុងចិត្តថា ប្រសិនបើពិតជាឪពុកខ្ញុំជាប់ឃុំនៅក្នុងគុកនេះមែន គាត់ច្បាស់ជាត្រូវទទួលរងទារុណកម្មធ្ងន់ធ្ងរ ដូចរូបភាពដែលខ្ញុំបានឃើញនៅតាមអគារនីមួយៗនោះហើយ។

ទោះបីជាយ៉ាងណា ខ្ញុំនៅតែមិនទាន់មានអ្វីដើម្បីបញ្ជាក់ថា ឈ្មោះនេះពិតជាឈ្មោះរបស់ឪពុកខ្ញុំទេ។ ពេលដែលខ្ញុំត្រឡប់មកផ្ទះវិញ ខ្ញុំក៏សម្រេចចិត្តផ្សព្វផ្សាយរឿងរ៉ាវទាំងនេះនៅក្នុងគណនីហ្វេសប៊ុករបស់ខ្ញុំ។ មិត្តភក្តិរបស់ខ្ញុំម្នាក់បានណែនាំខ្ញុំឲ្យទំនាក់ទំនងទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាទីកន្លែងស្រាវជ្រាវ និងមានតម្កល់ឯកសារពីរបបខ្មែរក្រហម។ មិនបង្អង់យូរ ខ្ញុំបានផ្ញើសារអេឡិចត្រូនិចទៅកាន់អ៊ីម៉ែលដែលមាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ភ្លាមៗនោះ ខ្ញុំបានទទួលអ៊ីម៉ែលឆ្លើយតបមកវិញដោយមានភ្ជាប់នឹងចម្លើយសារភាពចំនួន ៣ច្បាប់ ដែលចម្លើយសារភាពមួយច្បាប់ ក្នុងចំណោមចម្លើយសារភាពចំនួន៣ច្បាប់នោះ គឺជាចម្លើយសារភាពរបស់ឪពុកខ្ញុំ។ ឯកសារនេះ បានបញ្ជាក់យ៉ាងច្បាស់ថា ឪពុករបស់ខ្ញុំពិតជាត្រូវបានចាប់យកមកគុកទួលស្លែងពិតប្រាកដមែន។ បន្ទាប់មក ខ្ញុំក៏បានចែករំលែករឿងរ៉ាវទាំងអស់នេះទៅម្តាយ និងសាច់ញាតិរបស់ខ្ញុំ។ យើងគ្រប់គ្នាស្រណោះគាត់ណាស់ ដែលត្រូវខ្មែរក្រហមបានចាប់យកមកគុកទួលស្លែង និងទទួលរងទារុណកម្មយ៉ាងសាហាវព្រៃផ្សៃបែបនេះ។

## ពេលទទួលបានដំណឹងពីឪពុក

ខ្ញុំមិនធ្លាប់គិតថា ខ្មែរក្រហមបានចាប់ឪពុករបស់ខ្ញុំយកមកទួលស្លែងនោះទេ ហើយខ្ញុំក៏មិនដែលធ្លាប់មកទួលស្លែងពីមុនមកដែរ។ នៅពេលដែលដឹងថាឪពុកខ្ញុំត្រូវខ្មែរក្រហមចាប់យកមកទួលស្លែងដូច្នេះ អ្វីដែលយើងអាចធ្វើជូនគាត់បានគឺយើងបានមូលមតិគ្នាមកបង្សុកូលនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និង

សារមន្ទីរវាលពិឃាដបឹងជើងឯកជូនគាត់ដោយសង្ឃឹមថា ជាតិក្រោយគាត់នឹងមិនជួបប្រទះនឹងអំពើឃោរឃៅដូច្នេះទេ។ ខ្ញុំបានដឹងរឿងច្រើនពីឪពុកខ្ញុំតាមរយៈឯកសារចម្លើយសារភាពរបស់គាត់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឲ្យ។ វាបានរំឭករឿងរ៉ាវជាច្រើនដល់ខ្ញុំនិងម្តាយនៅក្នុងរបបខ្មែរក្រហម។ ម្តាយរបស់ខ្ញុំបាននិយាយថា វាពិតជារឿងរ៉ាវដែលបានកើតឡើងនៅពេលនោះមែន ប៉ុន្តែខ្មែរក្រហមបានប្រែក្លាយព័ត៌មានទាំងនោះទៅជាអំពើក្បត់អង្គការទៅវិញ។ ម្តាយខ្ញុំនៅចងចាំឈ្មោះមនុស្សមួយចំនួន ដែលបានរាយការណ៍នៅក្នុងចម្លើយសារភាពនោះ។ ចម្លើយសារភាពរបស់ឪពុកខ្ញុំ បានបញ្ជាក់ថា ការចងចាំរបស់ខ្ញុំពិតជាត្រឹមត្រូវទោះបីជាពេលនោះខ្ញុំនៅក្មេងក៏ដោយ។ នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ខ្ញុំរស់នៅជាមួយឪពុករបស់ខ្ញុំបានត្រឹមតែរយៈពេលប្រហែល ២ខែតែប៉ុណ្ណោះ។

## ចម្លើយសារភាពរបស់ឪពុកខ្ញុំដែលរក្សាទុកនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ឪពុកខ្ញុំឈ្មោះ ស្រ៊ុន សេងហ៊ិត មានស្រុកកំណើតនៅភូមិបុស្សឫស្រុក ឃុំខ្ពប ស្រុក២០ ក្នុងខេត្តបាត់ដំបង។ គាត់គឺជាអតីតសាស្ត្រាចារ្យវិទ្យាល័យបាត់ដំបងនៅក្នុងសម័យសង្គមចាស់។ នៅក្នុងរបបខ្មែរក្រហម គាត់គឺប្រធានកងចល័ត និងជាប្រជាជនថ្មីនៅសហករណ៍ទី ៣ ស្រុកភ្នំសំពៅ ភូមិភាគពាយ័ព្យ។ ខាងក្រោមនេះគឺជាការរៀបរាប់ពីសកម្មភាពរបស់គាត់ប្រាប់ទៅដល់កងសួរចម្លើយ ចាប់តាំងពីមុនឆ្នាំ១៩៧០ រហូតដល់អង្គការចាប់ខ្លួនគាត់យកទៅឃុំឃាំងនៅក្នុងគុកទួលស្លែង ៖

## សកម្មភាពមុនឆ្នាំ១៩៧០

នៅក្នុងឆ្នាំ១៩៥៥ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាវត្តខ្ពបរហូតដល់ថ្នាក់ទី៧។ នៅក្នុងឆ្នាំ១៩៦១ ខ្ញុំបានប្រឡងជាប់ និងទៅរៀននៅវិទ្យាល័យទិចនិចនៅឯភ្នំពេញ។ នៅពេលរៀននៅឯទីក្រុងភ្នំពេញ ខ្ញុំបានស្នាក់នៅផ្ទះរបស់ឈ្មោះ ពៅ ឈន ដែលជាអតីតវិសុករវិទ្យាល័យទិចនិចភ្នំពេញ។ នៅក្នុងឆ្នាំ១៩៦៤ ឈ្មោះ ពៅ ឈន បានអប់រំខ្ញុំឲ្យចូលធ្វើជាភ្នាក់ងារ សេ.អ៊ី.អា ដោយអប់រំអំពីរបបលោកសេរី គឺជារបបសម្បូរសប្បាយដូចជា ប្រទេសអាមេរិក ហើយថែមទាំងលើកយកពីរបបកុម្មុយនីស្ត និងប្រទេសចិនថា ជារបបមនុស្សរស់នៅលំបាកវេទនាណាស់។ ក្នុងនាមខ្ញុំជាភ្នាក់ងារ សេ.អ៊ី.អា ខ្ញុំមានតួនាទីដូចជា ១) ត្រូវកសាងកម្លាំង សេ.អ៊ី.អា ឲ្យបានច្រើន ២) តាមដានសកម្មភាពខ្មែរក្រហម និង៣) ឃោសនាសិស្សឲ្យស្អប់ខ្មែរក្រហម។ បន្ទាប់ពីចូលធ្វើជាភ្នាក់ងារ សេ.អ៊ី.អា ឈ្មោះ ពៅ ឈន បានឲ្យខ្ញុំស្គាល់ខ្សែរយៈ សេ.អ៊ី.អា ពីរនាក់បន្ថែមទៀតគឺឈ្មោះ ឡេង ស៊ីផុន និង ហ៊ីង ទុន ដែលជាអតីតសិស្សវិទ្យាល័យតិចនិច។ ក្នុងរយៈពេលនោះ ខ្ញុំ, ឡេង ស៊ីផុន, និង ហ៊ីង ទុន បានធ្វើសកម្មភាពបាចត្រាក់ នៅតាមផ្លូវព្រះមុន្នីវង្សនៅឯភ្នំពេញបានម្តង។ ខ្លឹមសារត្រាក់នោះគឺ ខ្មែរក្រហមជាអ្នកបម្រើផលប្រយោជន៍ឲ្យកុម្មុយនីស្ត។ នៅក្នុងឆ្នាំ១៩៦៦ ឈ្មោះ ពៅ ឈន បានឲ្យខ្ញុំទាក់ទងបក្ខពួកចំនួន ៣នាក់បន្ថែមទៀតគឺ ១) ង៉ោ គឹមសេង, នុក កល្យាន និង ពៅ វ៉ាន់ ហៅ កវ៉ាន ដែលសុទ្ធតែជាសិស្ស។ បន្ទាប់ពីទាក់ទងអ្នកទាំងបីនេះ ខ្ញុំបានចាប់ខ្មែរក្រហមចំនួន ៤ នាក់នៅវិទ្យាល័យទួលគោក។ រហូតដល់ឆ្នាំ១៩៦៧ ខ្ញុំបានប្រឡងជាប់ចូលធ្វើជាសាស្ត្រាចារ្យខាងអគ្គិសនី និងមកនៅឯមហាវិទ្យាល័យគរុកោសល្យភ្នំពេញ។ នៅពេលនោះ ឈ្មោះ ពៅ ឈន បានឲ្យខ្ញុំស្គាល់ខ្សែរយៈ សេ.អ៊ី.អា ចំនួន ២នាក់ផ្សេងទៀតគឺ លឹម អ៊ុយសេង និង ភុយ ស៊ីខុម ដែលជាអតីតសាស្ត្រាចារ្យមហាវិទ្យាល័យគរុ-កោសល្យ។ ខ្ញុំនិងខ្សែ សេ.អ៊ី.អា ចំនួន២នាក់នេះ បានកសាងកម្លាំងបន្ថែមចំនួន ២នាក់ទៀតគឺឈ្មោះ ដូ វេង និង ឃី ហួយ។ មិនតែប៉ុណ្ណោះ បក្ខពួកយើងថែមទាំងចាប់បានខ្មែរក្រហមម្នាក់ឈ្មោះ សាញ់ ដែលជាសិស្សនៅក្នុងមហាវិទ្យាល័យគរុកោលស្យ។ នៅក្នុងឆ្នាំ១៩៦៩ ខ្ញុំបានដាច់ខ្សែទាក់ទងពីបក្ខពួកទាំងអស់នេះ ព្រោះខ្ញុំបានផ្លាស់មកបង្រៀននៅវិទ្យាល័យបាត់ដំបងវិញ។ នៅក្នុងរយៈពេលដែលខ្ញុំរស់នៅក្នុងខេត្តបាត់ដំបង ខ្ញុំបានទាក់ទងជាមួយនឹងឈ្មោះ អួនកាន់ណូរ៉ា និង ឈា យួម និងបានទទួលផែនការពីរ គឺតាមដានចលនាខ្មែរក្រហមក្នុងចំណោមសិស្ស និងកសាងកម្លាំងបន្ថែម។ ក្រោយមក ខ្ញុំក៏បានទាក់ទងបក្ខពួកមួយចំនួនទៀតឈ្មោះ សេង ដូ, លី ប៊ុនជ និង ដួង សារ៉េត ដែលជាសាស្ត្រាចារ្យនៅវិទ្យាល័យបាត់ដំបង។

## សកម្មភាពចាប់ពីឆ្នាំ១៩៧០មក

ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ ឈ្មោះ ឈា យួម បានចាត់តាំងខ្ញុំ, សេង ដូ, លី ប៊ុនជ និង ដួង សារ៉េត ឲ្យទៅទាក់ទងជាមួយឈ្មោះ ប៉ូច ដែលជាអតីតមេឃុំកំពង់ព្រះ ស្រុកសង្កែឲ្យចូលរួមតាមដានខ្មែរក្រហម។ ក្រោយពីចាត់តាំងហើយ ខ្ញុំនិងគ្នីគ្នាបានធ្វើសកម្មភាពចាប់ខ្មែរក្រហមបានចំនួន ៧នាក់។ ក្រោយមក ខ្ញុំបានកសាងកម្លាំងបានចំនួន ២នាក់បន្ថែមទៀតគឺមានឈ្មោះ សោ បេងឃុង និង សុខ ប៊ុនហុក ដែលជាអតីតសាស្ត្រាចារ្យវិទ្យាល័យបាត់ដំបង។ ខ្ញុំនិងបក្ខពួកចាប់បានខ្មែរក្រហមចំនួន ៣នាក់ដែលជាសិស្សនៅក្នុងវិទ្យាល័យបាត់ដំបង។ ចន្លោះឆ្នាំ ១៩៧៣ ដល់ ឆ្នាំ១៩៧៤ ខ្ញុំបានចូលរួមសកម្មភាពជាមួយគ្នីគ្នា ហើយកសាងកម្លាំងបានពីរនាក់បន្ថែមទៀតគឺមានឈ្មោះ ចៅ ឈីង និង ឈឹម សាគុន។ ក្រោយមកខ្ញុំនិងបក្ខពួកចាប់បានខ្មែរក្រហមចំនួន៧នាក់បន្ថែមទៀតដែលជាសិស្សវិទ្យាល័យបាត់ដំបង។

## សកម្មភាពក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥

ក្រោយពីខ្មែរក្រហមរំដោះបាន ខ្ញុំបានដាច់ខ្សែរយៈពីបក្ខពួកចាស់ដែលធ្លាប់រួមសកម្មភាពជាមួយគ្នា។ ក្រោយមកខ្ញុំបានទាក់ទងជាមួយឈ្មោះ អែម សូវ តាមរយៈឈ្មោះ ឈា យួម។ ខ្ញុំបានទាក់ទងជាមួយឈ្មោះ ស៊ិន ញឹក អតីតនាយកផ្នែកសិក្សាវិទ្យាល័យបាត់ដំបង និងជាប្រជាជនថ្មីនៅសហករណ៍ទី ២ ស្រុកភ្នំសំពៅ តំបន់៣។ អំឡុងពេលនោះ ខ្ញុំក៏មានទំនាក់ទំនងជាមួយឈ្មោះ សូវ ឈួត, ស៊ិន សារឿន និង ញឹក ដើម្បីរួមសកម្មភាពកសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមប្រជាជនថ្មីដែរ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំបានទៅរៀននៅស្រុកមង្គលបុរីតំបន់ ៣ ហើយបានជួបជាមួយបក្ខពួកចាស់ឈ្មោះ ម៉ៅ អួប។ ក្រោយមក ម៉ៅ អួប ក៏មានការណែនាំឲ្យស្គាល់ខ្សែ សេ.អ៊ី.អា ចំនួន៤នាក់ទៀតរួមមានឈ្មោះ គួម ឈួង, ហ៊ី សាញ់, មុច ម្រម, និង ហៃ។ នៅខែសីហា ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងឲ្យខ្ញុំទៅដេកនៅមន្ទីរឃុំតាង៉ែន ស្រុកភ្នំសំពៅ តំបន់៣ ហើយមានតួនាទីជាអ្នកអប់រំប្រជាជនថ្មី។ មុនពេលទៅរស់នៅឃុំតាង៉ែន ខ្ញុំបានទទួលផែនការពីឈ្មោះ មុច ម្រម ឲ្យឃោសនាប្រាប់ប្រជាជនថ្មីឲ្យស្អប់បដិវត្តន៍ និងកសាងកម្លាំង សេ.អ៊ី.អា បន្ថែមទៀត។ ពេលរស់នៅក្នុងឃុំតាង៉ែន ខ្ញុំនិងបក្ខពួកបានកសាងកម្លាំង សេ.អ៊ី.អា ជាបន្តបន្ទាប់និងបានបំផុសឲ្យប្រជាជនចំនួន១០គ្រួសារ សាររត់ចូលទៅក្នុងទឹកដីថៃ ដោយយើងបានលើកឡើងថា រស់នៅទីនេះ ថ្ងៃណាមួយអង្គការនឹងយកទៅសម្លាប់។ រហូតដល់ខែវិច្ឆិកា ឆ្នាំ ១៩៧៥ ឈ្មោះ ឈន បានចាត់តាំងឲ្យខ្ញុំទៅលើកទំនប់ទឹក។ រយៈពេលនោះ ឈន បានឲ្យខ្ញុំទទួលផែនការពីឈ្មោះ ហៃ ដោយឲ្យកសាងកម្លាំងសេ.អ៊ី.អា បន្ថែម និងបំផុសឲ្យប្រជាជនរត់ចេញពីកន្លែងលើកទំនប់ ដើម្បីឲ្យស្ទះផែនការរបស់អង្គការ។ក្រោយពីទទួលបានផែនការហើយឈ្មោះ ហៃ បានឲ្យខ្ញុំស្គាល់ខ្សែរយៈ សេ.អ៊ី.អា ផ្សេងទៀត ដើម្បីទាក់ទងបំផ្លាញស្រូវជាមួយឈ្មោះ ឆាំ អតីតអ្នកធ្វើស្រែ។ ក្រោយមក ខ្ញុំនិងបក្ខពួក បានកសាងកម្លាំង សេ.អ៊ី.អា បាន៣នាក់បន្ថែមទៀតគឺ ឈ្មោះ គី អតីតជាងនាឡិកា, ស៊ុនអតីតជាជាងឡាន និង លីម ឡាយ អតីតជាអ្នកលក់ត្បូង។ រហូតដល់ខែធ្នូឆ្នាំ១៩៧៥ ឈ្មោះ ហៃ បានចាត់តាំង ខ្ញុំ,ម៉ៅ អួប និង ហ៊ី សាញ់ ឲ្យទៅចាប់ឈ្មោះ ទឿន ប្រធានកងចល័ត ឃុំពាក់ស្បែក ដោយចោទថាជាខ្មាំង។ ពេលចាប់បាន ខ្ញុំយកទៅឲ្យឈ្មោះ ឆាំ។ នៅចុងខែធ្នូ ឆ្នាំ១៩៧៥ ខ្ញុំបានទទួលផែនការពីឈ្មោះ ហៃ ឲ្យបំផ្លាញស្រូវរដ្ឋក្នុងពេលបង្កបង្កើនផល និងបំផុសឲ្យមានភាពច្របូកច្របល់ក្នុងកងចល័ត។

ខែមករា ឆ្នាំ១៩៧៦ ខ្ញុំ បានធ្វើសកម្មភាពជាមួយឈ្មោះ អួប, ហ៊ី សាញ់ និង ម្រម ដុតកណ្តាប់ស្រូវអស់មួយគំនរចំនួន១០ស្លឹក។ ខែកុម្ភៈ ឆ្នាំ១៩៧៦ ឈ្មោះ ឆាំ បានដកអង្គភាពចល័តរបស់ខ្ញុំឲ្យមកនៅភ្នំសំពៅវិញ។ ក្នុងរយៈពេលនោះឈ្មោះ យួម បានឲ្យខ្ញុំទាក់ទងជាមួយឈ្មោះ ជា ដើម្បីចូលរួមសកម្មភាពបង្អាក់ពេលវេលាប្រមូលផលស្រូវរបស់អង្គការ។ ឈ្មោះ ជា ក៏បានលួចស្រូវពីសហករណ៍ទី២ លាក់ទុកឲ្យឈ្មោះ ឈន ដើម្បីយកទៅឲ្យឈ្មោះ ម៉ាញ ដែលជាអ្នកដឹកនាំកម្លាំងក្បត់នៅភ្នំកុយ។ ពេលនោះដែរ ខ្ញុំបានធ្វើសកម្មភាព និងកសាងកម្លាំងខ្សែរយៈ សេ.អ៊ី.អា បានចំនួន ២នាក់ បន្ថែមទៀតគឺឈ្មោះ ព្រុំ ឆាត និងសូ។ នៅខែមីនា ឆ្នាំ១៩៧៦ ឈ្មោះ

ហៃ និង យឿន បានចាត់តាំងខ្ញុំឲ្យធ្វើសម្ភភាពជាមួយ ឈ្មោះ ហាប់ ដើម្បីចាប់កម្លាំងបដិវត្តន៍ចំនួន ២នាក់ គឺ ឈ្មោះ ឡុច និង សួស ដោយចោទថា ធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍។ ការចាប់ខ្លួន ឡុច និង សួស នេះ ដោយសារមានទំនាស់ជាមួយនឹងបក្ខពួកខ្ញុំអំពីបញ្ហាលើកភ្លឺស្រែមិនធ្វើតាមការចាត់តាំងរបស់បក្ខពួករបស់ខ្ញុំ។ នៅខែមេសា ឆ្នាំ១៩៧៦ ឈ្មោះ ឆាំ បានចាត់តាំងឲ្យខ្ញុំមកនៅខាងស្រែពិសោធន៍វិញ។ ឆាំ បានឲ្យខ្ញុំស្គាល់ខ្មែរយៈពីរនាក់ទៀត ឈ្មោះ ឈឿម ប្រធានស្រែពិសោធន៍ និង សាលី អនុប្រធានស្រែពិសោធន៍។ ក្រោយមក យើងក៏បានកសាងកម្លាំងបន្ថែមបានចំនួន ៣នាក់ទៀត គឺ ឈ្មោះ ប៉ាន, វន និង មឿន។ ផែនការរបស់យើងគឺ បំផ្លាញស្រូវពិសោធន៍ឲ្យអស់ ២ ហិចតាកន្លះ ដោយមិនចាត់តាំងកម្លាំងឲ្យទៅប្រូតនៅខែទឹកឡើងដោយទុកឲ្យស្រូវរលួយ។ នៅខែឧសភា និងខែមិថុនាឆ្នាំ១៩៧៦ ខ្ញុំបានទទួលផែនការពីឈ្មោះ ឆាំ ដើម្បី ១) ពង្រីងនិងពង្រីកកម្លាំង សេ.អ៊ី.អា បន្ថែមទៀត ២) បំផ្លាញតាមភារកិច្ចបង្កបង្កើនផល និង៣) ត្រៀមទុកអង្ករយកទៅឲ្យចោរព្រៃ។ ក្រោយមកខ្ញុំក៏បានបញ្ចូលកម្លាំងបានចំនួន៤នាក់ទៀត គឺឈ្មោះ សឿន, កួន, កៅ, និង ចាន់ ដោយមានគម្រោងបំផ្លាញស្រូវពិសោធន៍ឲ្យអស់ ៥ហិចតា។ យើងឲ្យបក្ខពួកចំនួន ៤នាក់នេះទៅទម្លាយទឹកបញ្ចូលស្រែឲ្យលិចរលួយអស់។ ខែកក្កដា ឆ្នាំ១៩៧៦ ឈ្មោះ ឆាំ បានចាត់តាំងខ្ញុំឲ្យមកនៅស្រែកសិដ្ឋានរដ្ឋបឹងត្រាវវិញ។ នៅទីនោះ ខ្ញុំ, យឿន និង ហាប់ បានបំផ្លាញកណ្តាប់សំណាប់អស់១ស្ទឹកពីរផ្លូនដោយយកទៅដាន់ពន្លិចទឹកចោល ថែមទាំងបំផ្លាញស្រូវពង្រួសអស់ចំនួន ៥ហិចតា ដោយទម្លាយទឹកជន់ដាក់ឲ្យរលួយអស់។ ខ្ញុំនិងបក្ខពួក ក៏បានបញ្ចូលកម្លាំងបន្ថែមបានពីរនាក់ទៀតគឺ មានឈ្មោះស្នា និងស៊ុថា។ ខែសីហា ឆ្នាំ១៩៧៦ ឈ្មោះ ឆាំ បានឲ្យខ្ញុំទាក់ទងខ្មែរ សេ.អ៊ី.អា ចាស់ៗឈ្មោះ អែម សូវ និងសារឿន និងខ្មែរ សេ.អ៊ី.អាថ្មីចំនួន ២នាក់ទៀតឈ្មោះ ប៊ុន និងប៉ូច។



ក្រុមគ្រួសារ និងបងប្អូនរបស់ ស្រ៊ុន សុទិដ្ឋ បានធ្វើបុណ្យឧទ្ទិសកុសលឲ្យដល់ឪពុក ស្រ៊ុន សេងហ៊ិត នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងនៅសារមន្ទីរវាលពិឃាដបឹងជើងឯក។ (ស្រ៊ុន សុទិដ្ឋ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)





ក្រោយពីទាក់ទងហើយ យើងទាំងបួននាក់បានបំផ្លាញសន្ទុងស្រូវអស់ចំនួន៤ហិចតា។ ខែកញ្ញានិងខែតុលា ឆ្នាំ១៩៧៦ ប៊ុន បានចាត់តាំងខ្ញុំ, អែម សូវ, សារឿន និង ប៊ូច ឲ្យចែកសំណាប ហើយបក្ខពួកខ្ញុំបានបំផ្លាញសំណាបអស់ប្រហែល១ស្ទឹក ដោយរែកទៅចោលក្នុងព្រៃពេលយប់។ ក្រោយមកយើងបានបញ្ចូលកម្លាំងបន្ថែមម្នាក់ទៀតឈ្មោះ ឌឿន។ យើងបានលួចលាក់ស្រូវរបស់សហករណ៍ទី៣ បានចំនួន៦បាវ យកទៅឲ្យឈ្មោះ ឆាំ ដើម្បីត្រៀមទុកផែនការវាយបក្សឆ្នាំ១៩៧៧។ នៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ១៩៧៦ ខ្ញុំបានទទួលផែនការពីឈ្មោះ ឆាំ ឲ្យត្រៀមកម្លាំងរៀបចំទុកបម្រើផែនការវាយយកខេត្តបាត់ដំបង និងឲ្យយកស្បៀងឲ្យឈ្មោះ ព្រឿន ជាអ្នកកាន់ទ័ពព្រៃនៅភ្នំកូនដំរី។ ក្រោយពីបានទទួលផែនការហើយ ខ្ញុំបានធ្វើសកម្មភាពរួមជាមួយឈ្មោះ ប៊ូច សារឿន, អែម សូវ និង ប៊ុន កសាងកម្លាំង សេ.អ៊ី.អា បានចំនួន ៤នាក់បន្ថែមទៀត គឺមានឈ្មោះ សុខ, សាវុន, យឿន និង ថៃ។

ខែមករា ឆ្នាំ១៩៧៧ ប៊ុន បានចាត់តាំងឲ្យខ្ញុំទៅប្រូតស្រូវនៅវាល ឡូញ ដើម្បីធ្វើសកម្មភាពជាមួយខ្មែរបណ្តាញចាស់ៗ យើងបានដុតបំផ្លាញស្រូវនៅឯវាល ឡូញឆេះអស់ចំនួន ២ហិចតា និងលួចស្រូវរបស់សមូហភាពបាន ៥បាវ ប្រហុក ១ពាង ដើម្បីយកទៅឲ្យឈ្មោះ ព្រឿន តាមរយៈឈ្មោះ ឆាំ។ ក្រៅពីនេះយើងបានកសាងកម្លាំងបន្ថែមបានចំនួនពីរនាក់ទៀត គឺមានឈ្មោះ ប៊ិល និង យាន។ នៅខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៧៧ ខ្ញុំនិងបក្ខពួក បានបំពុលគោនៅសហករណ៍ទី៣ ងាប់អស់គោចំនួន១១ក្បាល និងពុលមួយចំនួនទៀត ដោយយកថ្នាំពុលលាយជាមួយទឹកដាក់ឲ្យគោផឹក។ ក្រោយមកយើងបានលួចស្រូវបានចំនួន ៧បាវ អំបិល ១ការ៉ុងដើម្បីយកទៅឲ្យឈ្មោះ ព្រឿន ដែលជាអ្នកក្តាប់កងទ័ពព្រៃនៅភ្នំកូនដំរីដោយមានឈ្មោះសាលីជាអ្នកយកទៅឲ្យ។ យើងក៏បានបញ្ចូលភ្នាក់ងារ សេ.អ៊ី.អា បានចំនួន៣នាក់ទៀតគឺឈ្មោះ យ៉ែន, ស៊ុវ៉ាន់ និង ម៉ាក់។ នៅខែមេសា ឆ្នាំ១៩៧៧ ផែនការរបស់ខ្ញុំត្រូវបានបរាជ័យ ដោយអង្គការមានវិធានការមិនឲ្យដើរទាក់ទងគ្នា។ ដោយសារតែផែនការនេះបរាជ័យ ខ្ញុំក៏បានទទួលផែនការថ្មីពីឈ្មោះ ប៊ុន ម្តងទៀត គឺពង្រីងពង្រីកកម្លាំង សេ.អ៊ី.អា បន្តទៀត, ត្រៀមស្បៀងវាយយកខេត្តបាត់ដំបងនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ និងបំផ្លិចបំផ្លាញបដិវត្តន៍តាមភារកិច្ចបង្កើតផល។ ក្រោយពីទទួលបានផែនការរួចហើយ នៅខែឧសភាឆ្នាំ១៩៧៧ ខ្ញុំបានរួមសកម្មភាពជាមួយខ្មែរចាស់មានឈ្មោះ ប៉ុច, សារឿន, ប៊ិ និង ទាប លួចលាក់ស្រូវចំនួន ១៥បាវ អំបិល ២ការ៉ុង ក្រម៉ា១០ ក្រណាត់ខ្មៅ៣០ម៉ែត្រ យកទៅឲ្យឈ្មោះ ឆាំ ទុកដើម្បីមានផែនការថ្ងៃមុខ។ ក្រៅពីនោះ ខ្ញុំនិងបក្ខពួក បានបំពុលក្របីងាប់អស់ចំនួន ៣ក្បាល និងបញ្ចូលកម្លាំង សេ.អ៊ី.អា បាន ៣នាក់បន្ថែមទៀតគឺឈ្មោះ ឈង, ដន និង ហ៊ុយ។ នៅខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំបានធ្វើសកម្មភាពជាមួយឈ្មោះ ប៉ូច, ប៊ុន និងសារឿន ដើរបំផុសបំផុលប្រជាជនថ្មីដែលធ្វើការងារជាមួយឲ្យធ្វើការងារលួមៗ ដើម្បីទុកកម្លាំងទៅថ្ងៃក្រោយ។ យើងក៏បំផុសអំពីការស៊ីបុកមិនគ្រប់គ្រាន់ និងតាំងពីពេលនោះមក ប្រជាជនមួយចំនួនត្រូវផ្អាកធ្វើការងារជាបន្តបន្ទាប់។ នៅខែកក្កដាឆ្នាំ១៩៧៧ ផែនការរបស់យើងត្រូវបរាជ័យម្តងទៀត ដោយសារតែខ្មែរ សេ.អ៊ី.អា មួយចំនួនត្រូវបានអង្គការចាប់ខ្លួន។ តាំងពីពេលនោះមក ខ្ញុំផ្អាកធ្វើសកម្មភាពមួយរយៈ។

រហូតមកដល់ខែសីហា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនខ្ញុំ និងក្រោយមកបានបញ្ជូនខ្ញុំមកឃុំឃាំងក្នុងគុកទួលស្លែង។ ខ្ញុំត្រូវបានឈ្មោះទូច សឿន និងទិតសួរចម្លើយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧។

## «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ម៉ៃ ភី ៖ ប៉ូលីស

***ឈ្មោះ សេក ស៊ុណ្ណារី ត្រូវជាប្រពន្ធរបស់ ម៉ៃ ភី បាននិយាយរៀបរាប់ប្រាប់ថា៖***



*ម៉ៃ ភី និង សេក ស៊ុណ្ណារី បន្ទាប់ពីរៀបការ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅក្នុងរបបលន់ នល់ ប្តីរបស់ខ្ញុំឈ្មោះ ម៉ៃ ភី ធ្វើជាប៉ូលីសនៅក្រុងភ្នំពេញ។ គាត់បានធ្វើការងារផ្សេងទៀតនៅអង្គការមនុស្សធម៌មួយដែលចែកចាយស្បៀងអាហារ។ គាត់បានធ្វើដំណើរញឹកញាប់ទៅកាន់ខេត្តជាច្រើនដើម្បីផ្តល់អង្ករ ប្រហុក ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ និងមុងជាច្រើនដល់ប្រជាជនដែលរងទុក្ខវេទនាដោយសារសង្គ្រាម។

ខ្ញុំកើតនៅខេត្តកណ្តាល។ នៅពេលដែលស្ថានការណ៍ក្នុងស្រុកកំណើតរបស់ខ្ញុំតឹងតែងខ្លាំង ម្តាយរបស់ខ្ញុំបានសម្រេចចិត្តផ្លាស់ទីលំនៅ។ ឪពុករបស់ខ្ញុំបានស្នាក់នៅក្នុងភូមិ ខណៈដែលម្តាយខ្ញុំជួលផ្ទះមួយនៅតាខ្មៅនៅជិតក្រុងភ្នំពេញ និងលក់បារី។ ភី និងខ្ញុំបានរៀបការនៅផ្ទះម្តាយមីងរបស់ខ្ញុំ ដែលនៅជិតទឹកទន្លេម្តាយរបស់ខ្ញុំនៅតាខ្មៅ។

ទោះជាយ៉ាងណា យើងបានអញ្ជើញភ្ញៀវមកចូលរួមពិធីមង្គលការរបស់យើង ចំនួន៥០តុ ប៉ុន្តែមានតែភ្ញៀវ២០តុប៉ុណ្ណោះ ដែលបានមកចូលរួម ព្រោះអឺគ្រាប់បែកបានទម្លាក់នៅក្បែរៗផ្ទះរបស់យើង។ នៅអំឡុងពិធីមង្គលការ ភ្ញៀវច្រើននាក់បានពួននៅក្រោមផ្ទះដើម្បីជៀសវាងពីការបាញ់ប្រហារ។ យ៉ាងណាក៏ដោយ ខ្ញុំស្នាក់នៅខាងក្នុង ខ្ញុំបានប្តេជ្ញាថាខ្ញុំមិនពួននៅក្រោមផ្ទះទេ ទោះជាខ្ញុំត្រូវស្លាប់ក៏ដោយ។

យើងបានរស់នៅជាមួយម្តាយរបស់ខ្ញុំមួយឆ្នាំ បន្ទាប់មកប្តីរបស់ខ្ញុំបានផ្ទេរទៅធ្វើការនៅកំបូល ជាផ្នែកមួយនៃទីក្រុងភ្នំពេញ។ គាត់ធ្វើការជាសន្តិសុខ ត្រួតពិនិត្យមើលប្រជាជនដែលបានព្យាយាមដឹកជញ្ជូនទំនិញរត់ពន្ធនៅក្នុងរថយន្ត។ កូនប្រុសរបស់យើងបានកើតនៅអំឡុងពេលនោះ។

នៅពេលដែលគ្រួសាររបស់យើងត្រូវបានជម្លៀស យើងបានចេញទៅខេត្តកណ្តាល។

យើងមិនចង់ទៅស្រុកកំណើតរបស់យើងទេ ដូចអ្នកផ្សេងៗជាច្រើនទៀតដែរ យើងមានការភ័យខ្លាចថាប្តីរបស់ខ្ញុំនឹងត្រូវសម្លាប់ប្រសិនបើអង្គការដឹងអំពីអតីតភាពរបស់គាត់។ ដូច្នេះ ភី បានប្តូរឈ្មោះរបស់គាត់ទៅជា វណ្ណា និងខ្ញុំបានប្តូរឈ្មោះរបស់ខ្ញុំទៅជា ចន្ធា។ ខ្ញុំបានប្រាប់គេថាគាត់ជាអ្នកអូសរទេះ ហើយខ្ញុំជាអ្នកលក់ដូរ។

បន្ទាប់មកអង្គការបានបញ្ជូនយើងទៅខេត្តបាត់ដំបងតាមរថភ្លើង។ បន្ទាប់ពីបានមួយខែនៅទីនោះ ឪពុករបស់ខ្ញុំធ្លាក់ខ្លួនឈឺ ហើយយើងបានបញ្ជូនគាត់ទៅមន្ទីរពេទ្យមូលដ្ឋាន ប៉ុន្តែជំងឺរបស់គាត់កាន់តែធ្ងន់ទៅៗ ព្រោះមិនមានអាហារនិងថ្នាំពេទ្យគ្រប់គ្រាន់។ នៅមន្ទីរពេទ្យនោះ អង្គការបានអនុញ្ញាតឲ្យយើងយកគាត់មកផ្ទះវិញដោយដឹងថាគាត់រស់មិនបានយូរឡើយ។





១៥ថ្ងៃក្រោយមក គាត់បានស្លាប់នៅក្នុងផ្ទះយើង។ មុនពេលគាត់ស្លាប់ គាត់បាននិយាយទៅកាន់ម្តាយខ្ញុំថា "នៅពេលគាត់ស្លាប់ កុំយំអី ខ្ញុំនឹងបានចាកផុតពីភាពវេទនាទាំងអស់។ ឯងជាអ្នករងទុក្ខច្រើន ព្រោះឯងនៅមានជីវិតរស់នៅឡើយ"។

ក្រោយមក កូនប្រុសរបស់ខ្ញុំឈ្មោះ រស្មី បានស្លាប់ដោយសារកង្វះខាតអាហារ និងថ្នាំពេទ្យ។ ប្រជាជនដែលឈឺត្រូវបានផ្តល់នូវថ្នាំគ្រាប់ពណ៌ខ្មៅដូចជាអាចម៍ទន្សាយអ៊ីចឹង។ បន្ទាប់មកមិនយូរប៉ុន្មាន ម្តាយខ្ញុំបានធ្លាក់ខ្លួនឈឺជាទម្ងន់។ ខ្ញុំមានមាសទម្ងន់ ៣៧,៥ ក្រាម ដែលខ្ញុំយកមកតាមខ្លួនពីភ្នំពេញ។ ខ្ញុំបានដូរមាសនោះបានអង្ករចំនួន៦កំប៉ុងគត់ ជូនម្តាយខ្ញុំ។

ភី ត្រូវបានចាត់តាំងចូលក្នុងកងបុរស ដែលជាទីកន្លែងធ្វើការងារធ្ងន់ៗ។ គាត់ភ្ជួររាស់ស្រែ ស្ទូងស្រូវ និងដកសំណាប។ យើងមិនបានឃើញគ្នាញឹកញាប់ទេ ព្រោះខ្ញុំនៅក្នុងកងនារីជីកស្រះ។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានពរពោះ៤ខែជាកូនទីពីររបស់ខ្ញុំ។ ខ្ញុំមិនបានដឹងថា ខ្ញុំមានកូនឡើយ ទាល់តែខ្ញុំឡើងដើមអំពិលហើយកូននៅក្នុងពោះវាចាប់ផ្តើមធាក់។

ថ្ងៃមួយនោះ នៅពេលខ្ញុំកំពុងដើរទៅកងការងាររបស់ខ្ញុំ ខ្ញុំបានឃើញអង្គការសម្លាប់ ទាហាន ប៉ូលិសជាច្រើននាក់ និងអ្នកខ្ជិលធ្វើការ។ ប្រសិនបើយើងមិនមើលការសម្លាប់នោះទេ អង្គការនឹងចោទប្រកាន់យើងជាខ្មាំង។ បុរសចំណាស់ម្នាក់បានសុំបារីអង្គការបានមួយដើមជក់មុនពេលគាត់ត្រូវបានសម្លាប់។ ខ្ញុំស្គាល់បុរសនោះ គាត់មានឈ្មោះ ហ៊ួយ មាស ធ្លាប់ធ្វើជាអ្នកចម្រៀងប្រជាប្រិយ។

កម្មាភិបាលបានប្រាប់គាត់ឲ្យរត់ជុំវិញរណ្តៅសពជន្ទួសវិញ បន្ទាប់មក ហ៊ួយ មាស បានសុំអង្គការច្រៀងចម្រៀងបានមួយបទ។ ខ្មែរក្រហមឆ្លើយថាបាន បន្ទាប់ពីគាត់បញ្ចប់ការច្រៀងចម្រៀង ខ្មែរក្រហមបានវាយគាត់ទាល់តែស្លាប់ ហើយបន្ទាប់មក វះយកថ្លើមរបស់គាត់ទៅឆាហូប។ បន្ទាប់ពីឃើញទិដ្ឋភាពនេះ ខ្ញុំមិនបានហូបអ្វីសោះរយៈមួយអាទិត្យ។ ខ្ញុំ ស្នាក់នៅភូមិនោះដល់ឆ្នាំ១៩៧៩ នៅពេលដែលរបបនោះបានដួលរលំ។

**ប៊ាង ពីច័ន្ទ និង ទេនី ខកហ្គៀល**



*ពិធីមង្គលការរបស់ ម៉ៃ ភី និង សេក ស៊ុណ្ណារី នៅឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# គង់ មារតី ៖ ធនាគារិក

ម្តាយខ្ញុំបានស្លាប់នៅពេលដែលខ្ញុំនៅតូចៗ ខ្ញុំនៅចាំថា បន្ទាប់មកឪពុកខ្ញុំបានស្លាប់ទៀត នៅពេលដែលខ្ញុំមានអាយុ១០ឆ្នាំ។ ដូចនេះ ខ្ញុំបានធំឡើងដោយប្រឹងប្រែងខ្លួនឯងយ៉ាងខ្លាំង។ បន្ទាប់ពីការស្លាប់របស់ឪពុកខ្ញុំមក ខ្ញុំមានឪពុកធម៌ម្នាក់ជាចៅហ្វាយស្រុកមួយនៅក្នុងខេត្តកំពង់ធំ។ គាត់បានសុំខ្ញុំធ្វើជាឪពុកធម៌របស់ខ្ញុំ។ ក្រោយមកគាត់បានស្លាប់នៅពេលដែលខ្ញុំអាយុបាន១១ឆ្នាំ និងបន្ទាប់ពីនោះមក ម្តាយធម៌របស់ខ្ញុំបានស្លាប់នៅពេលដែលខ្ញុំអាយុបាន ១៥ឆ្នាំ។

ខ្ញុំបានជួបលោកសង្ឃមួយអង្គ នៅតាមផ្លូវនៅខេត្តកំពង់ធំ។ ព្រះអង្គមានសង្ឃដីកាថា "អ្នកឯងមិនមានម្តាយមិនមានឪពុក។ អ្នកអាចទៅភ្នំពេញជាមួយអាត្មាបាន"។ ខ្ញុំបានទៅជាមួយព្រះអង្គ និងរស់នៅក្នុងវត្តមួយបានរយៈពេលមួយឆ្នាំ។ ខ្ញុំបានបញ្ចប់ការសិក្សានៅវិទ្យាល័យទួលស្វាយព្រៃ ក្រោយមកវិទ្យាល័យនេះ បានក្លាយទៅជាគុកទួលស្លែង។

នៅខណៈពេលដែលខ្ញុំរៀននៅមហាវិទ្យាល័យ ខ្ញុំបានធ្វើការមិនពេញម៉ោងដូចជា លក់នំប៉័ង និងធាក់ស៊ីក្លូ ដើម្បីរកប្រាក់បន្ថែម។ ខ្ញុំក៏បានរៀនភាសាបារាំងដែរ ហើយនៅម៉ោងទំនេរ បានទៅហាត់រៀនយូដូ ដោយបានទទួលខ្សែក្រវ៉ាត់ខ្មៅ។ នៅពេលដែលខ្ញុំជានិស្សិតឆ្នាំទីបី នៅសកលវិទ្យាល័យពាណិជ្ជ-


សាកលវិទ្យាល័យភ្នំពេញ
UNIVERSITE DE PHNOM-PENH
Nº 269/BS/72
សាធារណរដ្ឋខ្មែរ
RÉPUBLIQUE KHMERE
មហាវិទ្យាល័យពាណិជ្ជសាស្ត្រ
FACULTÉ DES SCIENCES COMMERCIALES
ATTESTATION DE REUSSITE
LE DOYEN DE LA FACULTÉ DES SCIENCES COMMERCIALES
soussigné certifie que
MONSIEUR KONG MEARDEY គង់ មារតី
né le 11 JUILLET 1950
à CHHEP (KAMPONG- THOM)
a été déclaré reçu à l'examen de BREVET SUPERIEUR DE L'ENSEIGNEMENT COMMERCIAL
Mention PASSABLE
Session du 19 JUIN 1972
Centre de PHNOM-PENH
Phnom-Penh, le 27 AOUT 1972
N. B. Aucun duplicata du présent certificat ne sera délivré.

សញ្ញាប័ត្រ ឌីប្លូម មហាវិទ្យាល័យរបស់ គង់ មារតី។ សាធារណរដ្ឋខ្មែរ/សកលវិទ្យាល័យភ្នំពេញ មហាវិទ្យាល័យវិទ្យាសាស្ត្រពាណិជ្ជកម្ម សូមបញ្ជាក់ថា គង់ មារតី កើតនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៥០ នៅខេត្តកំពង់ធំ ប្រកាសថាបានប្រឡងជាប់សញ្ញាប័ត្រជាន់ខ្ពស់សម្រាប់បង្រៀនមុខជំនាញពាណិជ្ជកម្មធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧២ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សាស្ត្រ ខ្ញុំបានចាប់ផ្តើមធ្វើការនៅធនាគារខ្មែរពាណិជ្ជ និងបង្ហាត់យូដូផង។

ខ្ញុំមិនមានគ្រួសារ ឬអ្នកជិតខាងណាណែនាំខ្ញុំឡើយ ដូចនេះខ្ញុំប្រាកដណាស់ដឹងអំពីការរស់នៅ និងយល់ថាខ្ញុំត្រូវតែធ្វើអ្វីៗទាំងអស់ជាការចាំបាច់ដើម្បីរស់។ ខ្ញុំមិនមានសំណាងអ្វីឡើយក្នុងការរស់នៅ ប៉ុន្តែខ្ញុំជាមនុស្សប៉ិនប្រសប់។ ខ្ញុំខិតខំប្រឹងប្រែង ដើម្បីអនាគត និងបន្តប្រឹងប្រែងទៀតនៅពេលដែលខ្ញុំជាប់ឃុំឃាំង។

នៅថ្ងៃទី១៧ មេសា ១៩៧៥ ខ្ញុំនៅធនាគារកំពុងរៀបចំឯកសារ។ ពេលនោះសហការីរបស់ខ្ញុំ និងខ្ញុំបានដឹងថាមានរឿងចម្លែកៗ យើងក្រឡេកមើលទៅខាងក្រៅឃើញយោធាស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ មួរជើងខោខាងស្តាំ និងមានកាន់អាវុធ។ យោធាទាំងនោះបានចូលក្នុងធនាគារ ហើយបានបាញ់ និងបង្ខំបុគ្គលិកធនាគារទាំងអស់ឲ្យចេញទៅខាងក្រៅ។ បុគ្គលិករបស់ខ្ញុំជាច្រើននាក់ និងខ្ញុំបានចាកចេញដោយមិនបានចាក់សោរបន្ទប់ឡើយ។

នៅតាមផ្លូវចេញពីទីក្រុង ខ្មែរក្រហមបានប្រកាសតាមមេក្រូថា "អង្គការត្រូវការអ្នកមានចំណេះដឹងអ្នកបច្ចេកទេស និងរដ្ឋការជាន់ខ្ពស់ពីរបបលន់ នល់ ដើម្បីជួយកសាងទីក្រុងឡើងវិញ។ វាត្រូវការពេលវេលាដើម្បីរៀបចំប្រទេសឡើងវិញ"។ ប្រជាជនជាច្រើននាក់ មានបុរសស្ទើរទាំងអស់បានចុះឈ្មោះ។ ខ្មែរក្រហមបានផ្តល់ឲ្យអ្នកទាំងនោះមានជា អង្ករ ត្រីងៀត សាច់ជ្រូក និងនំប៉័ង ដើម្បីលើកទឹកចិត្តពួកគេឲ្យចុះឈ្មោះ។

ខ្ញុំបានចំណាយពេលមួយខែបន្ទាប់មកនៅក្នុងវត្តមួយនៅស្រុកកៀនស្វាយ ការអស់សង្ឃឹមបានកើនឡើងរាល់ថ្ងៃ។ នៅពេលរដូវភ្លៀងបានចាប់ផ្តើម ខ្មែរក្រហមបានចាប់ផ្តើមបែងចែកប្រជាជន។ អ្នកខ្លះស្នាក់នៅធ្វើការនៅតាមវាលស្រែ ខណៈដែលអ្នកមានសាច់ញាតិនៅតាមខេត្តបានចេញទៅ។ គ្រួសារអ្នកមានជនជាតិចិនខ្លះដែលរស់នៅក្រុងភ្នំពេញជានិរន្តរ៍ ហើយមិនមានកន្លែងណាត្រូវទៅនោះ បានបើករថយន្តរបស់ខ្លួនចូលក្នុងទន្លេសម្លាប់ខ្លួនឯង។

ខ្ញុំមិនមានទីកន្លែងដែលត្រូវទៅទេ ខ្ញុំក៏បានធ្វើដំណើរឆ្លងទន្លេអ្នកលឿង។ នៅព្រំប្រទល់ខេត្តព្រៃវែង និងខេត្តស្វាយរៀង ខ្ញុំបានសម្រេចចិត្តបោះដុំថ្មមួយដុំឡើងទៅលើ។ ប្រសិនបើដុំថ្មធ្លាក់ចុះមកដី ឈរត្រង់ ខ្ញុំនឹងធ្វើដំណើរឆ្ពោះទៅតំបន់ខាងកើត និងប្រសិនបើថ្មធ្លាក់មកមិនត្រង់ ខ្ញុំនឹងធ្វើដំណើរឆ្ពោះទៅតំបន់ខាងជើង។ ដុំថ្មនោះបានធ្លាក់ចុះមកក្រោមត្រង់ ដូចនេះ ខ្ញុំបានងាកទៅខាងកើត។

នៅពេលដែលខ្ញុំមកដល់ឃុំកំពង់សិង្ហ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនទាំងអស់អង្គុយពេញមួយថ្ងៃ ដោយមិនមានអាហារ ឬទឹកដឹកឡើយ។ បន្ទាប់មកខ្មែរក្រហមបានចាប់ផ្តើមស្រង់ជីវប្រវត្តិរបស់ប្រជាជន។ ខ្ញុំបានសម្រេចចិត្តប្រាប់គេថា ខ្ញុំជានិស្សិត។

ខ្ញុំបានជ្រើសយកឈ្មោះដែលអ្នកសុំខ្ញុំធ្វើជាកូនចិញ្ចឹម ហើយបានដាក់ឈ្មោះឲ្យខ្ញុំថា គង់ មារតីភក្តី។ ឈ្មោះខ្មែរមានតែមួយ ឬពីរពាក្យប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងរបប ប៉ុល ពត ប្រសិនបើអ្នកមានឈ្មោះវែង វាមានន័យថាអ្នកមិនមែនបុគ្គលខ្មែរ [កសិករ] ទេ និងត្រូវស្លាប់។ ដូច្នេះតាំងពីពេលនោះមក ខ្ញុំបានប្រើឈ្មោះគង់ មារតី ប៉ុណ្ណោះ។

ថ្ងៃបន្ទាប់មក យោធាខ្មែរក្រហមបាននិយាយថា យើងត្រូវការរៀនសូត្រឡើងវិញ។ កម្មាភិបាលសក់រួញម្នាក់បានប្រកាសថា "មិត្តទាំងអស់គ្នា មានសំណាងហើយ។ អង្គការចង់អប់រំអ្នកទាំងអស់គ្នា។ មិនបាច់យករបស់ប្រើប្រាស់ផ្ទាល់ខ្លួនទៅជាមួយទេ អង្គការមានអ្វីៗគ្រប់យ៉ាងដែលអ្នកត្រូវការ"។ យើងត្រូវបានដាក់ឲ្យដើរក្នុងជួរជាច្រើនជួរ ដោយមានយោធាប្រដាប់អាវុធម្នាក់ដើរពីក្រោយជួរនីមួយៗ។ បន្ទាប់មក ខ្មែរក្រហមបានយកយើងទៅមន្ទីរសន្តិសុខពងទឹក នៅខេត្តព្រៃវែង។ បន្ទាប់មកបានស្រង់ជីវប្រវត្តិរបស់យើងម្តងទៀត ខ្មែរក្រហមបានដាក់យើងនៅក្នុងការិយាល័យមួយនិងចាក់សោទ្វារពីខាងក្រៅ។ នៅខាងក្នុងនោះមានតែកេសគ្រាប់រំសេវលោហៈមួយ ដែលយើងអាចប្រើជាបង្គន់។ បន្ទាប់មកខ្ញុំដឹងថា ខ្ញុំបានជាប់អន្ទាក់ហើយ។

នៅក្នុងមន្ទីរសន្តិសុខនោះមានអ្នកទោស ៥១៨នាក់ ដែលអ្នកទាំងនោះជាអតីតនិស្សិត គ្រូបង្រៀន និងទាហានលន់ នល់។ នៅពេលយប់យើងម្នាក់ៗដេកផ្ទុយគ្នា។ ជើងរបស់យើង ជាប់ច្រវាក់ភ្ជាប់ជាមួយនឹងដែកសរសៃវែងមួយដែលចាក់សោនៅខាងចុង។ ខ្ញុំបានជាប់នៅទីនោះចំនួន១០ថ្ងៃ អង្គការបានបញ្ជូនចេញអ្នកដែលមានឋានៈខ្ពស់ ខណៈដែលអ្នកផ្សេងទៀតត្រូវបានបញ្ជូនទៅធ្វើការ។ ខ្ញុំបានធ្វើការនៅផ្នែកកសាងផ្លូវថ្នល់ មានអ្នកទោសចំនួន ៥០នាក់។ យើងដើរទៅការដ្ឋានរបស់យើងក្នុងរយៈពេលមួយម៉ោង ជាទីកន្លែងដែលយើងកាប់ដីរាល់ថ្ងៃពីម៉ោង ៥ព្រឹក ទៅដល់ថ្ងៃត្រង់ បន្ទាប់មកពី

ម៉ោងមួយរសៀល ដល់ម៉ោង៦ល្ងាច ទើបយើងអាចបានហូបបាយ។ អ្នកទោសទាំងអស់បានធ្វើការយ៉ាងខ្លាំង ទាំងយប់ទាំងថ្ងៃ ព្រោះអង្គការបានប្រកាសថា នៅពេលយើងបញ្ចប់ការសាងសង់ផ្លូវ អង្គការនឹងដោះលែងយើង។

ប៉ុន្តែខ្មែរក្រហមបានកុហកយើង ហើយការសង្ឃឹមរបស់យើងលែងមានទៀតដែរ។ ជំនួសឲ្យការដោះលែងយើង ខ្មែរក្រហមបានបញ្ជូនយើងទៅការដ្ឋានថ្មីមួយទៀតដើម្បីជីកប្រឡាយ។ ពេលនេះជារដូវវស្សា យើងបានដេកនៅក្បែរប្រឡាយ ខ្ញុំអស់កម្លាំងជាខ្លាំង និងបានដេកលក់នៅពេលភ្លៀង។ ខ្មែរក្រហមបានបន្ថយរបបអាហាររបស់យើង អ្នកទោសជាច្រើននាក់បានធ្លាក់ខ្លួនឈឺធ្ងន់ និងស្លាប់ដោយសារធ្វើការច្រើនជ្រុល។

បន្ទាប់មកខ្ញុំត្រូវបានបញ្ជូនឲ្យទៅរកបន្លែសម្រាប់សហករណ៍ និងទទួលបានអាហារប្រសើរជាងមុន។ នៅពេលយប់ ខ្ញុំម៉ាស្សាឲ្យប្រធានដាំស្ល និងអ្នកដាំស្លផ្សេងទៀត នៅក្នុងកងជាថ្នូរនឹងអាហារបន្តិចបន្តួច។ ខ្ញុំព្យាយាមអស់ពីសមត្ថភាព ដើម្បីយកចិត្តអ្នកទាំងនោះ និងបានប្រាប់អង្គការថា ខ្ញុំជាអ្នកម៉ាស្សា។ នៅពេលដែលខ្ញុំរស់នៅក្រុងភ្នំពេញ ខ្ញុំជាគ្រូបង្ហាត់យូដូម្នាក់ ដូច្នេះខ្ញុំស្គាល់ប្រព័ន្ធរបស់តួខ្លួនមនុស្ស។ យប់មួយនោះបុរសម្នាក់បានប្រាប់ថា អង្គការចង់ជួបខ្ញុំ។ ខ្ញុំភ័យខ្លាចជាខ្លាំង។ នៅពេលដែលខ្ញុំបានដើរចូលទៅក្នុងការិយាល័យនោះ មេខ្មែរក្រហមបានឲ្យខ្ញុំធ្វើម៉ាស្សា ញីប្រាច់កែងជើងរបស់គាត់។ ខ្ញុំបានញីប្រាច់យ៉ាងខ្លាំង និងលាបប្រេងខ្លាញ់ពស់លាយនិងដេះធ្យូងលើកែងជើងរបស់គាត់។ បន្ទាប់មកខ្ញុំបានឆ្កិះតម្រង់ឆ្អឹងឲ្យចូលក្នុងជួរឆ្អឹងវិញ។ បន្ទាប់ពីនោះមក ខ្មែរក្រហមបានផ្តល់ឲ្យខ្ញុំនូវរបបអាហារពេញលេញ។

នៅចុងឆ្នាំ១៩៧៦ នៅពេលដែលយើងបញ្ចប់ជីកប្រឡាយ អង្គការបានហៅឲ្យទៅចូលរួមប្រជុំមួយ និងបានដោះលែងអ្នកទោសជាច្រើនអ្នកនៅមន្ទីរសន្តិសុខ ដោយមានស្ត្រីជាច្រើននាក់ ប៉ុន្តែពួកយើងដែលនៅសល់ត្រូវបានបញ្ជូនទៅការដ្ឋានសំណង់ថ្មីមួយទៀតនៅក្នុងខេត្តព្រៃវែង។ យើងបានដើរទៅទីនោះតាមផ្លូវជាតិលេខ១១។ បុរសជាច្រើននាក់មានការសប្បាយរីករាយ ព្រោះគាត់មិនបានឃើញផ្លូវជាតិជាយូរមកហើយ។ យើងបានដើរជាជួរ ប្រសិនបើអ្នកណាម្នាក់ឈានចេញក្រៅជួរ អ្នកនោះនឹងត្រូវបានវាយដំ។ ការងាររបស់យើងនៅការដ្ឋានថ្មីនោះ គឺសង់ទំនប់ទឹកស្តុកទឹកសម្រាប់ស្រោចស្រពវាលស្រែ ធ្វើការនៅកន្លែងចិញ្ចឹមសត្វពាហនៈ ភ្ជួរស្រែ និងជីកប្រឡាយ។ ខ្មែរក្រហមបានវាយយើង នៅពេលយើងឈប់សម្រាកអ្នកមើលការខុសត្រូវបានសើច និងឲ្យអ្នកជាប់ទោសរាប់ចំនួនដងដែលត្រូវវាយ។ អ្នកមើលការខុសត្រូវនោះបានវាយដំអ្នកទោសពីរនាក់រហូតដល់ស្លាប់ដោយសារជីកទឹកប្រឡាយ។ យោធាខ្មែរក្រហមបានវះយកថ្លើមរបស់អ្នកទោសយកមកចម្អិនហូប។

ខ្ញុំស្ទើរតែស្លាប់ដោយសារអត់ឃ្លាននៅការដ្ឋាននោះ។ ពេលខ្លះខ្ញុំលួចចេញទៅរកចាប់កង្កែប ក្តាម ខ្យង និងកណ្តុរមកហូប។ ប៉ុន្តែខ្មែរក្រហមបានចាប់ខ្ញុំ និងវាយដំខ្ញុំជាមួយនឹងមែកឫស្សីទាល់តែហូរឈាម។

មានកើតសត្វរុយជាច្រើននៅឆ្នាំនោះ ដូចនេះនៅពេលដែលយើងហូបអ្វីៗ យើងត្រូវតែប្រយ័ត្ន បិទមាត់របស់យើង។ អ្នកទោសបានស្លាប់ម្តងមួយៗ អ្នកខ្លះស្លាប់នៅពេលដេក អ្នកខ្លះស្លាប់ក្នុងខណៈដែលកំពុងដើរ ខ្លះត្រូវបានប្រហារជីវិត និងអ្នកផ្សេងទៀតបានចងកសម្លាប់ខ្លួន។ អ្នកទោសខ្លះដោយមានការស្រេកឃ្លានខ្លាំង គាត់បានហូបសាកសព។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ អង្គការបានឲ្យយើងទាំងអស់គ្នាឈរមួយជួរ។ កម្មាភិបាលបាននិយាយថា អ្នកទោសស្ទើរតែទាំងអស់បានគោរព និងជឿជាក់លើអង្គការ អ្នកទាំងនោះនឹងត្រូវបានបញ្ជូនទៅមូលដ្ឋានវិញ។ ប៉ុន្តែនៅមានអ្នកទោស២០នាក់ទៀតដែលរៀនសូត្រមិនទាន់គ្រប់គ្រាន់នៅឡើយ។ ខ្ញុំស្ថិតនៅក្នុងចំណោមអ្នកទាំង២០នាក់នោះ។ ក្រោយមកខ្ញុំបានឮកម្មាភិបាលនិយាយថា អ្នកដែលបានដោះលែងនោះត្រូវបានសម្លាប់។

ក្រោយបន្តិចមក សន្តិសុខបានហៅអ្នកទោសទាំង២០នាក់ឲ្យឈរតម្រង់ជួរ។ រថយន្ត ៦គ្រឿង ដែលផលិតនៅប្រទេសចិនបានឈប់ ហើយយើងបានឡើងលើរថយន្តនោះ។ អង្គការបានប្រាប់យើងថា យើងមានសំណាងហើយដែលកំពុងបញ្ជូនត្រឡប់ទៅមូលដ្ឋានវិញ។ ខ្ញុំយំ ហើយគ្រប់គ្នាបានថ្លែងអំណរគុណដល់អង្គការ។ ខ្ញុំជាប់គុកអស់រយៈពេលមួយឆ្នាំប្រាំមួយខែ និងប្រាំមួយថ្ងៃ។ មានតែយើង២០នាក់គត់ដែលបានរស់រានមានជីវិតនៅក្នុងចំណោមប្រជាជន៥១៨នាក់នៅក្នុងគុក។

**បាង ពីច័ន្ទ និង ទេរី ខកហ្គៀល**





### «ផ្ទះផ្តល់ធូលី»
## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ប៊ួយ ស្រេង ៖ អ្នកបោះពុម្ព កាសែត

**ស្រេង ម៉ាប់ គ្រួចជាកូនប្រុសរបស់ ប៊ួយ ស្រេង បាននិយាយរៀបរាប់ពីប្រវត្តិរបស់ឪពុកថា៖**

នៅមុនពេលដែលខ្ញុំមិនទាន់កើត ឪពុករបស់ខ្ញុំបានធ្វើជាគ្រូបង្រៀននៅខេត្តពោធិ៍សាត់ ជាទីកន្លែងដែលគាត់ចាប់ចិត្តស្រឡាញ់ជាមួយម្តាយរបស់ខ្ញុំឈ្មោះ កង សុផាត។ ម្តាយខ្ញុំជាកូនស្រីរបស់អ្នកជំនួញ។ គាត់រៀនដល់ថ្នាក់មធ្យមសិក្សាទុតិយភូមិទី១ បន្ទាប់មកគាត់បានឈប់រៀន មកជួយលក់ដូរឪពុកម្តាយនៅក្នុងផ្សារ។



ប៊ួយ ស្រេង អាយុប្រហែល៤០ឆ្នាំ នៅពេលដែលគាត់កំពុងឃោសនារកសំឡេងឆ្នោតនៅក្នុងរបប លន់ នល់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កង សុផាត ភរិយារបស់ ប៊ួយ ស្រេង (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជីដូនរបស់ខ្ញុំ បានរៀបចំឲ្យឪពុកខ្ញុំយកប្រពន្ធថ្មីមួយទៀត នៅពេលដែលម្តាយរបស់ខ្ញុំបានពរពោះកូនទីពីរ។ ម្តាយរបស់ខ្ញុំ និងភរិយាថ្មីរបស់ឪពុកខ្ញុំបានសម្រាលកូនដំណាលគ្នានៅក្នុងថ្ងៃតែមួយ។

ខ្ញុំបានកើតនៅពេលឪពុកខ្ញុំកំពុងបង្រៀននៅខេត្តក្រចេះ។ ឪពុកម្តាយរបស់ខ្ញុំបានដាក់ឈ្មោះខ្ញុំថា ប៊ួយ សុមឆ្នា ប៉ុន្តែហៅថា ម៉ាប់ ពីព្រោះខ្ញុំធាត់កាលនៅពីក្មេង។ គ្រួសាររបស់យើងបានផ្លាស់ទីលំនៅ នៅពេលដែលឪពុករបស់ខ្ញុំផ្លាស់ទីកន្លែងបង្រៀន។ ឪពុកខ្ញុំបានផ្គត់ផ្គង់គ្រួសាររបស់យើងដោយប្រាក់បៀវត្សរ៍របស់គាត់ជាគ្រូបង្រៀន។

ឪពុករបស់ខ្ញុំឈប់បង្រៀននៅក្នុងរបប លន់ នល់ ហើយបានឈរឈ្មោះជាសមាជិកសភា។ បន្ទាប់មកគាត់ចាញ់ឆ្នោត ដូច្នេះយើងបានផ្លាស់ទីលំនៅទៅទីក្រុងភ្នំពេញវិញ។ នៅភ្នំពេញគាត់បានបើកក្រុម ហ៊ុនបោះពុម្ពមួយ និងសារព័ត៌មានមួយឈ្មោះ "ប្រយុទ្ធខ្មែរ" មានទីតាំងនៅទល់មុខពហុកីឡាដ្ឋានជាតិអូឡាំពិក ដែលបានបោះពុម្ពចែកចាយទូទាំងប្រទេស។ ឪពុករបស់ខ្ញុំជាវាគ្មិនដ៏ពូកែម្នាក់។ គាត់ចូលចិត្តនិយាយ និងសរសេរ។ បន្ទាប់មក គាត់បានជាប់ពន្ធនាគារមួយឆ្នាំ ដោយសារគាត់បានសរសេរអត្ថបទមួយប្រឆាំងទៅនឹងគោលនយោបាយរបស់ លន់ នល់។ ឪពុករបស់ខ្ញុំបានបើករោងពុម្ពឡើងវិញ បន្ទាប់ពីគាត់ត្រូវបានដោះលែងពីពន្ធនាគារ ហើយគាត់បានចាប់ផ្តើមសរសេរកាសែតមួយទៀតឈ្មោះ "សង្គ្រោះខ្មែរ"។ ការសែតនោះទើបតែបើកបានមួយសប្តាហ៍ប៉ុណ្ណោះ ក៏ត្រូវយោធាខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ។

មិត្តភក្តិរបស់ឪពុកខ្ញុំមួយចំនួនដែលរស់នៅប្រទេសអាមេរិក បានប្រាប់គាត់ឲ្យភៀសខ្លួនចេញពីប្រទេសកម្ពុជា ប៉ុន្តែគាត់បានបដិសេធ។ គាត់មានកូន៩នាក់ត្រូវចិញ្ចឹម និងបានរៀបចំពិធីមង្គលការឲ្យបងស្រីរបស់ខ្ញុំ។

នៅពេលដែលខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុង ខ្មែរក្រហមបាននិយាយថា អង្គការនឹងរៀបចំទីក្រុងភ្នំពេញឡើងវិញ ហើយប្រជាជនអាចវិលត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃ។

ដោយសារឪពុកខ្ញុំជាអ្នកការសែត ដូច្នេះគាត់ដឹងថា ប្រាកដជានឹងមានរឿងរ៉ាវកើតឡើងមិនខាន ហើយគាត់ក៏មិនមានជំនឿទៅលើខ្មែរក្រហមដែរ។

គ្រួសាររបស់ខ្ញុំបានរៀបចំរបស់របរផ្ទាល់ខ្លួនដាក់ក្នុងរថយន្តរបស់យើង ហើយបានបើកចេញទៅខេត្តព្រៃវែង។ នៅតាមផ្លូវ ខ្មែរក្រហមបានប្រកាសថា អ្នកដែលជិះឡានសុទ្ធតែពួកសក្តិភូមិ និងកេងប្រវ័ញ្ចញើសឈាមកម្មករ។ ខ្មែរក្រហមមិនបានអនុញ្ញាតឲ្យយើងបើកឡានទៅមុខទៀតទេ ដូច្នេះឪពុកខ្ញុំបានរុញឡានរបស់យើងចូលក្នុងទន្លេ ហើយយើងបានបន្តដំណើរដោយថ្មើរជើង។ ពីរថ្ងៃក្រោយមក គ្រួសាររបស់យើងបានទៅដល់ព្រៃវែង។ យើងបានញ៉ាំអាហារដែលយើងយកពីផ្ទះអស់ហើយ ដូច្នេះយើងយកខោអាវរបស់យើងទៅដូរយកអង្ករ។

នៅពេលដែលយើងទៅដល់ស្រុកកំណើតរបស់ឪពុកខ្ញុំ គាត់បានព្យាយាមលាក់អត្តសញ្ញាណរបស់គាត់ដោយនិយាយថា គាត់ជាកសិករ។ ឪពុកខ្ញុំចេះនេសាទត្រី ចេះធ្វើតុទូ និងចេះធ្វើស្រែចម្ការ ដូច្នេះវាមិនមានបញ្ហាអ្វីទេក្នុងខណៈនោះ។

នៅទីនោះ មានការច្រណែនយ៉ាងខ្លាំងរវាងប្រជាជនមូលដ្ឋាន និងប្រជាជន១៧ មេសា។ ឧទាហរណ៍គ្រប់ៗគ្នាគិតថា បានទទួលរបបអាហារស្មើៗគ្នា។ ប្រជាជនខ្លះ បានទទួលរបបអាហារដូចគ្នា ប៉ុន្តែជាទូទៅ ប្រជាជន១៧ មេសា បានទទួលរបបអាហារតិចជាងប្រជាជនមូលដ្ឋាន។

ម្តាយរបស់ខ្ញុំឆ្លងទន្លេបានកូនម្នាក់ទៀត នៅពេលនោះជាពេលដែលមិនមានថ្នាំពេទ្យសម្រាប់ព្យាបាលទេ គឺមានតែថ្នាំដែលប្រជាជនទូទៅហៅថា "ថ្នាំគ្រាប់អាចម៍ទន្សាយ"។ នៅទីនោះមិនមានការបណ្តុះបណ្តាលគ្រូពេទ្យបុរេជ្ជបណ្ឌិតទេ។ ម្តាយរបស់ខ្ញុំបានស្លាប់នៅពេលឆ្លងទន្លេ គាត់ហូរឈាមរហូតដល់ស្លាប់។ អង្គការមិនបានអនុញ្ញាតឲ្យឪពុកខ្ញុំបូជាសពម្តាយខ្ញុំទេ ដូច្នេះឪពុករបស់ខ្ញុំបានកប់សាកសពម្តាយខ្ញុំនៅក្នុងព្រៃ។ កូនប្រុសរបស់គាត់នៅមានជីវិត យើងបានដាក់ឈ្មោះថា សំណាង។ ដោយសារ សំណាង មិនមានទឹកដោះគោជៅ ឪពុករបស់ខ្ញុំបានស្នើសុំអ្នកភូមិឲ្យយក សំណាង ទៅចិញ្ចឹម។ គ្រួសារមួយនោះ បានយកសំណាង ទៅចិញ្ចឹម ហើយបានស្រឡាញ់វាយ៉ាងខ្លាំង និងចាត់ទុកវាថាជាកូនបង្កើតរបស់ខ្លួនទៀត។

នៅឆ្នាំ១៩៧៦ បុរសម្នាក់ឈ្មោះ លឿត បានលួចធ្វើឃាតប្រធានភូមិម្នាក់យ៉ាងសម្ងាត់។ អង្គការ មិនអាចរកឃើញអ្នកលួចធ្វើឃាតនោះទេ ដូច្នេះអង្គការបានស្នើឲ្យឪពុកខ្ញុំ និងបុរសផ្សេងៗទៀតនៅក្នុងភូមិផ្លាស់ទីលំនៅទៅកន្លែងផ្សេងៗ បុរសជាច្រើននាក់បានចាប់ឪពុកខ្ញុំយកទៅក្នុងយប់នោះ។ ឪពុកខ្ញុំពាក់អាវឆ្នូត និងប៉ង់កក្រម៉ា។

ខ្ញុំគិតថា ឪពុកខ្ញុំនឹងមានរឿងរ៉ាវមិនល្អកើតឡើងចំពោះគាត់មិនខាន ដោយសារអ្នកភូមិជាច្រើនបានដឹងថា គាត់ធ្លាប់ធ្វើការនៅក្នុងទីក្រុងភ្នំពេញ។ គាត់បានប្រាប់យើងថា ឲ្យរត់គេចចេញពីភូមិ ប្រសិនបើគាត់មិនត្រឡប់មកវិញ ហើយឲ្យថែរក្សារូបថតរបស់គ្រួសារដែលខ្ញុំលាក់ទុកក្នុងក្រឡមួយមានគ្របសំរាមពីលើ។ ខ្ញុំគិតថា គាត់ស្លាប់ហើយ ហើយយើងក៏មិនបានឃើញគាត់ម្តងទៀតដែរ។

**ប៉ាង ពីរ័ន្ត និង ខេនី ខករហ្គៀល**



កង សុជាត និងកូន៣នាក់របស់គាត់ នៅឆ្នាំ១៩៦០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









# ព្រឹត្តិការណ៍ ថ្ងៃ១៥មេសា

## ឧក្រិដ្ឋកម្មមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## កៅ សំរិទ្ធ (តពីលេខមុន)

ភូមិឆ្ងល់គ្រប់គ្នា

សមមិត្តស៊ឹម ជាអ្នកភូមិគោកធ្លក ទើបបានជាស្គាល់មនុស្សច្រើន។ គាត់ឃើញតាឈឹម និងអ្នកមូលដ្ឋានចាស់ទាំងអស់ដែលអង្គុយជុំគ្នា ដូចជាតាយ៉េក, តាឃឹម, តាស៊ីង, តាសាគី, តាកង។ល។ ក៏ណែនាំឲ្យអ្នកទាំងអស់នោះទៅអង្គុយនៅម្លប់ស្វាយខាងត្បូងព្រះវិហារ ប្រមាណ៥០ម៉ែត្រពីអ្នក១៧មេសា។ យុវជនារី(ឡៅ សុភារី) អាយុ១៧ឆ្នាំដែលជាអ្នក១៧មេសា បានប្រថុយបន្លំខ្លួនទៅអង្គុយជាមួយអ្នកមូលដ្ឋានចាស់ ហើយគ្មានអ្នកណាដេញចេញដូចកាលនៅភូមិត្រពាំងវែងទេ។ នៅទីនោះ ពួកយោធាស្រាយចំណងឲ្យរួចបែកថ្នាំឲ្យជក់ បន្ទាប់មកមានកម្មាភិបាលម្នាក់បាននិយាយសម្រួលសតិអារម្មណ៍អ្នកទាំងនោះថា «សូមកុំអន់ចិត្តអន់ថ្លើមនឹងអង្គការដែលបានចាប់ចងអ្នកទាំងអស់គ្នាអីអង្គការរកមុខតែអ្នកប្រឆាំងនឹងបដិវត្តន៍ប៉ុណ្ណោះ សូមអ្នកទាំងអស់គ្នាទៅផ្ទះវិញចុះ»។ នៅតាមផ្លូវទៅផ្ទះ អ្នកភូមិដែលឃើញពួកគាត់ដើរចេញពីវត្តក៏សាកសួរចង់ដឹង ថាមានអ្វីកើតឡើងតែគ្មានរណាឆ្លើយទេ ដើរឱនមុខដូចគ្មានវិញ្ញាណនៅក្នុងខ្លួន។ មានតែយុវជនប៉ោង(កូនតាកង) ទេដែលសើចឃឹកៗដូចគ្មានរឿងភិតភ័យអ្វីទាំងអស់។

នៅឯទីធ្លាវត្ត ពួកពេជ្ឈឃាតចាប់



កៅ សំរិទ្ធ

ផ្តើមចងភ្ជាប់ជនរងគ្រោះមួយក្រុមពី៣ទៅ៥នាក់ បណ្តើរទៅសម្លាប់ម្តងមួយក្រុមៗ ដែលនៅមិនឆ្ងាយប៉ុន្មានពីកន្លែងដែលជនជាប់ចំណងអង្គុយ គឺពួកគាត់អាចមើលឃើញការប្រល័យដោយផ្ទាល់ភ្នែក។ ដោយសារតែការភិតភ័យព្រោះការប្រល័យនោះមានភាពសាហាវឃោរឃៅពន់ពេក អ្នកដែលរួចជីវិតហេតុការណ៍នោះមានការចងចាំខុសគ្នាពីរបៀបពួកវាសម្លាប់ដូចខាងក្រោម ៖

- អាវ.កសម្លាប់ជនរងគ្រោះម្នាក់ម្តងៗ ហើយរាល់ពេលជនរងគ្រោះនីមួយៗ ត្រដរខ្យល់ដួល វាកាត់ផ្តាច់ខ្សែចំណងចេញ រួចចាត់ការអ្នកបន្ទាប់ៗទៀត។
- អាវ.កសម្លាប់ម្តងម្នាក់ៗដោយមិនកាត់ផ្តាច់ចេញពីចំណងរួម។
- យកគល់ឬស្សីដងផ្គាក់ (ប្រវែងប្រមាណ១ម៉ែត្រ ដែលនៅមិនទាន់ជាប់បញ្ចុះផ្លែផ្គាក់នៅឡើយ)វាយសំពងជនរងគ្រោះឲ្យដួលសិន ទើបយកកាំបិតអាវ.កសម្លាប់ជាក្រោយ។
- យកធាងត្នោតដែលមានបន្លាអាវ.កសម្លាប់។

មានយុវជនម្នាក់ឈ្មោះ ឆេកាំង ដែលជាអ្នកភូមិថ្នល់ បានរត់ទាំងចំណងរួចពីការប្រល័យ ៖ គាត់ត្រូវបានពួកឃាតកចងមួយខ្សែជាប់គ្នាសរុប៥នាក់ ហើយប្រើវិធីទី១ ដូចរៀបរាប់ខាងលើ គឺសម្លាប់ហើយផ្តាច់ចំណងចេញម្នាក់ម្តងៗ។ ឆេកាំងគឺជាជនទី៥ដែលនឹងត្រូវសម្លាប់។ នៅពេលដែលជនរងគ្រោះទី៤ ត្រូវបានពេជ្ឈឃាតអាវ.ក និងផ្តាច់ចំណងចេញពីគាត់ ឆេកាំងក៏រត់គេចខ្លួនទាំងដៃជាប់ចំណងស្ទាបសេកកាត់តាមគុម្ពោតព្រៃតាមវាលស្រែទៅទិសខាងកើត។ ពួកយោធាដែលកំពុងយាមអ្នកជាប់ចំណងក្នុងទីធ្លាវត្តក៏ស្ទុះរត់ទៅដេញបាញ់។ រត់បានចម្ងាយប្រមាណ ៣០០ ៤០០ម៉ែត្រ ក៏ឃើញគាត់ដួល ពួកវាគិតថាគាត់ត្រូវគ្រាប់ ហើយក៏វិលត្រឡប់មកកន្លែងដើមវិញដោយប្រញាប់ទៅយាមអ្នកជាប់ចំណងនៅឯក្នុងវត្ត។ តាមពិត ឆេកាំង ដួលដោយសារគាត់រត់ធ្លាក់ក្នុងអន្លង់ដែលគេជីកក្តាមទេ។ នៅពេលដែលពួកយោធា

វិលត្រឡប់ទៅវិញ គាត់ក្រោករត់ទៅ
ដល់ភូមិម្នាក់ដែលនៅប្រមាណ ៣
គីឡូម៉ែត្រពីទីនោះ ហើយបានអ្នកភូមិ
ជួយស្រាយចំណងដោយក្តីអាណិត
អាសូរជាទីបំផុត។

ក្នុងអំឡុងពេលដែលពួកវាកំពុងរត់
ដេញបាញ់ ឆេកាំងនោះ មានយុវជន
ជាប់ចំណងម្នាក់និយាយបបួលមិត្តភក្តិ
នៅជិតៗខ្លួនថា «នេះជាឱកាសល្អ
សម្រាប់យើងគេចខ្លួនហើយ ទាន់ពួកវា
មិននៅក្បែរ» តែគ្មានអ្នកណាប្រថុយ
រត់តាមគាត់បបួលទេដោយនៅតែ
សង្ឃឹមថា គេនឹងមិនសម្លាប់មនុស្ស
ដែលគ្មានកំហុសឡើយ។ យុវជនដែល
បបួលគេនោះ ក៏ជឿតាមមិត្តភក្តិ សុខ
ចិត្តនៅរង់ចាំយុត្តិធម៌ ដូចរង់ចាំក្តី
មរណៈទាំងអស់គ្នា។

នៅពេលដែលត្រឡប់មកពីដេញ
បាញ់ឆេកាំងវិញ ពួកយោធាអាវខ្មៅ
ក៏វិលត្រឡប់មកកន្លែងមនុស្សជាប់
ចំណង និងបន្តការប្រល័យ។ ពេជ្ឈឃាត
មួយក្រុមប្រមាណ៥-៦នាក់ប្រើកាំបិត
ត្នោត២-៣ (ប្រហែលជាកាំបិតត្នោត
ដែលពួកវារឹបយកពីអ្នកឡើងត្នោត
នៅភូមិត្រពាំងវែង)សម្រាប់អារ.ក។
នៅរាល់ពេលដែលពួកវាត្រឡប់ពីលាន
ពិឃាតមកយកជនរងគ្រោះផ្សេងៗ
ទៀតដែលកំពុងអង្គុយជុំគ្នា ដៃវាកាន់
កាំបិតដែលប្រឡាក់ឈាម សួរថា
«អ្នកណាទៀត?» (មានន័យថាអ្នកណា
ចង់ទៅស្លាប់នៅវេននេះ?) គ្រប់ៗគ្នា
ឱនមុខចុះ និងភ័យរន្ធត់ឥតខបមា។

យុវជនជម្លៀសពីកំពង់គ្រីម្នាក់ឈ្មោះ
ហ៊ីងដែលជាប់ចំណងម្នាក់ឯងឆ្ងាយ
ពីគេបន្តិច មិនដឹងថាពួកអាវខ្មៅខឹងពី
រឿងអ្វី បានជាចាក់គាត់នឹងកាំបិត
ចំពុះទុង ធ្លាយពោះវៀនទ្រូល ឈាម
ដោកដី ប្រកាច់ស្លាប់យ៉ាងវេទនា។

យុវជនក្លាហានម្នាក់ ដែលកំពុងត្រូវ
ពេជ្ឈឃាតបណ្តើរយកទៅប្រហារបាន
ស្រែកសុំទៅពួកវាថា «ស្តាយណាស់
ដែលមិនបានរស់នៅធ្វើបដិវត្តន៍បន្ត
ទៀត។ សូមមិត្តកុំធ្វើបាបខ្មែរគ្នាឯងអី»។
គាត់ត្រូវពួកវាប្រហារនៅផ្លូវរទេះខាង
ជើងសាលាឆាន់។

បងរិនដែលជាអ្នកជម្លៀសមកពី
កំពង់គ្រី ជាប់ចំណងជាមួយសាច់ញាតិ
ម្នាក់ឈ្មោះ ជិន និងបុរសម្នាក់ឈ្មោះ
ម៉ែ។ ពេលកំពុងតែស្លុតចិត្តនឹងការ
ប្រហារ ជាពិសេស តក់ស្លុតនឹងការស្លាប់
របស់យុវជន ហ៊ីង នៅក្បែរនោះ គាត់
បានឃើញសមមិត្ត ស៊ឹម ដើរចូលទៅ
ហើយនិយាយជាមួយយោធាម្នាក់ទៀត
(ប្រហែលជាសមមិត្ត បើន) និងសម្លឹង
មកគាត់។ បងរិន នឹកថាដល់វេន
គេយកគាត់ទៅសម្លាប់ហើយ តែបែរ
ជាឃើញពួកយោធាស្រាយចំណង
ឲ្យទាំងបីនាក់ ហើយដេញថា«ទៅៗ»។
គាត់គិតក្នុងចិត្តថាប្រហែលជាវាប្តូរ
វិធីសម្លាប់ដោយឲ្យមនុស្សដើរចេញ
ហើយបាញ់ពីក្រោយ។ សឹងតែគ្មាន
ព្រលឹងនៅក្នុងខ្លួន ពួកគាត់នាំគ្នាដើរ
ផងរត់ផងសំដៅទៅផ្ទះដែលនៅខាង
លិចវត្ត ត្រចៀកផ្ទៀងស្តាប់ស្នូរកាំភ្លើង
ជានិច្ច ទាល់តែទៅដល់ផ្ទះទើបជឿថា
នេះជាការដោះលែងពិតមែន។ គាត់
យល់បានថា ហេតុអ្វីទើបមានការ
ដោះលែង នោះគឺមកពីសមមិត្ត ស៊ឹម
ស្គាល់ឪពុកគាត់ (ជាងទង់) ដែលជា
ជាងកង់នៅកំពង់គ្រីតាំងពីសង្គមចាស់
ជម្លៀសមកនៅភូមិតាភ្វា ជាមួយ
នឹងសោ/គ្រឿងបន្លាស់កង់មួយចំនួន។
ជារឿយៗ កម្មាភិបាលខ្មែរក្រហមរួម
ទាំងសមមិត្តផង តែងយកកង់មក
ឲ្យគាត់ជួសជុល។

ឯបងរតន៍វិញ ដែលកំពុងអង្គុយ
ជាប់ចំណង នៅពេលឃើញសមមិត្ត
បើនដើរមកជិតក៏ហៅថា «បង! ខ្ញុំអត់
មានបានធ្វើអីនឹងគេទេ នៅធ្វើការឯទំនប់
ម្កាក់ដូចបងធ្លាប់ឃើញហើយ»។
សមមិត្ត បើន សម្លឹងមុខ ក៏សួរបញ្ជាក់
ថា «មិត្តឯងដែលតែងជាំបាយឲ្យ
ខ្ញុំហូបមែនទេ?» បងរតន៍ឆ្លើយថា
«បាទ»។ បើន ក៏ស្រាយចំណងឲ្យ
និងនិយាយថា «ទៅផ្ទះចុះ អង្គការ
រកមុខតែជនក្បត់ទេ»។ នៅពេលដែល
គាត់ទៅដល់ផ្ទះបងរិន ហើយបងរតន៍
ក៏ស្នាក់នៅទីនោះបន្តដោយមិនទាន់
ហ៊ានទៅផ្ទះម្នាក់ឯងទេ។ អ្នកផ្ទះគាត់
មានការបារម្ភយ៉ាងខ្លាំងពីការបាត់
ខ្លួនសមាជិកគ្រួសារក៏ឲ្យរ៉ូន និងគ្នីគ្នា
២៣នាក់ ទៅលួចមើល ថាមានអ្វីកើត
ឡើងនៅវត្ត។ ដោយគាត់ដើរកាត់
តាមវាលស្រែ ទើបបានជាជួសគ្នា
ជាមួយបងរតន៍ ដែលកំពុងស្នាក់នៅ
ផ្ទះបងរិន។ គឺជាសំណាងល្អណាស់ដែល
នៅពេលសារ៉ូន មកដល់ ពួកឃាតក
បានចាកចេញផុតពីវត្តបាត់ទៅហើយ។
សារ៉ូន បានប្រទះឃើញសាកសពដែល
ត្រូវបានប្រហារនៅផ្លូវរទេះក្បែររបង
វត្តខាងជើងសាលាឆាន់ មើលស្គាល់
ថាជាសាកសពបងមុនី បងសិ បងប្រុច
បងថៃ បងវននិងអ្នកខ្លះទៀតដែលគាត់
មិនស្គាល់។ រឿងដែលអាណោចអធ័ម
គឺនៅក្បែរសាកសពឃើញមានធាង
ត្នោតមួយកំណាត់ដែលមានប្រឡាក់
ឈាមដោកជាំ ដែលប្រាកដជាត្រូវបាន
ពួកឃាតកយកទៅអារ.ក សម្លាប់
ពួកគាត់។ សពយុវជនមាឌធំម្នាក់ក្នុង
ចំណោមនោះ មានការប្រកាច់ធាក់
ជើងយ៉ាងយូរទំរាំតែស្លាប់ ទើបបានជា
កែងជើងរបករបាញខ្លាំង ហើយដីនិង
ស្មៅជុំវិញជើងគាត់ក៏ទក់ខ្ទេចខ្ទី។
ដោយមានការបារម្ភថាបងរតន៍ស្ថិត
នៅក្នុងចំណោមសាកសព សារ៉ូនបាន
ដើរទៅរកមើលនៅកន្លែងផ្សេងៗទៀត
ប្រទះឃើញសាកសពប្រមាណ៤០-
៥០នាក់ នៅម្តុំស្រះគោកខ្មោចខាងកើត
វត្ត មួយចំនួនទៀតនៅខាងជើងព្រះ
វិហារក្បែរដើមពោធិ៍ តែមិនឃើញបង
រតន៍ទេ។ សារ៉ូនចាប់ផ្តើមមានសង្ឃឹម
ខ្លះៗ ហើយនៅពេលត្រឡប់មកផ្ទះវិញ
ដោយដើរកាត់តាមភូមិក៏ប្រទះឃើញ
បងរតន៍នៅឯផ្ទះបងរិន។

លោកឈាង ដែលជាអតីតគ្រូ
បង្រៀនម្នាក់មានផ្ទះនៅមិនឆ្ងាយប៉ុន្មាន
ពីរបងវត្តប៉ែកខាងត្បូង ជាអ្នកដែល
ពួនក្នុងផ្ទះលួចមើលឃើញសកម្មភាព
អារ.កសម្លាប់ជនរងគ្រោះពីដើមដល់
ចប់។ គាត់មើលឃើញថា សមមិត្តអ៊ិន
ត្រូវគេយកទៅចងនឹងដើមស្វាយព្រៃ
ទុកមួយរយៈ ហើយត្រូវពួកអាវខ្មៅ
យកទៅសម្លាប់ក្រោយគេបង្អស់។

នៅពេលដែលឃើញពួកឃាតក
បើកឡានចេញទៅមួយសន្ទុះធំហើយ
នោះ លោកខ្វត ឈឿន ដែលបាន
ទទួលដំណឹងតាមរយៈការខ្សឹបខ្សៀវ
គ្នាថា សមមិត្តអ៊ិន ដែលត្រូវជាបងថ្លៃ
ត្រូវគេចាប់ចង ក៏បបួលអ្នកជិតខាង
២នាក់ទៀតទៅរកមើល ក៏ឃើញសព
គាត់នៅតែម្នាក់ឯងក្បែរដំបូកធំមួយ។
នៅពេលពួកគាត់កំពុងគិតគូរពីរឿងដឹក
រណ្តៅកប់សាកសព ស្រាប់តែឃើញ
ឡានហ្ស៊ីបរបស់ពួកកងការពារ
ត្រឡប់មកវិញ។ សមមិត្តធាដែលជា
មនុស្សស្គាល់គ្នាគំហកសួរគាត់ថា
«អ្អែងមករកអីនៅទីនេះ?» យោធាម្នាក់
ទៀតពោលថា «មុននេះបើសិនជាពួក
យើងពួនចាំមើលសិន អាចនឹងឃើញ
មានគ្នាវាមកថែមទៀត ដឹងតែឆ្ងាញ់
ដៃហើយ»។ ពួកពេជ្ឈឃាតទាំងនោះ
បានប្រើអ្នកភូមិឡើងបេះដូងឲ្យវា
ផឹកទឹក ហើយប្រមាណជាម៉ោង៤-៥
រសៀលទើបចាកចេញត្រឡប់ទៅ
កំពង់គ្រីវិញ។

ស្អែកឡើងទើបមានអ្នកភូមិដែល
នៅក្បែរៗវត្តនាំគ្នាទៅកប់សាកសព។
លោកសួស មី អាយុ៦៦ឆ្នាំ ជាអ្នកភូមិ
គោកធ្លកបានដើររាប់ឃើញសពទាំង
អស់ដល់ទៅ៧២នាក់ ច្រើនជាងនៅ
វាលពិឃាតត្រពាំងវែងដល់ទៅពីរដង
ឯណោះ។

**មហាទុក្ខសោករបស់គ្រួសារខ្ញុំ**

ក្នុងពេលដែលការដ្ឋានទំនប់
រហាលព្រួលកំពុងដំណើរការ រូបខ្ញុំនិង
មិត្តរួមការងារ២នាក់ទៀត គឺបងគិ
ដែលជាអ្នកជម្លៀសមកពីភ្នំក្រោម និង
កាំង (អ្នកកំពង់គ្រី) ត្រូវបានអង្គការ
ចាត់តាំងឲ្យទៅនេសាទត្រីនៅស្ទឹងកំបុត
ក្នុងភូមិសាស្រ្តស្រុកជីក្រែង ដើម្បីយក
ទៅផ្គត់ផ្គង់កងចល័តនៅឯការដ្ឋាន។
កាលនោះខ្ញុំទើបនឹងមានអាយុ១៧ឆ្នាំ
ប៉ុណ្ណោះ។ ពួកយើងបានដឹងពីព្រឹត្តិ-
ការណ៍បះបោរសម្លាប់សមមិត្ត ខេង
និងដឹងផងដែរថាបណ្តា ពលករកង
ចល័តត្រូវរំសាយវិលត្រឡប់ទៅភូមិ
វិញ។ គាប់ជួនគ្នានឹងផែនការពួកយើង
ដែលគិតថានឹងវិលត្រឡប់ទៅផ្ទះវិញ
ឪពុករបស់ កាំង បានបររទេះគោមក
យកកូនគាត់ទៅផ្ទះវិញដែរ ប៉ុន្តែដោយ
សារយើងរកត្រីបានដល់ទៅមួយបាត
ទូកឯណោះ ដែលសុទ្ធតែជាត្រីដំរីធំៗ
យើងក៏សម្រេចចិត្តស្នាក់នៅទីនោះមួយ
ថ្ងៃទៀតសិនដើម្បីឆ្អើរងាយស្រួលយក
ទៅផ្ទះ។ យើងមិនបានដឹងថាថ្ងៃ
ដែលយើងឆ្អើរត្រីនោះដែលជាថ្ងៃមហា
ប្រល័យនៅឯគោកធ្លកលើទេ។

បងគិ និងឪពុករបស់កាំងពិភាក្សា
គ្នា និងសម្រេចចាកចេញពីស្ទឹងកំបុត
នៅប្រមាណម៉ោង ៥ល្ងាចថ្ងៃទី១៥
មេសាដើម្បីឲ្យឆាប់បានទៅដល់ផ្ទះ
ពីព្រឹកបន្តិចនៅថ្ងៃបន្ទាប់។ យប់នោះ
ពួកយើងសម្រាកនៅក្រោមដើមអំពិល
ធំមួយដើមនៅភូមិមួយក្នុងសង្កាត់
ជីក្រែង ហើយប្រមាណជាម៉ោង៥ព្រឹក
ថ្ងៃបន្ទាប់ យើងចាកចេញសំដៅទៅ
ផ្ទះនៅឃុំគោកធ្លកលើ។ ខ្ញុំនិងបងគិប្តូរ
គ្នាជិះកង់ម្នាក់ម្តង ឯកាំងនិងឪពុកប្តូរ
គ្នាបររទេះគោ។ ពួកយើងទៅដល់ដើម
ភូមិខ្វាឃុំនៅពេលភ្លឺស្រាងៗ។ ឪពុក
កាំងកាន់ពូថៅដើរមុខរទេះ ខ្ញុំជិះកង់ពី
ក្រោយរទេះ ហើយបងគិ កាន់ពូថៅ
ដើរពីក្រោយកង់។ ទិដ្ឋភាពភូមិខ្វាឃុំ
ស្ងាត់ជ្រងំដូចគ្មានមនុស្សរស់នៅ តែ
ពួកយើងមិនបានចាប់អារម្មណ៍ទេដោយ
គិតថានៅពេលព្រឹកព្រលឹមពេក។
លុះទៅដល់ដើមភូមិត្រពាំងវែងនាពេល
ដែលថ្ងៃរះកំពស់ចុងឈើ ទើបយើងឆ្ងល់
តែរកសួរអ្នកណាមិនកើតដោយសារ
ភាគច្រើនទ្វារផ្ទះបិទ ប្តុបង្អើបតែបន្តិច
ប៉ុណ្ណោះ ហើយម្តងម្កាលឃើញមនុស្ស
អើតចេញងាកមើលឆ្វេងស្តាំតែមួយ
ភ្លែតក៏លឹបចូលក្នុងផ្ទះវិញ។ ទីបំផុត
នៅពេលដែលយើងហៀបនឹងដើរផុត
ចុងភូមិទៅហើយទើបខ្ញុំឃើញបុរស
អាយុប្រមាណជាង៤០ឆ្នាំម្នាក់ចុះពីផ្ទះ
មកដីប្រកបដោយទឹកមុខស្រងូត
ស្រងាត់។ ខ្ញុំក៏សួរគាត់ថា «ពូ! ម៉េចក៏
ស្ងាត់ម៉្លេះ?» គាត់សម្លឹងមើលផ្លូវទៅ
កំពង់គ្រីមួយភ្លែតទើបឆ្លើយថា
«ម្សិលមិញនៅឯស្ពានខាងមុខនោះ
ពួកមិត្តចាប់មនុស្សអារ.កស្លាប់ច្រើន
ណាស់ ឆាប់លាក់ពូថៅ ហើយប្រញាប់
ទៅផ្ទះទៅ ព្រោះបន្តិចទៀតបែបជាមក
ម្តងទៀតហើយ »។ ឮដូច្នោះពួកយើង
មានការភិតភ័យយ៉ាងខ្លាំង។ ឪពុក

កាំផ្លែផងបងកិយកពូថៅលាក់ក្រោមកន្ទេលដែលក្រាលរទេះ ហើយបំបោលគោស្រូតដំណើរឲ្យបានលឿនឆាប់ទៅដល់ផ្ទះ។

នៅពេលដែលខ្ញុំជិះកង់ទៅដល់ស្ពានទី២ ប្រមាណ២០-៣០ម៉ែត្រខាងឆ្វេងដៃ ខ្ញុំឃើញជញ្ជ្រាំងស្រូវទក់វល់មានមួកស្លឹកត្នោត និងក្រមាដែលដាច់រហែកនៅរាយប៉ាយ ហើយហួសពីទីនោះប្រមាណ៣០ម៉ែត្រនៅខាងស្តាំដៃ ខ្ញុំឃើញសាកសពបុរសម្នាក់ដាច់បំពង់កដេកផ្កាប់មុខ នៅចង្កេះមានស្រោមកាំបិតត្នោតសៀតនឹងខ្សែក្រវាត់។ ខ្ញុំមិនបានដឹងទាល់តែសោះថាសពលោកឪពុកស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីនោះ។

ទៅដល់ផ្ទះបងកិ នៅភូមិសង្កែ ពួកយើងចែកចាយរបស់របរគ្នា ខ្ញុំយកកូនបង្ហើចខោអាវ និងត្រីឆ្អើរមួយបាច់ស្ពាយដើរកាត់ព្រៃខាងក្រោយភូមិគោកធ្លកសំដៅទៅផ្ទះនៅឯភូមិតាភ្វា។ ខ្ញុំដើរចូលក្នុងផ្ទះដោយមិនបានស្រែកហៅពីចម្ងាយ ធ្វើឲ្យលោកយាយ និងអ្នកម្តាយភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ដោយក្តីត្រេកអរដោយសារឃើញខ្ញុំនៅមានជីវិត លាយនឹងទុក្ខសោកដោយសារបាត់ដំណឹងលោកឪពុក ពួកគាត់ស្ទុះមកឱបខ្ញុំជាមួយនឹងទឹកភ្នែកហូរសស្រាក់ យំរៀបរាប់ពីការបារម្ភដ៏ធំធេង។ ប្អូនៗខ្ញុំដែលនៅវ័យជំទង់នៅឡើយនាំគ្នាអង្គុយត្របោមក្បាលជង្គង់មានទឹកមុខស្រងូតស្រងាត់ព្រោះយល់បានពីទុក្ខសោករបស់គ្រួសារ លើកលែងតែប្អូនស្រីពៅ ម៉ាលី ដែលនៅតូចមិនទាន់ដឹងអីនៅឡើយ។

មួយសន្ទុះក្រោយមក លោកតាកៅ លួន ដែលមកពីភូមិខាងជើងលីចបចូលមកប្រាប់ខ្ញុំអោយនៅតែក្នុងផ្ទះកុំចេញទៅណា គាត់នឹងទៅកប់សាកសពនៅឯវត្ត ហើយស្វែងរកលោកឪពុកផងៗ គាត់ត្រឡប់មកវិញនៅវេលាថ្ងៃត្រង់ ហើយនិយាយប្រាប់លោកយាយថា មិនឃើញគាត់នៅទីនោះទេ (វត្តគោកធ្លក) ប្រហែលជានៅឯភូមិត្រពាំងវែងឯណោះៗ ទីបំផុតនៅថ្ងៃរសៀលយើងបានទទួលដំណឹងដ៏សោកសៅថា គេប្រទះឃើញសពគាត់នៅឯភូមិត្រពាំងវែង ហើយបានបញ្ចុះក្នុងផ្នូររួមជាមួយអ្នកដទៃទៀត។ ដំណឹងនោះធ្វើឲ្យពួកយើងយំម្តងទៀត ។ អ្នកម្តាយយំរៀបរាប់ពីអនុស្សាវរីយ៍កន្លងមក និងអំពីកូនស្រីពៅដ៏កំសត់ដែលនៅតូចមិនទាន់ស្គាល់ឪពុកនៅឡើយ។ អ្វីដែលធ្វើឲ្យខ្ញុំក្តុកក្តួលចិត្តបំផុតទប់ទឹកភ្នែកមិនបាននោះ គឺឃើញអ្នកម្តាយយកបង្ហើចខោអាវរបស់លោកឪពុក និងរបស់បងកំសាន្ត (គាត់ស្លាប់កាលពី១១ខែមុន) មកស្រាយហើយថើប និងយំរៀបរាប់ថា «កូនទៅចោលម្តាយមិនទាន់បានមួយឆ្នាំផង ប្តីទៅចោលទៀត» «រូបកាយអ្នកទាំងពីរបាត់បង់ទៅហើយ នៅសល់តែក្លិនធ្វើឲ្យអ្នកនៅរស់សែននឹករលឹកសោកសង្រេងខ្លាំងណាស់»។

ប្រមាណជាមួយខែក្រោយព្រឹត្តិការណ៍ថ្ងៃ១៥មេសា លោកមា ចាន់អ៊ុក និងចាន់ អ៊ុល រស់នៅភូមិទ័ពសៀមដែលជាប្អូនជីដូនមួយ និងដែលសុទ្ធតែមានសន្តានចិត្តគោរពស្រលាញ់លោកឪពុកយ៉ាងជ្រាលជ្រៅ ហើយមានសេចក្តីក្លាហានប្រឈមមុខនឹងអន្តរាយផងនោះ បានទៅគាស់យកអដ្ឋិធាតុលោកឪពុកចេញពីផ្នូររួម។ លោកមាទាំងពីរបានខ្ចប់អដ្ឋិធាតុនឹងក្រណាត់មួយផ្ទាំងដឹកតាមរទេះគោក្នុងពេលយប់ជ្រៅដើម្បីគេចពីភ្នែកអន្តរាយ។ នៅតាមផ្លូវ ឈ្លបម្នាក់បានសួរថាដឹកអីមកពីណាៗ លោកមាឆ្លើយថាដឹកប្រហុកមកពីទន្លេ ឈ្លបនោះក៏ឈប់សួរដេញដោលៗ

ពួកលោកមា និងមីងៗបានរៀបចំធ្វើពិធីបូជានៅក្នុងភូមិទ័ពសៀមដែលពួកគាត់រស់នៅដោយមានចាស់ៗមួយចំនួនសូត្របង្សុកូលផងដែរ។ ពិធីដ៏ប្រថុយប្រថាននោះ ធ្វើដោយសង្ខេបបំផុតដោយខ្លាចក្រែងពួកកងឈ្លបមកឃើញ។ ភ្លាមៗក្រោយបូជារួច លោកយាយហួត បានយកក្រណាត់ជាឌឹបសមួយផ្ទាំងតូចវេចខ្ចប់ធាតុ ហើយទុកលាក់ក្នុងកន្ត្រកម្លូដើរសំដៅទៅផ្ទះនៅឯភូមិតាភ្វាជាមួយនឹងទឹកភ្នែកហូរសស្រាក់ៗ នៅពេលទៅដល់កាំជណ្តើរផ្ទះ គាត់ស្រែកទ្រហោរយំរៀបរាប់ថា «កូនតែមួយគ្រាប់របស់ម្តាយអើយ! កាលពីថ្មីៗហ្នឹងសោះដែលកូនចាកចេញទៅជាមួយនឹងរូបកាយទាំងសាច់ទាំងឈាម តែពេលនេះម្តេចក៏កូនត្រឡប់មកវិញក្នុងរូបរាងជាផេះជាធ្យូងទៅវិញ?»ៗ ពេលនោះគ្មានអ្នកណាម្នាក់អាចទប់អារម្មណ៍មិនឲ្យក្តុកក្តួលទប់ទឹកភ្នែកមិនឲ្យហូរចំពោះមហាទុក្ខសោកដែលមានជំរៅដូចបាតសមុទ្រនេះបានឡើយ។

ប៉ុន្មានថ្ងៃក្រោយមកប្រធានភូមិបានដឹងពីរឿងបូជាសព ហើយចោលសំដីដៀមដាមថា មានអ្នកខ្លះថាធ្វើបុណ្យឲ្យខ្មាំងដែលប្រឆាំងនឹងបដិវត្តន៍ៗ ជាសំណាងល្អ ដែលគាត់នោះមិនបាន

***(តនៅលេខក្រោយ)***





# បញ្ជីឈ្មោះអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម ចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

***ផាន់ផាន់ ពៅដារ៉ា និង ឡុង ដានី***

(តចប់)

**ទួន សារយ៉េន** *ហៅ អាត មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ុំ ទួនយឹម និងអ៊ុំស្រី អៀម សៀម មានប្រពន្ធឈ្មោះ ខៃហៅ ឡា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសាលាបច្ចេកទេសឫស្សីកែវ ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ០៥ បន្ទប់តូច ៤ៗ ខ្មែរក្រហមសម្លាប់ ទួន សាយ៉េន នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៤៥ ថ្ងៃៗ*

**ទួន សុខផល្លា** *ហៅ កឿន មានអាយុ៣៤ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅពាមជីលាំង ខេត្តកំពង់ចាម ជាកូនរបស់អ៊ុំ ទួនគឹមស៊ា និងអ៊ុំស្រី ទឹក ហៅអ៊ាន មានប្រពន្ធឈ្មោះ ទួនចាន់ដាវ៉ា ហៅ ភាន់មានកូនប្រុស ៣ នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្រសួងសា-ធារណការ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១បន្ទប់ធំ០៥ បន្ទប់តូច២ៗ ខ្មែរក្រហមសម្លាប់ ទួនសុខផល្លាឬ ទួនសុផល្លា នៅថ្ងៃទី៦ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៦៥ ថ្ងៃៗ*

**ធៀង គីនី** *មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៦ ស្រុកកំណើតនៅក្រមួនសរ ខេត្តកម្ពុជាក្រោម ឪពុកម្តាយឈ្មោះ ទៀង បូផាមាស និង ស៊ុំ សុផាន់ មានប្រពន្ធឈ្មោះ ទូច យ៉ានី មានកូនប្រុស ២នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្រុងភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ យ បន្ទប់ធំ ៥ បន្ទប់តូច ១១ៗ ខ្មែរក្រហមសម្លាប់ ទៀង គីនី នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ៗ*

**ធៀង ឆន** *ហៅ ថា ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅស-២១ ឃ ក្នុងឆ្នាំ១៩៧៦ៗ ខ្មែរក្រហមចាប់បញ្ជូន ទៀត ឆន ឬ ទៀង ចន ហៅ ថា ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ៗ*

**ធៀប ផាត់** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៦ៗ ខ្មែរក្រហមចាប់បញ្ជូន ទៀប ផាត់ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៦២ ថ្ងៃៗ*

**ធៀប ស៊ីថុន** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ៗ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយៗ*

**ធៀវ កូស៊ិត** *មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅសង្កែ ខេត្តបាត់ដំបង ជាកូនរបស់ពូទៀវ ឃៀប និងមីង ជុស អ៊ួច មានប្រពន្ធឈ្មោះ ស៊ុំវុឌ្ឍី ហៅ ប៊ិច មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គីសនីចាក់អង្រែ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ កបន្ទប់ធំ០៧ បន្ទប់តូច១២ៗ ខ្មែរក្រហមចាប់បញ្ជូន ទៀវ កូស៊ិត ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦ៗ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយៗ*

**ទេប ឬ ទេព សារ៉ន** *ហៅ ទេប សំរិត មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកៀនស្វាយ ខេត្ត*

កណ្តាល ជាកូនរបស់ពូ ទេប ម៉ង និងមីង ម៉ុល មុង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង១៣ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ១ បន្ទប់តូច ១១។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ទេព ឌីណា** ហៅ គុប មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៧ អតីតសមាជិកគណៈនារីនៅប៉េកាំង មានស្រុកកំណើតនៅកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាកូនរបស់អ៊ំ ទេព ជុំ និងអ៊ំស្រី តាន់ យូ ហៀង មានប្តីឈ្មោះ ព្រុំ ភឿន ចាប់ខ្លួននៅស្រុកចំការលើ ថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ០៥ បន្ទប់តូច ៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ ព្រុំ ភឿន ជាប្តីត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកគុកទួលស្លែងជាមួយប្រពន្ធដែរ តែសម្លាប់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។

**ទេព ថារីណៃ** ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅ ស-២១យ ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដលគុកទួលស្លែង និងការសម្លាប់នៅឡើយ។

**ទេព ទ្រី** មានអាយុ៤៣ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅដង្កោ ខេត្តកណ្តាល ជាកូនរបស់អ៊ំ ទេព ហ៉ម និងអ៊ំស្រី ព្រាក់ ភួង មានប្រពន្ធឈ្មោះ ពៅ ដារី ហៅ គង់ មានកូនប្រុស ១នាក់និងស្រី ៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនកំពង់សោម ខែកក្កដា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១២ បន្ទប់ធំ ១។ ខ្មែរក្រហមចាប់បញ្ជូន ទេព ទ្រី ទៅដល់គុកទួលស្លែងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧៩ ថ្ងៃ។

**ទេព បក្ស** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់២៥ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ទេព បក្ស ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៤ ឬ ២៥ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦។

**ទេព ប៊ុនមុនី** ហៅ ប៊ុង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅតាឡូ នៅថ្ងៃទៅ១ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ទេព ប៊ុនមុនី នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៥ ថ្ងៃ។

**ទេព ផល្លា** ហៅ ឈុន មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ ទេព ឈុំ និងមីង យុន ម៉ៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថាមពល ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទេព ផល្លា នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥៦ ថ្ងៃ។

**ទេព លន** ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅ ស-២១យ ក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ទេព លន ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ទេព សួបុផា** ហៅ ផា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតាឡៃ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ទេព សួបុផា ឬ ទេព សួងបូផា នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៦ ថ្ងៃ។

**ទេព សំអន** ហៅ សំអាន មានអាយុ៤០ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតអ្នកការទូត មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់អ៊ំ ទេព ជឿន និងអ៊ំស្រី សោម សឹ មានប្រពន្ធឈ្មោះ ហូដាហាស្សាន់ (អេស្ស៊ីប) មានកូនប្រុស ២នាក់ និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៧៦ នៅភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ១ បន្ទប់តូច ៩។ ខ្មែរក្រហមចាប់បញ្ជូន ទេព សំអនឬ ទេព សំអាន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៨ ឬ ២៣ ឬ ២៨ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧។

**ទេព ហឿន** មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះអណ្តែត ខេត្តតាកែវ ជាកូនរបស់ពូ ទេព ញឹម និងមីង ធំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង១៣ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ព្រុំ សែលី** មានអាយុ ២៨ឆ្នាំ គិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ជាកូនរបស់ពូ ព្រុំ ប៉ែន និងមីង ឡាប់។ ខ្មែរក្រហមចាប់ខ្លួន សែលី នៅថ្ងៃទី១៥ខែមករា ឆ្នាំ១៩៧៧។

**ម៉ី ថុល** មានអាយុ៤៤ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅត្បូងឃ្មុំ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ម៉ី ផេង និងអ៊ំស្រី ស្វាយ នាង។ ខ្មែរក្រហមបានចាប់ខ្លួនពូថុល នៅព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយព្យ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ ហើយក្រោយមកបញ្ជូនគាត់មកដល់គុកទួលស្លែងនៅថ្ងៃទី២០ឬ២៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ (មានឯកសារពីរនិយាយខុសគ្នាលើថ្ងៃដែលបញ្ជូនមកដល់គុកទួលស្លែង)។ ខ្មែរក្រហមសម្លាប់ពូ ថុល នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំដដែល (ទំនងជាសម្លាប់នៅបឹងជើងឯក)។

**ពៅ ឃុន** ហៅ ហួរ មានអាយុ២៩ឆ្នាំគិតត្រឹមឆ្នាំ១៩៧៥ ជាអតីតគ្រូបង្រៀន មានស្រុកកំណើតនៅស្រុកបាភ្នំខេត្តព្រៃវែង ជាកូនរបស់ពូ ពៅ ទុយ និង មីង តៅ ណៅ ។ ចាប់ខ្លួនថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅព្រែកព្នៅ ដោយមូលហេតុធ្វើដំណើរឥតលិខិតពីកំពង់ស្ពឺទៅព្រៃវែង ដើម្បីឲ្យបានជួបគ្រួសារ និងឪពុកម្តាយ។ ខ្មែរក្រហមបានបញ្ជូន ពៅ ឃុន បន្តទៅដល់គុកទួលស្លែងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦។ រំលងបាន ៥០ថ្ងៃ ខ្មែរក្រហមបានសម្លាប់ ពៅ ឃុន នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំដដែល (ទំនងជាសម្លាប់នៅបឹងជើងឯក)។

**សុក រ៉ាត** មានអាយុ៤១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខេត្តកំពត ជាកូនរបស់អ៊ំ សុក ញឹប និង អ៊ំស្រី លិម សិត។ ខ្មែរក្រហមបានចាប់ខ្លួនពូ រ៉ាត នៅភូមិព្រែកប៊ិន តំបន់២៥ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៦ ដោយពាក់ព័ន្ធក្នុងរឿង សេ.អ៊ី.អា ដោយសារការខ្ទះខាតក្នុងជីវភាពរស់នៅ ហើយបញ្ជូនគាត់ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ខ្មែរក្រហមបានសម្លាប់គាត់នៅថ្ងៃទី២១ ខែឧសភា ឆ្នាំដដែល បន្ទាប់ពីជាប់នៅគុកទួលស្លែងបាន ៥៧ ថ្ងៃ។

**ហៃ ស៊ាប** ហៅ ផាត មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅវ៉ារិន ខេត្តសៀមរាប ជាកូនរបស់ពូ ហៃ និងមីង សេក គីម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសៀមរាប តំបន់ ១០៦ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមចាប់បញ្ជូន ហៃ ស៊ាប ហៅ ផាត ទៅដល់គុកទួលស្លែងនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៨១ ថ្ងៃ។

**ឡាត់** ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ បើយោងតាមឯកសារផ្សេងៗ ឈ្មោះ ឡាត់ មានច្រើនលើសពីម្នាក់ ក៏ប៉ុន្តែមានត្រកូលខុសៗគ្នា ហើយគ្មានរូបថតទេ។

**ឡាយ ឡេង (ឡេង)** ត្រូវជាប្រពន្ធរបស់លោក លី ប៊ុនឈាង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅវៀតណាម ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនចូលដល់គុកទួលស្លែងនៅថ្ងៃដដែល។ ខ្មែរក្រហមបានសម្លាប់មីង ឡាយ ឡេង នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់គុកទួលស្លែងបាន ៩៥ ថ្ងៃ។

**អ៊ិម ថុក (ថុត)** មានអាយុ៣៦ឆ្នាំ គិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបាត់ដំបង ខេត្តបាត់ដំបង ជាកូនរបស់អ៊ំ អ៊ុម ធុច និងអ៊ំស្រី ណាប់ ជូ មានប្រពន្ធឈ្មោះ មុំ មៃ។ ខ្មែរក្រហមចាប់ខ្លួនពូ ថុក នៅអគ្គិសនី ១ ក្នុងខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនចូលដល់គុកទួលស្លែងនៅថ្ងៃទី២៨។ ខ្មែរក្រហមសម្លាប់ពូ ថុក នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ ក្រោយពេលដែលពូបានជាប់គុកទួលស្លែងអស់រយៈពេល ៦២ថ្ងៃ។

**ការបោះពុម្ពផ្សាយរឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ**

ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាប្រជាជនកម្ពុជាគ្រប់រូប និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅ អំពីរឿងរ៉ាវពិតផ្ទាល់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម ហើយមានបំណងផ្សព្វផ្សាយ សូមផ្ញើមកទស្សនាវដ្តីស្វែងរកការពិតតាមអាសយដ្ឋាន ៖ ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ឬ (៨៥៥) ៩៩៦ ៧៥០

អ៊ីម៉ែល៖ truthbunthorn.s@dccam.org - គេហទំព័រ៖ www.dccam.org

រូបក្របមុខ៖
កងចល័តលើកភ្លឺស្រែនៅការដ្ឋានការងារមួយកន្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



រូបក្របក្រោយ៖
កុមារីឡើងអានអក្សរដែលសរសេរនៅលើក្តារខៀន ដោយគ្រូនិងសិស្ស នៅឈរស្តាប់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 247, July 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.